## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអភិវឌ្ឍន៍ជនបទ

# គោលការណ៍ណែនាំ
# ស្តីពី
# ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ




**ខែឧសភា ឆ្នាំ ២០២៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអភិវឌ្ឍន៍ជនបទ

# គោលការណ៍ណែនាំ
# ស្តីពី
# ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ




ខែឧសភា ឆ្នាំ ២០២៣

# មាតិកា


**បុព្វកថា** ........ 3

**សេចក្តីថ្លែងអំណរគុណ** ........ 5

**អក្សរកាត់** ........ 6

**សន្ទានុក្រម** ........ 9

**បញ្ជីតារាង** ........ 11

**បញ្ជីរូបភាព** ........ 11

**១. ស្ថានភាពបច្ចុប្បន្ន នៃការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ** ........ 12

**២. និន្នាការទូទៅ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ** ........ 15

២.១ សេចក្តីផ្តើម ........ 15

២.២ លទ្ធផលផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ........ 17

**៣. ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ** ........ 18

៣.១ **ជំហានទី ១៖** ការចូលរួមរបស់សហគមន៍ និងការបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ........ 19

៣.១.១ ថ្នាក់ឃុំ ........ 19

៣.១.២ ថ្នាក់ភូមិ ........ 22

៣.១.៣ តួនាទី និងការទទួលខុសត្រូវ ........ 24

៣.២ **ជំហានទី ២៖** ការគូសផែនទី និងការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ 26

៣.២.១ ការគូសផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ........ 26

៣.២.២ ការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ........ 28

៣.៣ **ជំហានទី ៣៖** ការកំណត់ និងការវាយតម្លៃគ្រោះថ្នាក់ និងវិធានការការពាររួមបញ្ចូលហានិភ័យដែលបង្កឡើងដោយអាកាសធាតុ ........ 30

៣.៣.១ ជំហាន ៣.ក ការកំណត់មុខសញ្ញាគ្រោះថ្នាក់ និងការធ្វើតេស្តគុណភាពទឹក ........ 30

៣.៣.២ ជំហាន ៣.ខ ការវាយតម្លៃគ្រោះថ្នាក់ដែលបង្កដោយអាកាសធាតុ និងបរិស្ថាន និងផលប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងប្រភពទឹក ........ 33

៣.៣.៣ ជំហាន ៣.គ ការវាយតម្លៃអំពីគ្រោះថ្នាក់ និងវិធានការត្រួតពិនិត្យ តាមដាន ........ 34

៣.៤. **ជំហានទី ៤ ៖** ការរៀបចំ និងការអនុវត្តផែនការកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលធន់នឹងអាកាសធាតុ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ........ 38

៣.៤.១ ការរៀបចំផែនការកែលម្អ ........ 38
៣.៤.២ ការអនុវត្តផែនការកែលម្អ ........ 40
៣.៤.៣ សកម្មភាពលើកកម្ពស់ការយល់ដឹង ........ 41
**៣.៥ ជំហានទី ៥ ៖** ការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាព និងការទំនាក់ទំនង នៃលទ្ធផល ........ 44
៣.៥.១ សេចក្តីផ្តើម ........ 44
៣.៥.២ វិធីសាស្ត្រ នៃការត្រួតពិនិត្យ ការតាមដាន ........ 45
៣.៥.៣ ការទំនាក់ទំនង នៃលទ្ធផល ........ 45
**៣.៦ ជំហានទី ៦ ៖** ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព នៃផែនការកែលម្អ ........ 46
**៤. ការរៀនសូត្រឡើងវិញ និងការទទួលស្គាល់** ........ 47
**៥. ថវិកាសម្រាប់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ** ........ 50
**៦. ឧបសម្ព័ន្ធ** ........ 52
**ឧបសម្ព័ន្ធ ក.** គំរូសៀវភៅផែនការសុវត្ថិភាពថ្នាក់ឃុំ ........ 52
ជំហានទី ១ ៖ ការចូលរួមរបស់សហគមន៍ និងការបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុ ........ 54
ជំហានទី ២ ៖ ការគូសផែនទី និងការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ 57
ជំហានទី ៣ ៖ ការកំណត់គ្រោះថ្នាក់ និងវិធានការឆ្លើយតប ........ 61
ជំហានទី ៤ ៖ ផែនការកែលម្អនៅថ្នាក់ឃុំ ........ 69
ជំហានទី ៥ ៖ ផែនការត្រួតពិនិត្យ តាមដាន ........ 72
**ឧបសម្ព័ន្ធ ខ.** ការកំណត់ និងការវាយតម្លៃហានិភ័យដោយគ្រោះមហន្តរាយ ........ 75

# បុព្វកថា

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ដែលចាត់ទុកជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ឆ្នាំ ២០១៤-២០២៥ បានកំណត់អាទិភាពអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជា និងជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងសំណង់អនាម័យជនបទ។ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់សេវាកម្មទឹក ដោយផ្តោតយ៉ាងសំខាន់លើគុណភាព និងសុវត្ថិភាពទឹកនោះ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើត និងរៀបចំគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដើម្បីជាឧបករណ៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់យកទៅប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកជនបទ។

គុណភាព និងសុវត្ថិភាពទឹក គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍ និងសុខមាលភាពរបស់មនុស្ស។ ការផ្តល់នូវការទទួលបានទឹកផឹកប្រកបដោយសុវត្ថិភាព បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុខភាព និងកាត់បន្ថយភាពក្រីក្រ។ ថ្នាក់ដឹកនាំពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជា បានអនុម័តយកការអភិវឌ្ឍប្រកបដោយចីរភាព ហើយក្នុងនោះមានគោលដៅជាក់លាក់មួយលើវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ។ គោលដៅ ៦.១ បានបញ្ជាក់អំពីការតាំងចិត្ត ដើម្បីសម្រេចឲ្យបានជាសកលនូវសមភាព នៃការទទួលបានទឹកសុវត្ថិភាព និងអាចទទួលយកបានសម្រាប់គ្រប់ៗគ្នានៅឆ្នាំ ២០៣០ និងដើម្បីឈានទៅសម្រេចឲ្យបាន ១០០ ភាគរយ នូវទស្សនវិស័យយុទ្ធសាស្ត្រជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ ២០១១-២០២៥ ដែលបានចែងថា “ **នៅឆ្នាំ ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថាន ដែលមានអនាម័យប្រកបដោយនិរន្តរភាព** ”។

ការធានាឲ្យសម្រេចបានទាន់ពេលវេលានូវទស្សនវិស័យ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺនៅតែជាបញ្ហា និងការប្រឈមដ៏សំខាន់។ ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៥ គឺមានតែ ៥២% នៃប្រជាជននៅតំបន់ជនបទ ទទួលបានប្រភពទឹកដែលមានការកែលម្អប៉ុណ្ណោះ ហើយភាគច្រើន នៃអ្នកទាំងនោះកំពុងផឹកទឹកដែលពុំទាន់មានសុវត្ថិភាពសម្រាប់សុខភាព។ តាមការសិក្សានាពេលថ្មីៗនេះរបស់អង្គការសុខភាពពិភពលោក បានរកឃើញថា គឺមានតែ ២៣% នៃគ្រួសារនៅតំបន់ជនបទផឹកទឹកមានសុវត្ថិភាព (ផ្នែកគុណភាពមីក្រូជីវសាស្ត្រ) ប៉ុណ្ណោះ។ វាមានមូលហេតុជាច្រើន ដែលបណ្តាលឲ្យទឹកផឹកមិនមានសុវត្ថិភាព ដូចជា ការបំពុលប្រភពទឹក វិធីសាស្ត្រមិនមានអនាម័យក្នុងការដឹកជញ្ជូនទឹក និងស្តុកទឹក។

គោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ គឺបានបង្ហាញអំពីវិធីសាស្ត្រជាជំហានៗ សម្រាប់ធ្វើឲ្យប្រសើរឡើងនូវគុណភាពទឹកផឹកជនបទ និងធ្វើឲ្យការផ្គត់ផ្គង់ទឹកកាន់តែមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ក្នុងនោះក៏មានព័ត៌មាន

សំខាន់ៗលើសុវត្ថិភាពទឹកជនបទផងដែរ ឧទាហរណ៍ ព័ត៌មានលើការបន្សុទ្ធ និងស្តុកទឹកឲ្យមានសុវត្ថិភាពតាមគ្រួសារ ដែលមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា គឺដោយសារតែប្រជាជននៅតំបន់ជនបទភាគច្រើនមិនទាន់ទទួលបានការផ្គត់ផ្គង់ទឹកផឹកមានសុវត្ថិភាព និងអាចទុកចិត្តបាន។

គោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺអាចអនុវត្តន៍បានដោយមន្ទីរអភិវឌ្ឍន៍ជនបទ អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងសហគមន៍ ដើម្បីការពារការបំពុលទឹកផឹកពីប្រភពទឹកដល់ចំនុចផឹកទឹក។ គោលការណ៍ណែនាំនេះ ក៏ជួយជានាឲ្យមានការអនុលោមតាមលក្ខខណ្ឌក្នុងគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទផងដែរ។ គោលការណ៍ណែនាំនេះបានបង្កើតឡើងដោយផ្អែកលើបទពិសោធន៍ដែលទទួលបានពីការអនុវត្តគម្រោងផែនការសុវត្ថិភាពទឹកជនបទសាកល្បងនៅក្នុងខេត្តព្រៃវែង និងកំពង់ស្ពឺ និងលទ្ធផលពីការពិគ្រោះយោបល់ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៥ រាជធានីខេត្ត។ ជាមួយគ្នានេះដែរ ក៏មានការផ្តល់យោបល់ពីសាកលវិទ្យាល័យ អង្គការ ដៃគូអភិវឌ្ឍន៍លើវិស័យទឹក ការសំអាត និងអនាម័យ ក្រុមប្រឹក្សាឃុំ សាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងនាមក្រសួងអភិវឌ្ឍន៍ជនបទ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងការបង្កើត និងរៀបចំគោលការណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ។

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រី**

**បណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន**

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ ត្រូវបានបង្កើត និងរៀបចំឡើងដោយក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា។

ក្នុងនាមក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ឯកឧត្តម **អ៊ុក ពញ្ញា** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ឯកឧត្តម **ទ្រី មេង** រដ្ឋលេខាធិការ ឯកឧត្តមបណ្ឌិត **នួន ដាញ៉ិល** រដ្ឋលេខាធិការ ឯកឧត្តម **យឹម ជុង** រដ្ឋលេខាធិការ ឯកឧត្តម **នួន ពេជ្រនិមិត្ត** អនុរដ្ឋលេខាធិការ ឯកឧត្តម **អ៊ឹង ខណ្ណា** អនុរដ្ឋលេខាធិការ និងឯកឧត្តម **ជ្រាយ ប៉ុម** អគ្គនាយកបច្ចេកទេស ដែលបានគាំទ្រ និងណែនាំដ៏ខ្ពង់ខ្ពស់ដល់ការបង្កើត និងរៀបចំគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធនានាដែលបានផ្តល់មតិ យោបល់ក្នុងការបង្កើត រៀបចំ និងចូលរួមផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ។

ថ្ងៃចន្ទ ៣ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០២៣

**ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ**

ស្រ៊ុន ពុទ្ធី

# អក្សរកាត់

- BCC : Behavior Change Communication ការផ្សព្វផ្សាយដើម្បីផ្លាស់ប្តូរឥរិយាបទ
- BSF : BioSand Filter ធុងចម្រោះជីវខ្សាច់
- CFU : Colony-Forming Units (measurement of bacteria in water) ឯកតាសម្រាប់កូលីហ្វម ឬអ៊ីកូលី
- CBO : Community Based Organization អង្គការសហគមន៍មូលដ្ឋាន
- CC : Commune Council ក្រុមប្រឹក្សាឃុំ
- CCWC : Commune Committee for Women and Children គណៈកម្មាធិការឃុំ ទទួលបន្ទុកការងារស្ត្រី និងកុមារ
- CDHS : Cambodia Demographic and Health Survey អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា
- CDP : Capacity Development Plan ផែនការអភិវឌ្ឍន៍សមត្ថភាព
- CFP : Commune Focal Point (for RWSSH) ជនបង្គោលឃុំ (សម្រាប់ការងារវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ)
- CIPS : Cambodia Inter-Censal Population Survey អង្កេតចន្លោះជំរឿនប្រជាសាស្ត្រកម្ពុជា
- CLTS : Community Led Total Sanitation សហគមន៍ដឹកនាំអនុវត្តន៍កម្មវិធីអនាម័យ ទាំងស្រុង
- CMDG : Cambodian Millennium Development Goal គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- CSES : Cambodia Socio-Economic Survey អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា
- CWP : Ceramic Water Purifier ធុងចម្រោះសេរ៉ាមិច
- DA : District Administration រដ្ឋបាលថ្នាក់ស្រុក
- DOECD : District Office of Economic and Community Development ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគមន៍
- DOSH : Department of School Health (Ministry of Education, Youth and Sport) នាយកដ្ឋានសុខភាពសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា)
- DP : Development Partner ដៃគូអភិវឌ្ឍន៍
- DRHC : Department of Rural Health Care (MRD) នាយកដ្ឋានថែទាំសុខភាពជនបទ (ក្រសួងអភិវឌ្ឍន៍ជនបទ)
- DRWS : Department of Rural Water Supply (MRD) នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ (ក្រសួងអភិវឌ្ឍន៍ជនបទ)
- HC : Health Center មណ្ឌលសុខភាព
- HF : Health Facility (includes Health Centers or Health Posts) មូលដ្ឋានសុខាភិបាល (រួមមាន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព)
- HH : Household គ្រួសារ (ខ្នងផ្ទះ)

- KAP : Knowledge, Attitudes and Practice (Survey) ចំណេះដឹង ឥរិយាបទ និងការប្រព្រឹត្ត (អង្កេត)
- µg/l : Micrograms per Liter (unit of concentration in water) មីក្រូក្រាមក្នុងមួយលីត្រ (ខ្នាតសូលុយស្យុងទឹក)
- µS/cm : Microsiemens per centimeter (electrical conductivity of water, used to approximate "total dissolved solids") ឯកតាសម្រាប់វាស់ភាពឆ្លងចរន្តក្នុងទឹក
- mg/l : Milligrams per Liter (unit of concentration in water) មីលីក្រាមក្នុងមួយលីត្រ (ខ្នាតសូលុយស្យុងទឹក)
- MRD : Ministry of Rural Development ក្រសួងអភិវឌ្ឍន៍ជនបទ
- MISTI : Ministry of Industry, Science, Technology and Innovation ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- MOEYS : Ministry of Education, Youth and Sport ក្រសួងអប់រំ យុវជន និងកីឡា
- MOH : Ministry of Health ក្រសួងសុខាភិបាល
- MOI : Ministry of Interior ក្រសួងមហាផ្ទៃ
- MPN : Most Probable Number (measurement of bacteria in water) ឯកតាសម្រាប់វាស់កូលីហ្វម ឬអ៊ីកូលី
- NAP : National Action Plan ផែនការសកម្មភាពជាតិ
- NGO : Non-Governmental Organization អង្គការមិនមែនរដ្ឋាភិបាល
- NSDP : National Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- NSP : National Strategic Plan (for RWSSH 2014-2025) ផែនការយុទ្ធសាស្ត្រជាតិ (សម្រាប់វិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទឆ្នាំ ២០១៤-២០២៥)
- NTU : Nephelometric Turbidity Unit ឯកតាសម្រាប់វាស់ភាពល្អក់ក្នុងទឹក
- O&M : Operation and Maintenance ប្រតិបត្តិការ និងការថែទាំ
- OD : Open Defecation ការបន្ទោរបង់ពាសវាលពាសកាល
- ODF : Open Defecation Free ការបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង
- PAP : Provincial Action Plan ផែនការសកម្មភាពខេត្ត
- PDRD : Provincial Department of Rural Development មន្ទីរអភិវឌ្ឍន៍ជនបទ
- PED : Provincial Education Department (MOEYS) មន្ទីរអប់រំ យុវជន និងកីឡា
- PHD : Provincial Health Department (MOH) មន្ទីរសុខាភិបាល
- RSH : Rural Sanitation and Hygiene ការសំអាត និងអនាម័យជនបទ
- RWS : Rural Water Supply ការផ្គត់ផ្គង់ទឹកជនបទ
- RWSP : Rural Water Safety Plan ផែនការសុវត្ថិភាពទឹកជនបទ

- RWSSH : Rural Water Supply, Sanitation and Hygiene ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ
- SDG : Sustainable Development Goal គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- SNV : Netherlands Development Organization អង្គការអភិវឌ្ឍន៍ហូឡង់
- TWG : Technical Working Group for RWSSH ក្រុមការងារបច្ចេកទេសសម្រាប់វិស័យផ្គត់ផ្គង់ទឹក ការសំអាត និងការលើកកម្ពស់អនាម័យជនបទ
- UNICEF : United Nations Children's Fund មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ
- VFP : Village Focal Point ជនបង្គោលភូមិ
- WASH : Water, Sanitation and Hygiene ទឹក ការសំអាត និងអនាម័យ
- WHO : World Health Organization អង្គការសុខភាពពិភពលោក
- WSP : Water and Sanitation Program of the World Bank កម្មវិធីទឹក ការសំអាត និងអនាម័យ នៃធនាគារពិភពលោក
- WSUG : Water and Sanitation User's Group ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ

# សន្ទានុក្រម

- **ធនធានទឹក៖** គឺជាប្រភពទឹកដែលមានប្រយោជន៍ ឬមានសក្តានុពលសំខាន់សម្រាប់មនុស្ស និងបរិស្ថាន។ ឧទាហរណ៍ ការប្រើប្រាស់ជាច្រើន ដូចជា កសិកម្ម ឧស្សាហកម្ម តាមផ្ទះប្រជាជន កន្លែងកំសាន្ត និងការអភិរក្សបរិស្ថាន។ ការប្រើប្រាស់របស់មនុស្សភាគច្រើនជាទឹកមកពីប្រភពទឹកសាប។
- **ប្រភពទឹក៖** គឺសំដៅទៅកន្លែងដែលទឹកអាចទាញយកមកប្រើប្រាស់បាន ដូចជា ទឹកក្រោមដី ទឹកលើដី និងទឹកផុស ។
- **ការផ្គត់ផ្គង់ទឹក៖** គឺការផ្តល់ទឹកប្រើប្រាស់តាមផ្ទះសម្រាប់ ផឹក បោកគក់ លាងសំអាត ងូត និងទឹកប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ច។
- **ការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ៖** គឺសំដៅទៅលើការផ្គត់ផ្គង់ទឹកដែលបានមកពីប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ អណ្តូងគ្រប់ប្រភេទ ប្រភពទឹកលើដីដែលមានបំពាក់ប្រព័ន្ធចម្រោះ ប្រព័ន្ធត្រងទឹកភ្លៀង និងស្ថានីយផលិតទឹកផឹកសហគមន៍ ។
- **ការទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ៖** គឺសំដៅទៅលើលទ្ធភាពទទួលបានទឹកពីប្រភពទឹកដែលមានការកែលម្អ ដែលចំណាយពេលទៅយក និងមកវិញ រួមទាំងពេលរង់ចាំមិនលើសពី ៣០ នាទី។
- **ទឹកស្អាត ៖** គឺជាទឹកដែលថ្លា គ្មានក្លិន គ្មានពណ៌ គ្មានរសជាតិ គ្មានមេរោគ និងគ្មានសារធាតុគីមីលើសកំណត់ ហើយមិនប៉ះពាល់ដល់សុខភាព។
- **ទឹកសុវត្ថិភាព៖** គឺជាទឹកស្អាត ដែលផឹកបានគ្រប់វ័យ គ្រប់ទីកន្លែង និងគ្រប់ពេលវេលា។
- **ការបន្សុទ្ធ និងការស្តុកទឹកឲ្យមានសុវត្ថិភាពតាមគ្រួសារ៖** គឺជាវិធីសាស្ត្រក្នុងការធានាទឹកផឹកក្នុងគ្រួសារមានសុវត្ថិភាព (ឧទាហរណ៍ គុណភាពទឹកផឹកស្របតាមកម្រិតកំណត់ក្នុងគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ របស់ក្រសួងអភិវឌ្ឍន៍ជនបទ)។ វិធីសាស្ត្របន្សុទ្ធទឹកក្នុងគ្រួសារមានដូចជា ចម្រោះទឹក និងដាំទឹក។ល។ វិធីសាស្ត្រអំពីរបៀបទុកដាក់ទឹកផឹកឲ្យមានសុវត្ថិភាពមានដូចជា ការប្រើប្រាស់ធុងទឹកស្អាតភ្ជាប់ជាមួយរ៉ូប៊ីណេ ដែលការពារពីការប៉ះពាល់ទឹកដោយដៃ ឬសម្ភារផ្សេងៗ។
- **ផែនការសុវត្ថិភាពទឹក៖** គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពមួយក្នុងការធានាសុវត្ថិភាព នៃការផ្គត់ផ្គង់ទឹក។ វាគឺជាការវាយតម្លៃគ្រប់ជ្រុងជ្រោយលើហានិភ័យ និងគ្រប់គ្រងហានិភ័យគ្រប់ជំហាន ចាប់ពីប្រភពទឹករហូតដល់ការប្រើប្រាស់ចុងក្រោយ។ គោលបំណងរួម គឺដើម្បីធានាឲ្យបាននូវសុវត្ថិភាពទឹកប្រើប្រាស់តាមរយៈ ៖ ១) ការស្វែងរកប្រភពទឹកគ្រប់គ្រាន់ពេញមួយឆ្នាំ និងការបង្ការការបំពុលប្រភពទឹក ២) ការបន្សុទ្ធទឹកដើម្បីកាត់បន្ថយសារធាតុចម្លងរោគទាំងអស់ ៣) ការបង្ការការកើតឡើងវិញ នៃសារធាតុចម្លងបាក់តេរី/មេរោគក្នុងអំឡុងពេលស្តុកទឹក ចែកចាយទឹក និងការប្រើប្រាស់ទឹកចុងក្រោយ ដូចជា ទឹកផឹក។
- **គ្រោះថ្នាក់៖** គឺជាហានិភ័យដែលអាចកើតចេញពីហេតុការណ៍អាក្រក់ ដូចជា កង្វះខាតប្រភពទឹក ការបំពុលប្រភពទឹក ទឹកជំនន់ដែលបង្កឲ្យមានពពួកបាក់តេរីចម្លងរោគ ឬសារធាតុគីមីចូលក្នុងទឹកប្រើប្រាស់ ហើយបណ្តាលឲ្យប៉ះពាល់ដល់សុខភាពប្រជាជន។ គ្រោះថ្នាក់អាចមានកម្រិតទាប មធ្យម ឬខ្ពស់ ហើយអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។
- **វិធានការការពារ៖** គឺជាសកម្មភាព ឬវិធីសាស្ត្រគ្រប់គ្រង ឬជាមធ្យោបាយផ្សេងៗ នៃការការពារ ការកាត់បន្ថយ ឬការបំបាត់សារធាតុពុល និងមេរោគពីប្រភពទឹក ឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។

- **ការតាមដាន និងត្រួតពិនិត្យគុណភាពទឹក៖** គឺជាសកម្មភាពយកសំណាកទឹកទៅវិភាគជាទៀងទាត់ ដើម្បីដឹងពីគុណភាពទឹក។
- **បង្គន់អនាម័យដែលមានការកែលម្អ៖** គឺសំដៅទៅលើបង្គន់ចាក់ទឹកដែលតភ្ជាប់ទៅនឹងប្រព័ន្ធលូបង្ហូរទឹកស្អុយ ឬភ្ជាប់ទៅនឹងអាងស្តុកលាមក ឬរណ្តៅមានគម្រប បង្គន់ស្ងួតដែលមានជើងបង្គន់សម្រាប់បត់ជើង ឬបង្គន់អនាម័យដែលមានបំពង់ខ្យល់ចេញ ចូលក្នុងរណ្តៅ។
- **ការទទួលបានបង្គន់អនាម័យដែលមានការកែលម្អ៖** គឺជាលទ្ធភាពទទួលបានបង្គន់អនាម័យដែលមានការកែលម្អតាមលំនៅដ្ឋាន។
- **អនាម័យផ្ទាល់ខ្លួនក្នុងការគ្រប់គ្រងទឹក៖** គឺសំដៅដល់ឥរិយាបទទាំងឡាយដែលទាក់ទងទៅនឹងការអនុវត្តអនាម័យក្នុងការស្តុក និងការប្រើប្រាស់ទឹកក្នុងផ្ទះ និងការអនុវត្តអនាម័យផ្សេងៗ។ អនាម័យផ្ទាល់ខ្លួនល្អគឺជាការអនុវត្តដ៏ល្អមួយដែលធ្វើឲ្យទឹកន្លែង និងការរស់នៅរបស់យើងស្អាតជានិច្ច ដើម្បីជួយបង្ការបាក់តេរី/មេរោគបង្កជំងឺផ្សេងៗ។
- **អនាម័យបរិស្ថាន៖** គឺជាបរិស្ថានដែលស្អាត ហើយមិនបង្កឲ្យមានជំងឺដែលពាក់ព័ន្ធទៅនឹងទឹក និងលាមក។
- **និរន្តរភាពសេវា៖** គឺជាសេវាទាំងឡាយណាដែលមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់ដំណើរការការថែទាំ ការជួសជុល និងមានការគិតគូទាំងផ្នែកបច្ចេកទេស សង្គម ស្ថាប័ន និងបរិស្ថាន ដើម្បីបន្តផ្តល់សេវាជាមូលដ្ឋានដែលអាចទទួលយកបានជាប្រចាំ។
- **តំបន់ជនបទ៖** គឺសំដៅដល់តំបន់ភូមិសាស្ត្ររដ្ឋបាលមួយដែលមានដង់ស៊ីតេប្រជាជនអតិបរមា ២០០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ មានបុរស ៥០% ឡើងធ្វើការក្នុងវិស័យកសិកម្ម និងមានប្រជាជនសរុប ២.០០០ នាក់ ក្នុងមួយឃុំ។

# បញ្ជីតារាង

តារាងទី ១៖ ការទទួលបានសេវាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ នៅតំបន់ទីប្រជុំជន និងតំបន់ជនបទ ....... 12
តារាងទី ២៖ គោលដៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ១ ....... 13
តារាងទី ៣៖ សូចនាករ លទ្ធផល និងគោលដៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ២ ....... 13
តារាងទី ៤៖ ឧទាហរណ៍ គ្រោះថ្នាក់ដែលអាចកើតមានចំពោះប្រភពទឹក និងវិធានការឆ្លើយតប ....... 35
តារាងទី ៥៖ ឧទាហរណ៍ គ្រោះថ្នាក់ដែលអាចកើតមានក្នុងពេលយក/ដងទឹក ដឹកជញ្ជូនទឹក និងវិធានការការពារ ....... 36
តារាងទី ៦៖ ឧទាហរណ៍ គ្រោះថ្នាក់ នៃការស្តុកទឹក និងវិធានការការពារ ....... 36
តារាងទី ៧៖ ឧទាហរណ៍ ការបន្សុទ្ធ និងការស្តុកទឹក និងវិធានការគ្រប់គ្រង ....... 37

# បញ្ជីរូបភាព

រូបភាពទី ១៖ ចំណុចសំខាន់ៗ ចំនួនបួន (០៤) ក្នុងដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ....... 16
រូបភាពទី ២៖ ជំហានទាំងប្រាំមួយ (០៦) នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ... 19
រូបភាពទី ៣៖ ផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតភូមិ ....... 27
រូបភាពទី ៤៖ ផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឃុំ ....... 28
រូបភាពទី ៥៖ ឧទាហរណ៍ គ្រោះថ្នាក់ដែលអាចកើតមានចំពោះប្រភពទឹក និងវិធានការឆ្លើយតប ....... 35

## ១. ស្ថានភាពបច្ចុប្បន្ន នៃការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ

ប្រទេសកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពដ៏ប្រសើរក្នុងការផ្គត់ផ្គង់ទឹក និងអនាម័យជនបទដែលមានការកែលម្អ គិតចាប់តាំងពីឆ្នាំ ១៩៩០ ហើយមកដល់ឆ្នាំ ២០១៥ ជិតពាក់កណ្តាល នៃប្រជាជនជនបទនៅពុំទាន់ទទួលបានសេវាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យកម្រិតមូលដ្ឋាននៅឡើយ។ លើសពីនេះ ក៏នៅមានគម្លាតដ៏ធំរវាងការទទួលបានសេវានេះ រវាងតំបន់ជនបទ និងតំបន់ទីប្រជុំជន និងរវាងប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលមានជីវភាពធូរធារ[1]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀត ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យដែលធ្វើឲ្យប្រជាជនគ្រប់រូបនៅសហគមន៍ជនបទត្រូវមានការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថាន ដែលមានអនាម័យប្រកបដោយនិរន្តរភាព ត្រឹមឆ្នាំ ២០២៥ ។

កង្វះហេដ្ឋារចនាសម្ព័ន្ធ សម្ភារ បរិក្ខាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ និងការអនុវត្តអនាម័យមិនគ្រប់គ្រាន់មានផលវិបាកអវិជ្ជមានជាច្រើន ជាពិសេស ប្រជាជនក្រីក្រនៅតំបន់ជនបទ។ ជំងឺចំនួនប្រាំមួយ (០៦) ក្នុងចំណោមជំងឺចំនួនដប់ (១០) ដែលបានរាយការណ៍នៅកម្ពុជា គឺបណ្តាលមកពីការផឹកទឹកមិនស្អាត។ បញ្ហាអនាម័យ និងអនាម័យខ្លួនប្រាណមិនល្អ អាចបណ្តាលឲ្យមានអត្រាមរណៈខ្ពស់ពោលគឺ ១០ ០០០ នាក់ រៀងរាល់ឆ្នាំ ភាគច្រើនក្នុងចំណោមនោះ គឺជាកុមារ[2]។ ការខាតបង់ផ្នែកសេដ្ឋកិច្ចដែលពាក់ព័ន្ធទៅនឹងបញ្ហាទាំងនេះត្រូវបានប៉ាន់ប្រមាណថា មានអត្រាជាង ៧% (នៃផលទុនក្នុងស្រុកសរុប GDP) របស់ប្រទេសកម្ពុជា ឬស្មើ ៣២ ដុល្លាក្នុងមនុស្សម្នាក់[3]។

អត្រាទទួលបានសេវាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យដែលមានការកែលម្អនៅតំបន់ទីប្រជុំជន និងតំបន់ជនបទមានក្នុងតារាងទី ១ ខាងក្រោម។

**តារាងទី ១៖ ការទទួលបានសេវាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ នៅតំបន់ទីប្រជុំជន និងតំបន់ជនបទ**

| បរិយាយ | ១៩៩០[4] | ២០១៥[5] | ២០២១/២០២២[6] |
|---|---|---|---|
| ការផ្គត់ផ្គង់ទឹកដែលមានការកែលម្អនៅតំបន់ជនបទ | ២០% | ៤៧% | ៨២,៧% |
| ការផ្គត់ផ្គង់ទឹកដែលមានការកែលម្អនៅតំបន់ទីប្រជុំជន | ៣២% | ៨១% | ៩៤% |
| បង្គន់អនាម័យដែលមានការកែលម្អនៅតំបន់ជនបទ | ០% | ៤៦% | ៨៣,៧% |
| បង្គន់អនាម័យដែលមានការកែលម្អនៅតំបន់ទីប្រជុំជន | ១៨% | ៧៩% | ៩៥% |

[1] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) ២០១២ ២០១៣ និង ២០១៤

[2] Cambodia Water Supply and Sanitation Sector Review, Royal Government of Cambodia and the World Bank (2012).

[3] Economic Impacts of Sanitation in Cambodia, WSP Research Report (2008).

[4] Progress on Drinking Water and Sanitation, 2014 Update. WHO and UNICEF (2014)

[5] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៤

[6] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ ២០២១/២០២២

ក្នុងឆ្នាំ ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទ។ គោលដៅ នៃផែនការយុទ្ធសាស្ត្រជាតិនេះមានលក្ខណៈសាមញ្ញ ប៉ុន្តែ វាហាក់ដូចជាពិបាកក្នុងការសម្រេចឲ្យបាន។ នៅឆ្នាំ ២០២៥ " ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព " ។ ក្របខ័ណ្ឌ នៃផែនការសកម្មភាពជាតិ សម្រាប់ការងារផ្គត់ផ្គង់ទឹក និងលើកកម្ពស់អនាម័យនៅតំបន់ជនបទ និងការងារការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ត្រូវបានអនុវត្តន៍ជាពីរដំណាក់កាល ដែលដំណាក់កាលទី ១ ពីឆ្នាំ ២០១៤-២០១៨ (ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទ) និងដំណាក់កាលទី ២ ពីឆ្នាំ ២០១៩-២០២៣ (ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ) ។

ក្របខ័ណ្ឌ នៃផែនការសកម្មភាពជាតិនេះបានកំណត់ទិសដៅដូចខាងក្រោម៖

**តារាងទី ២៖ គោលដៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ១**

| លទ្ធផលកម្រិតខ្ពស់ | ទិន្នន័យមូលដ្ឋាន (២០១៣) | ចំណុចដៅ ២០១៨ | គម្លាត[7] (ចំនួនប្រជាជន) | គម្លាត (ចំនួនគ្រួសារ) |
|---|---|---|---|---|
| ១. ការទទួលបានសេវាផ្គត់ផ្គង់ទឹកដែលមានការកែលម្អ | ៤៦,៦% | ៦០% | ២,០២ លាន | ៤៣៩.៤០០ |
| ២. ការប្រើប្រាស់បង្គន់អនាម័យដែលមានការកែលម្អ | ៤០,៩% | ៦០% | ២,៦៧ លាន | ៥៨០.៤០០ |
| ៣. ការលាងសំអាតដៃជាមួយនឹងសាប៊ូតាមពេលវេលាសំខាន់ៗ | ៤៦,៥%[8] | ៦០% | ២,០៣ លាន | ៤៤១.៩០០ |
| ៤. ការប្រើវិធីសាស្ត្របន្សុទ្ធទឹកផឹកតាមគ្រួសារសមស្រប | ៧០% | ៨០% | ១,៧៩ លាន | ៣៨៨.៧០០ |

**តារាងទី ៣៖ សូចនាករ លទ្ធផល និងគោលដៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ២**

| លទ្ធផលកម្រិតខ្ពស់ | ទិន្នន័យគោល ឆ្នាំ ២០១៧ (%) | ចំណុចដៅ ឆ្នាំ ២០២៣ (%) | គម្លាតដែលត្រូវបំពេញ (ប្រជាជន) | គម្លាតដែលត្រូវបំពេញ (គ្រួសារ/ខ្នងផ្ទះ) |
|---|---|---|---|---|
| ១. គ្រួសារនៅតំបន់ជនបទប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកជាមូលដ្ឋាន | ៥៨,៧ | ៩០ | ៣ ៥២៩ ៧៧១ | ៧៩៧ ៨៣៩ |

[7] គម្លាត" នៅក្នុងនេះ និងជួរបន្ទាប់ គឺជាភាពខុសគ្នារវាងទិន្នន័យដែលមានស្រាប់ (២០១៣) និងអ្វីដែលបានបញ្ជាក់នៅក្នុងគោលដៅផែនការសកម្មភាពឆ្នាំ ២០១៨ ។ តួលេខនេះសន្មត់ថា អត្រាកំណើនប្រជាជនជាប្រវត្តិសាស្ត្រនៅតែថេរ។
[8] យ៉ាងហោចណាស់ ៣ ដងក្នុងមួយថ្ងៃ ការស្ទង់មតិ KAP (2010)។

| លទ្ធផលកម្រិតខ្ពស់ | ទិន្នន័យគោល ឆ្នាំ ២០១៧ (%) | ចំណុចដៅ ឆ្នាំ ២០២៣ (%) | គម្លាតដែលត្រូវបំពេញ (ប្រជាជន) | គម្លាតដែលត្រូវបំពេញ (គ្រួសារ/ខ្នងផ្ទះ) |
|---|---|---|---|---|
| ២. គ្រួសារនៅតំបន់ជនបទប្រើប្រាស់សេវាផ្គត់ផ្គង់ទឹក ដែលមានការគ្រប់គ្រងប្រកបដោយសុវត្ថិភាព | ១៦ | ៣៣ | ២ ២៣០ ៩០០ | ៥០៤ ៥០០ |
| ៣. គ្រួសារនៅតំបន់ជនបទប្រើប្រាស់សេវាអនាម័យជាមូលដ្ឋាន | ៧១,២ | ៩០ | ២ ២៦៤ ៨៣៦ | ៥១១ ៩២៤ |
| ៤. គ្រួសារនៅតំបន់ជនបទប្រើប្រាស់សេវាអនាម័យដែលមានការគ្រប់គ្រងប្រកបដោយសុវត្ថិភាព | មិនមាន | ៣៥ | ៤ ៥៩៣ ០៩០ | ១ ០៤៤ ០០០ |
| ៥. គ្រួសារនៅតំបន់ជនបទមានកន្លែងលាងដៃដែលមានសាប៊ូ និងទឹក | ៧៧,១ | ៩០ | ១ ៦៩២ ៨៦០ | ៣៨៣ ០០០ |

ផែនការសកម្មភាពជាតិ និងចំណុចដៅឆ្នាំ ២០១៨ និង ២០២៣ បានរៀបចំឡើងដើម្បីពន្លឿនវឌ្ឍនភាពក្នុងវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ តាមរយៈការធ្វើសុខដុមនីយកម្ម ការយកចិត្តទុកដាក់លើប្រជាជនក្រីក្រ ការពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា និងការបង្កើនទុនវិនិយោគ។

គោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ គឺមានទំនាក់ទំនងជាមួយលទ្ធផលកម្រិតខ្ពស់ទី ៤ នៃផែនការសកម្មភាពជាតិដំណាក់កាលទី ១ (២០១៤-២០១៨) ដែលបានបង្ហាញក្នុងតារាងទី ២ ខាងលើ។ លទ្ធផលកម្រិតខ្ពស់ទី ៤ ស្តីពីការបង្កើនការប្រើប្រាស់វិធីសាស្រ្តបន្សុទ្ធទឹកផឹកតាមគ្រួសារសមស្របពី ៧០% ទៅ ៨០% ដែលបានកំណត់នេះ អាចសម្រេចបាន បើយោងតាមទិន្នន័យមូលដ្ឋាន ៧០% ឆ្នាំ ២០១៣។ ចំពោះសូចនាករលទ្ធផលទី ១ នៃផែនការសកម្មភាពជាតិដំណាក់កាលទី ២ (២០១៩-២០២៣) ក៏បានបង្ហាញថា គ្រួសារនៅតំបន់ជនបទនឹងប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកជាមូលដ្ឋានពី ៥៨.៧% ទៅ ៩០% ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាវាយតម្លៃគុណភាពទឹកមួយកែវចុងក្រោយនៅឆ្នាំ ២០១៣ ដោយអង្គការសុខភាពពិភពលោក បានរកឃើញថា មានតែ ២៣% នៃគ្រួសារនៅតាមតំបន់ជនបទមានទឹកផឹក “ដែលមានសុវត្ថិភាព” (ផ្អែកមីក្រូសាស្រ្ត Ecoli) ។ ក្នុងនោះមានតែគ្រួសារចំនួន ៣៥% ក្នុងចំណោមគ្រួសារដែលរាយការណ៍ថា បាន

បន្សុទ្ធទឹក មានទឹកផឹកដែលមានគុណភាពស្របតាមបទដ្ឋានកំណត់ក្នុងគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ[9]។

ផែនការសកម្មភាពជាតិ បានទទួលស្គាល់អំពីសារៈសំខាន់ នៃការបង្កើនការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ និងទឹកផឹកដែលមានសុវត្ថិភាព ដែលនឹងត្រូវជំរុញតាមរយៈការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុឲ្យបានចំនួន ១០០ ឃុំ ត្រឹមឆ្នាំ ២០១៨ និងចំនួន ៥០០ ឃុំ ត្រឹមឆ្នាំ ២០២៣។

ការដឹកនាំឆ្ពោះទៅរកការធានាឲ្យមានទឹកផឹក ដែលមានសុវត្ថិភាព គឺជាការភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG)៖ គោលដៅ ៦.១[10] « *នៅឆ្នាំ ២០៣០ សម្រេចបានជាសកលនូវសមភាព នៃការទទួលបានទឹកសុវត្ថិភាព និងអាចទទួលយកបានសម្រាប់ទាំងអស់គ្នា* »។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) បានគូសបញ្ជាក់អំពីសារៈសំខាន់ នៃការការពារគុណភាពទឹក ការកាត់បន្ថយការខ្វះខាតទឹក (លើកកម្ពស់ការប្រើប្រាស់ទឹកឡើងវិញ) ការអនុវត្តការគ្រប់គ្រងធនធានទឹកឲ្យប្រសើរជាងមុន និងសកម្មភាពផ្សេងៗទៀតដែលស្របជាមួយនឹងដំណើរការលើកកម្ពស់ក្នុងផែនការសុវត្ថិភាពទឹក[11]។

ឯកសារនេះ មានគោលបំណងផ្តល់នូវការណែនាំសំខាន់ៗក្នុងការរៀបចំផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនៅប្រទេសកម្ពុជា។ គោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះបានបង្កើត និងរៀបចំឡើងសម្រាប់មន្ទីរអភិវឌ្ឍន៍ជនបទ (PDRDs) រដ្ឋបាលថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ ដៃគូអភិវឌ្ឍន៍ (DPs) អង្គការ សង្គមស៊ីវិល និងស្ថាប័នសាធារណៈនៅតំបន់ជនបទប្រើប្រាស់។

# ២. ទិដ្ឋភាពទូទៅ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

## ២.១ សេចក្តីផ្តើម

វិធីសាស្ត្រគ្រប់គ្រងគ្រោះថ្នាក់គ្រប់ផ្នែកទាំងអស់ នៃការផ្គត់ផ្គង់ទឹក ចាប់ពី " **ប្រភពទឹក** " ទៅដល់ " **ទឹកប្រើប្រាស់ចុងក្រោយ** "។ ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះផ្តោតជាសំខាន់លើការធានាថា ទឹកផឹកនៅតាមគ្រួសារ សាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព វត្តអារាម និងកន្លែងសាធារណៈផ្សេងទៀតដែលមានសុវត្ថិភាពសម្រាប់សុខភាពមនុស្សឬទេ? គោលបំណងរួម នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺធានាថា៖

" មនុស្សគ្រប់រូបនៅតាមសហគមន៍ជនបទទទួលបានទឹកផឹកមានសុវត្ថិភាពគ្រប់ពេលវេលា និងគ្រប់ទីកន្លែង "

[9] National Microbial Assessment of Rural Household Point-of-Consumption Drinking Waters. MRD and WHO (2013).

[10] Goal 6: Ensure Availability and Sustainable Management of Water and Sanitation for All.

[11] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីគោលដៅ 6 SDGs សូមមើល https://sustainabledevelopment.un.org/sdg6.

មានចំណុចសំខាន់ៗចំនួនបួន (០៤) ក្នុងដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ៖




**រូបភាពទី ១៖ចំណុចសំខាន់ៗ ចំនួនបួន (០៤) ក្នុងដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ**

ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺជាវិធីសាស្ត្រផ្តល់នូវចំនុចសំខាន់ៗ និងជាមធ្យោបាយមួយដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងបញ្ហាគុណភាពទឹកនៅគ្រប់កម្រិត គឺចាប់ពីកម្រិតគ្រួសារទៅកម្រិតសហគមន៍ រហូតទៅដល់ប្រភពទឹក។ នៅក្នុងការអនុវត្តជាក់ស្តែង ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ជួយកំណត់បាននូវវិធានការដែលអនុវត្តន៍បានដោយបុគ្គលក្នុងគ្រួសារ ក្នុងភូមិ ក្នុងសាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព វត្តអារាម និងដោយរដ្ឋបាលមូលដ្ឋាន (ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ)។ ដូចបានបង្ហាញក្នុង **រូបភាពទី ១៖ចំណុចសំខាន់ៗ ចំនួនបួន (០៤)** ក្នុងដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុខាងលើ វិធានការទាំងនេះជួយការពារការបំពុលទឹកនៅក្នុងប្រភពទឹក ក្នុងអំឡុងពេលយកទឹកមកប្រើប្រាស់ (ឧទាហរណ៍ ការបូមទឹក ឬការយកទឹកចេញពីប្រភពទឹក) ក្នុងពេលដឹកជញ្ជូនទឹកទៅផ្ទះ (ឬទីតាំងផ្សេងៗ) ដោយប្រើប្រភេទធុងសម្រាប់ដាក់ទឹក ក្នុងពេលស្តុកទឹកនៅផ្ទះ និងនៅដំណាក់កាលប្រើប្រាស់ទឹកផឹក ដូចជា ដៃ កាទឹក កែវទឹក ត្រូវតែស្អាត។

ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺជាការចូលរួមធ្វើផែនការដែលឆ្លើយតបទៅនឹងស្ថានភាពមូលដ្ឋាន ហើយផ្តោតលើសកម្មភាពជាអាទិភាពខ្ពស់ដែលជួយកាត់បន្ថយ ឬការពារផលប៉ះពាល់ដល់សុខភាពដែលបណ្តាលមកពីទឹកមិនស្អាត ក៏ដូចគ្នានឹងបញ្ហាដទៃទៀតដែលទាក់ទងជាមួយអនាម័យ។ ដូច្នេះ ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនឹងបានចូលរួមចំណែកលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់សហគមន៍ សេដ្ឋកិច្ច សមធម៌ និងជួយកាត់បន្ថយភាពក្រីក្រ ជាពិសេស ប្រជាជនក្រីក្រ និងក្រុមងាយរងគ្រោះដែលតែងតែមិនបានទទួលសេវាផ្គត់ផ្គង់ទឹកដែលមានការកែលម្អ។

លើសពីនេះទៀត ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុក៏បានឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុផងដែរ។ ការប្រែប្រួលអាកាសធាតុអាចនឹងផ្លាស់ប្តូរពេលវេលា និងអាកាសធាតុដែលជាលទ្ធផល អាចប៉ះពាល់ដល់បរិមាណ នៃធនធានទឹក និងគុណភាពសេវាផ្គត់ផ្គង់ទឹក និងអនាម័យ។ ទោះបីជាមានការលំបាកក្នុងការព្យាករណ៍ឲ្យបានច្បាស់លាស់អំពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ប្រទេសកម្ពុជាត្រូវបានចាត់ចូលជាប្រទេសដែលងាយរងគ្រោះបំផុតផងដែរ។ ការកើនឡើងនៃកង្វះទឹកបណ្តាលមកពីគ្រោះរាំងស្ងួត ការធ្លាក់ចុះ នៃនីវ៉ូទឹកក្រោមដី និងទឹកជំនន់តាមរដូវ គឺជាបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាជាច្រើនទៀត ដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។ ការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវតែគិតថាតើត្រូវធ្វើដូចម្តេចដើម្បីធានាឱ្យមានភាពធន់ នៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

ការធ្វើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺត្រូវតែផ្តោតទៅលើគោលការណ៍ជាចំបងដែលថាទឹកផឹក គឺជាធនធានកម្រដែលត្រូវតែការពារ ត្រូវតែរក្សាឲ្យមានសុវត្ថិភាព និងប្រើប្រាស់ត្រឹមត្រូវដោយមិនខ្ជះខ្ជាយ។ ទឹកផឹកសុវត្ថិភាព មានសារៈសំខាន់ក្នុងការធានាបាននូវភាពប្រសើរឡើងនូវសុខភាពសាធារណៈ ពីព្រោះ ជំងឺឆ្លងដោយសារបញ្ហាទឹក និងអនាម័យ គឺជាបញ្ហាចំបងមួយ (០១) ក្នុងចំណោមបញ្ហាផ្សេងៗទៀតដែលបណ្តាលឲ្យមានអត្រាស្លាប់ច្រើននៅប្រទេសកម្ពុជា ជាពិសេស កុមារ។

ដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺសាមញ្ញ ប៉ុន្តែ មានបញ្ហា និងការប្រឈមច្រើន។ ជំហាននីមួយៗ ក៏ដូចគ្នានឹងសកម្មភាពដែលមាន គឺអាចអនុវត្តន៍បានដោយមន្ទីរអភិវឌ្ឍន៍ជនបទ ក្រុមប្រឹក្សាឃុំ ថ្នាក់ដឹកនាំភូមិ និងជនបង្គោលភូមិ។ សូមចងចាំថា ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺមិនមែនជាដំណើរការទាំងឡាយ ឬដំណើរការមួយ ឬជាលំហាត់ដែលសម្រេចបាន ឬមិនបាននោះទេ។ រាល់សកម្មភាពដែលឃុំ ឬភូមិបានធ្វើ គឺជាជំហានឈានទៅរកការកែលម្អសុវត្ថិភាពទឹក។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុអាចនឹងជួបបញ្ហា និងការប្រឈមជាច្រើន ៖

ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ មិនមែនជា " វត្ថុ " ប៉ុន្តែ ជា " ដំណើរការ " ដែលតម្រូវឲ្យមានការគាំទ្រ និងការត្រួតពិនិត្យ តាមដានជាប្រចាំដោយថ្នាក់ដឹកនាំគ្រប់កម្រិត ( ឧទាហរណ៍ មេភូមិ អាជ្ញាធរឃុំ និងអ្នកពាក់ព័ន្ធផ្សេងៗ ) ។

ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុមានជំហានជាបន្តបន្ទាប់ដែលត្រូវតែអនុវត្តន៍ និងត្រូវតែពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធ្វើបច្ចុប្បន្នភាព និងបន្តកែលម្អគ្រប់ពេលវេលា។

យោងទៅតាមហេតុផលនេះ ដើម្បីសម្រេចជោគជ័យក្នុងការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺតម្រូវឲ្យមាន៖

- ការខិតខំប្រឹងប្រែង ជាមួយនឹងប្រសិទ្ធិភាព នៃការដឹកនាំពីថ្នាក់ឃុំ និងភូមិ
- ការគាំទ្រដោយមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទ និងការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ឆន្ទៈបុគ្គល ក៏ដូចជាគ្រួសារ ក្នុងការអនុវត្តផែនការ និងផ្លាស់ប្តូរឥរិយាបទនៅក្នុងសហគមន៍
- ថវិកា និងធនធានផ្សេងៗ ដើម្បីអនុវត្តន៍សកម្មភាពកែលម្អ។

## ២.២ លទ្ធផលផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

វាមានលទ្ធផលសំខាន់ៗចំនួនប្រាំ (០៥) ដែលនឹងបានមកពីការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ៖

- ការការពារប្រភពទឹក ៖ ប្រភពទឹកកែលម្អរបស់សហគមន៍មានបរិមាណគ្រប់គ្រាន់ស្របនឹងតម្រូវការ និងត្រូវបានការពារពីការបំពុលផ្សេងៗ ពីសារធាតុពុលគីមី និងមីក្រូជីវសាស្ត្រ។
- ការប្រើប្រាស់ទឹកឲ្យបានត្រឹមត្រូវ៖ ការដងទឹក ការស្តុកទឹក និងការប្រើប្រាស់ទឹកផឹកមិនបណ្តាលឲ្យមានការចម្លងបាក់តេរី/មេរោគឡើងវិញ។
- ទឹកផឹកចុងក្រោយត្រូវតែមានសុវត្ថិភាព៖ គុណភាពទឹកផឹកចុងក្រោយ ស្របតាមកម្រិតកំណត់ក្នុងគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ (ដោយការប្រើប្រាស់បច្ចេកទេសបន្សុទ្ធទឹកផឹកសមស្រប)

- បរិស្ថានសហគមន៍ស្អាត៖ បរិស្ថានស្អាតជាប្រចាំ (សំណល់រាវ និងរឹងត្រូវតែគ្រប់គ្រងប្រកបដោយអនាម័យ)។ នេះរួមបញ្ចូលទាំងការបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល និងសកម្មភាពផ្សេងៗទៀតដែលចាំបាច់ ដើម្បីធានាបានបរិស្ថានរស់នៅស្អាត និងមានអនាម័យល្អ។
- ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ៖ សំណង់ប្រភពធនធានទឹកសហគមន៍ត្រូវបានសាងសង់ និងគ្រប់គ្រងត្រឹមត្រូវ ដែលមានភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

ការរីកចម្រើនឈានទៅរកការសម្រេចបាននូវលទ្ធផលទាំងនេះ គួរតែត្រូវបានកត់ត្រា ផ្ទៀងផ្ទាត់ និងទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ការចង់បាន " ចុងក្រោយ " គឺ ភូមិក្លាយជា " ភូមិទឹកសុវត្ថិភាព " ។ នៅថ្នាក់ឃុំ គោលបំណងសំខាន់ គឺភូមិទាំងអស់ត្រូវទទួលបាននូវ " ភូមិទឹកសុវត្ថិភាព " ហើយក្លាយជា " ឃុំទឹកសុវត្ថិភាព " ។

## ៣. ផែនការសុវត្ថិភាពទឹកជនបទធន់ដែលនឹងអាកាសធាតុ

ជំហានទាំងប្រាំមួយ (០៦) គឺជាជំហានមូលដ្ឋានសម្រាប់អនុវត្តន៍ផែនការសុវត្ថិភាពទឹកជនបទ។ ទោះបីជាយ៉ាងណាក៏ដោយ វាចាំបាច់ត្រូវតែគិតអំពីដំណើរការជាបន្តបន្ទាប់ដែលបានកំណត់ក្នុងជំហានទាំងអស់ ហើយដែលនឹងត្រូវធ្វើបន្តនាពេលអនាគត។ តម្រូវការទឹកស្អាត និងបរិស្ថានស្អាត គឺមិនអាចសម្រេចបានក្នុងពេលតែមួយនោះទេ ហើយក៏គ្មានករណីណាដែលថា វានឹងមាននិរន្តរភាពហួតដោយមិនមានការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងជាបន្តបន្ទាប់បានឡើយ។ ដូច្នេះ **ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ** គឺជាវដ្ត នៃជំហានទាំងប្រាំមួយ រួមមាន ជំហានទី ១ ៖ ការចូលរួមរបស់សហគមន៍ និងការបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ជំហានទី ២ ៖ ដែលផ្តោតទៅលើចំនុច ២ សំខាន់ៗ គឺ ការគូសផែនទីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដែលសិក្សាពីធនធានទឹក រួមបញ្ចូលទំហំបរិមាណធនធានទឹក និងឱកាសសម្រាប់ប្រភពទឹកបន្ថែមទៀត ជំហានទី ៣ ៖ ការកំណត់ និងការវាយតម្លៃគ្រោះថ្នាក់ និងវិធានការការពារ រួមបញ្ចូលហានិភ័យបង្កឡើងដោយអាកាសធាតុ ដែលផ្តោតទៅលើចំនុច ៣ សំខាន់ៗ គឺ **១.** កំណត់មុខសញ្ញាគ្រោះថ្នាក់ និងការធ្វើតេស្តគុណភាពទឹក **២.** ការវាយតម្លៃគ្រោះថ្នាក់បង្កដោយអាកាសធាតុ និងបរិស្ថាន និងផលប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងប្រភពទឹក និងការវាយតម្លៃអំពីគ្រោះថ្នាក់ និងវិធានការត្រួតពិនិត្យ តាមដាន ជំហានទី ៤ ៖ ការរៀបចំ និងការអនុវត្តផែនការកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលធន់នឹងអាកាសធាតុ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ជំហានទី ៥ ៖ ការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាព និងការទំនាក់ទំនង នៃលទ្ធផល និងជំហានទី ៦ ៖ ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព នៃផែនការកែលម្អ (**រូបភាពទី ២**)។




**រូបភាពទី ២៖ជំហានទាំងប្រាំមួយ (០៦) នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ**

## ៣.១ ជំហានទី ១៖ ការចូលរួមរបស់សហគមន៍ និងការបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

### ៣.១.១ ថ្នាក់ឃុំ

ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គួរតែអនុវត្តន៍នៅកម្រិតថ្នាក់ឃុំ ដែលជាកម្រិត នៃរដ្ឋបាលមូលដ្ឋាននៅជិតនឹងភូមិបំផុត។ ក្រុមប្រឹក្សាឃុំ មានសិទ្ធិអំណាចក្នុងការវិនិយោគធនធានរបស់ខ្លួន (ឃុំ និងភូមិ) លើហេដ្ឋារចនាសម្ព័ន្ធ និងការងារអភិវឌ្ឍន៍ផ្សេងៗទៀតដែលជាផ្នែកមួយ នៃផែនការវិនិយោគរបស់ឃុំ (CIP) ។

ក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និងក្រុមប្រឹក្សាឃុំទទួលបន្ទុកការងារទឹកស្អាត ការសំអាត និងអនាម័យ អាចទទួលបានការគាំទ្រការពង្រឹងសមត្ថភាព និងដំណើរការរៀបចំផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ពីការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ នៃរដ្ឋបាលស្រុក និងមន្ទីរអភិវឌ្ឍន៍ជនបទ។

ការចាប់ផ្តើមរៀបចំផែនការសុវត្ថិភាពទឹកឃុំ គួរតែធ្វើឡើងតាមរយៈកិច្ចប្រជុំតម្រង់ទិស និងធ្វើផែនការនៅថ្នាក់ឃុំ រយៈពេលមួយថ្ងៃ ដឹកនាំដោយមេឃុំ និងមានការគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទ។ ក្នុងពេលប្រជុំតម្រង់ទិសនេះ ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ គួរតែត្រូវបានបង្កើតឡើង។ ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំគួរតែមានសមាសភាពដូចខាងក្រោម៖

- មេឃុំ (ឬជំទប់ទី ១ ជាជម្រើសបន្ទាប់)
- ក្រុមប្រឹក្សាឃុំ ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ
- ក្រុមប្រឹក្សាឃុំ ទទួលបន្ទុកការងារ ទឹក ការសំអាត និងអនាម័យ
- មេភូមិទាំងអស់នៅក្នុងឃុំ
- ប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព
- តំណាងនាយក នាយិកាសាលាបឋមសិក្សាទាំងអស់ក្នុងឃុំ (០១ នាក់)
- អ្នកដឹកនាំសាសនា(០១ ឬច្រើននាក់)
- អ្នកគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសហគមន៍
- តំណាងវិស័យឯកជនដែលផ្តល់សេវាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ និងអ្នកពាក់ព័ន្ធផ្សេងទៀត

ចំនួនសមាជិកក្រុមការងារថ្នាក់ឃុំ អាចប្រែប្រួលពីឃុំមួយទៅឃុំមួយ ប៉ុន្តែ ជាធម្មតាចាប់ពី ០៩ នាក់ ឡើងទៅ។ ឈ្មោះ មុខងារ និងព័ត៌មានទំនាក់ទំនងរបស់សមាជិកនីមួយៗត្រូវតែកត់ត្រា និងចែកដល់សមាជិកទាំងអស់។ កំណត់ត្រាក្រុមការងារផែនការសុវត្ថិភាពទឹកឃុំត្រូវតែរក្សាទុកនៅសាលាឃុំ។

ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ គួរតែដឹកនាំដោយមេឃុំជាមួយនឹងជំទប់ទី ១ ។ អនុប្រធានក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ និងសមាជិកផ្សេងៗទៀត គួរតែត្រូវបានបោះឆ្នោតជ្រើសរើសជាមួយនឹងការណែនាំពីមន្ទីរអភិវឌ្ឍន៍ជនបទ។ សមាជិកទាំងនេះគួរតែជ្រើសរើសបាននៅចុងបញ្ចប់ នៃកិច្ចប្រជុំ។ ជម្រើសល្អសម្រាប់អនុប្រធានក្រុមការងារ និងសមាជិកផ្សេងៗទៀត គួរតែជាបុគ្គលដែលបង្ហាញអំពីការយល់ដឹងល្អ និងការចាប់អារម្មណ៍លើការងារនេះក្នុងពេលកិច្ចប្រជុំ។ ជម្រើសផ្សេងៗទៀតអាចជា សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នាយក នាយិកាសាលាបឋមសិក្សា ប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព មេភូមិដែលមានទឹកចិត្តខ្ពស់។

សមាជិកផ្សេងៗទៀតអាចបង្កើតឡើង និងជ្រើសរើសដោយក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ ដូចជា មន្ត្រីហិរញ្ញិក លេខា អ្នកសម្របសម្រួលការងារត្រួតពិនិត្យ តាមដាន និងរាយការណ៍ មន្ត្រីបច្ចេកទេស អ្នកសម្របសម្រួលការងារកៀរគរប្រភពធនធានជាដើម។ ក្រុមការងារនេះ គួរតែមានតុល្យភាពយេនឌ័រផងដែរ ។

នៅចុងបញ្ចប់ នៃកិច្ចប្រជុំតម្រង់ទិស ស្តីពីរៀបចំផែនការសុវត្ថិភាពទឹកឃុំ មេឃុំ សមាជិកក្រុម និងអ្នកចូលរួមទាំងអស់គួរតែ៖

- យល់ដឹងអំពីសារៈសំខាន់ នៃទឹកផឹកសុវត្ថិភាព និងតួនាទីរបស់ឃុំ និងភូមិក្នុងការធ្វើឲ្យមានបរិស្ថានស្អាត ដើម្បីលើកកម្ពស់សុខភាព សុវត្ថិភាព សុខុមាលភាពសេដ្ឋកិច្ច ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។
- យល់ដឹងអំពីគោលបំណងជាក់លាក់ ជំហានសំខាន់ៗ និងកម្រិតរីកចម្រើនដែលនឹងទទួលបានការទទួលស្គាល់ ក្នុងដំណើរការផែនការសុវត្ថិភាពទឹកឃុំ។
- បង្កើតបានក្រុមការងាររៀបចំផែនការសុវត្ថិភាពទឹកឃុំ។
- មានគំនិតជាមូលដ្ឋានដើម្បីរៀបចំ និងគាំទ្រដំណើរការរៀបចំផែនការសុវត្ថិភាពទឹកឃុំ។

- មានការព្រមព្រៀងគ្នាលើកាលវិភាគសម្រាប់កិច្ចប្រជុំទៀងទាត់ ដើម្បីត្រួតពិនិត្យ តាមដានដំណើរការផែនការសុវត្ថិភាពទឹកឃុំ។
- មានការព្រមព្រៀងគ្នាអំពីពេលវេលាចាប់ផ្តើមដំណើរការផែនការសុវត្ថិភាពទឹកឃុំ ព្រមទាំងឈ្មោះរបស់ក្រុមប្រឹក្សាឃុំ និងមន្ត្រីការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទដែលនឹងចូលរួមគាំទ្រ។
- មានឯកសារណែនាំដែលទាក់ទងទៅនឹងការរៀបចំផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងសម្ភារអប់រំ ផ្សព្វផ្សាយផ្សេងៗ។
- មានបញ្ជីឈ្មោះ តួនាទី និងព័ត៌មានសម្រាប់ទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាឃុំ ក៏ដូចជាមន្ត្រីមន្ទីរដែលទទួលបន្ទុកគាំទ្ររៀបចំផែនការសុវត្ថិភាពទឹកឃុំ។

❖ **តួនាទីក្រុមផែនការសុវត្ថិភាពទឹកឃុំ**

- បំពេញតារាងក្រុមការងារផែនការសុវត្ថិភាពទឹក។
- គូសផែនទីឃុំ បង្ហាញអំពីប្រភពទឹក និងស្វែងយល់អំពីព័ត៌មានផ្សេងៗដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទឹក រួមទាំងបញ្ហាដែលទាក់ទងទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។
- កំណត់មុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមានដល់ទឹក ចាប់ពីប្រភពទឹករហូតដល់ទឹកផឹក រួមបញ្ចូលបញ្ហាដែលអាចកើតឡើងដោយសារគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។
- ធ្វើផែនការកំណត់អាទិភាព និងដឹកនាំសកម្មភាពកែលម្អគ្រប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងសហគមន៍។
- ធ្វើផែនការ និងដឹកនាំសកម្មភាពលើកកម្ពស់ការយល់ដឹងតាមភូមិដល់គ្រួសារអំពីការអនុវត្តត្រឹមត្រូវក្នុងការរក្សាទឹកប្រើប្រាស់ឲ្យមានសុវត្ថិភាព។
- ធ្វើផែនការ និងដឹកនាំការតាមដានវឌ្ឍនភាព នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ រួមមាន ការត្រួតពិនិត្យ ការតាមដានគុណភាពទឹកក្នុងសហគមន៍ និងតាមគ្រួសារ និងចែករំលែកព័ត៌មាន។
- រៀបចំ និងលើកផែនការសម្រាប់មន្ទីរអភិវឌ្ឍន៍ជនបទ ឬអាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធ ចុះតាមភូមិដើម្បីជួយពិនិត្យថាតើការអនុវត្តផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុ បានត្រឹមត្រូវ និងមានប្រសិទ្ធភាពឬទេ?
- ប្រជុំពិនិត្យឡើងវិញលើវឌ្ឍនភាពសកម្មភាពផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងពិភាក្សាគ្នាថាតើការអនុវត្តបានតាមផែនការកំណត់ឬទេ? ធ្វើបច្ចុប្បន្នភាព ឬកែសម្រួល (ប្រសិនបើចាំបាច់) ដើម្បីជួយឲ្យប្រសើរឡើងនូវការអនុវត្ត ហើយអាចសម្រេចបានតាមគោលដៅកំណត់។
- រៀបចំផែនការថវិកា ធ្វើការកៀរគរ ឬស្នើសុំវិភាជន៍ថវិកា (ឃុំ ស្រុក និងខេត្ត) សម្រាប់ការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ។

### ៣.១.២ ថ្នាក់ភូមិ

ភូមិនីមួយៗនៅក្នុងឃុំ នឹងអនុវត្តន៍ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដោយខ្លួនឯងដែលជាផ្នែកមួយ នៃផែនការសុវត្ថិភាពទឹករបស់ឃុំទាំងមូល។

ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ គួរតែចាប់ផ្តើមផែនការសុវត្ថិភាពទឹកថ្នាក់ភូមិនៅកន្លែងដែលសហគមន៍អាចសម្រេចលទ្ធផលលឿន ដើម្បីបង្កើនទំនុកចិត្ត និងបង្ហាញគំរូល្អដល់ភូមិផ្សេងទៀត ជាពិសេស គេអាចរៀនសូត្រពីគ្នាបាន។

ដូចគ្នានឹងថ្នាក់ឃុំដែរ ផែនការសុវត្ថិភាពទឹកភូមិគួរតែចាប់ផ្តើមពីកិច្ចប្រជុំតម្រង់ទិស និងធ្វើផែនការរយៈពេល ០១ ថ្ងៃ។ កិច្ចប្រជុំនេះត្រូវតែចូលរួមដោយមេភូមិ បុគ្គលដែលមានឥទ្ធិពលក្នុងភូមិ និងសហគមន៍ដែលជាព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងអំពីការចាប់ផ្តើមដំណើរការផែនការសុវត្ថិភាពទឹកភូមិ។ កិច្ចប្រជុំនេះគួរតែរៀបចំដឹកនាំដោយមេភូមិ។ មន្ត្រីមកពីខាងក្រៅ (អាចជាឃុំ/ស្រុក/ឬខេត្ត) គួរតែចូលរួមបើកកិច្ចប្រជុំ និងការផ្តល់ព័ត៌មានពីក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ និងមូលហេតុ នៃកិច្ចប្រជុំនាថ្ងៃនេះ។

តំណាងឃុំ (ប្រធានក្រុមការងារផែនការសុវត្ថិភាពទឹក) (មេឃុំ ឬក្រុមប្រឹក្សាឃុំ ទទួលបន្ទុកការងារទឹក ការសំអាត និងអនាម័យ) គួរតែដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំផែនការសុវត្ថិភាពទឹកភូមិ។

គោលបំណង នៃកិច្ចប្រជុំ គឺដើម្បីជូនដំណឹងដល់សហគមន៍អំពីដំណើរការផែនការសុវត្ថិភាពទឹកឃុំ និងការរៀបចំផែនការសុវត្ថិភាពទឹកភូមិ។ ពេលបញ្ចប់កិច្ចប្រជុំ អ្នកចូលរួមនឹង៖

- យល់ដឹងអំពីសារៈសំខាន់ នៃទឹកផឹកសុវត្ថិភាព និងតួនាទីរបស់ភូមិក្នុងការធ្វើឲ្យមានបរិស្ថានស្អាត ដើម្បីលើកកម្ពស់សុខភាព សុវត្ថិភាព សុខុមាលភាពសេដ្ឋកិច្ច ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ។
- យល់ដឹងអំពីគោលបំណងជាក់លាក់ ជំហានសំខាន់ៗ និង "កម្រិតរីកចម្រើនដែលនឹងទទួលបានការទទួលស្គាល់" ក្នុងដំណើរការផែនការសុវត្ថិភាពទឹកភូមិ។
- បង្កើតបានក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ។
- មានគំនិតជាមូលដ្ឋានដើម្បីរៀបចំ និងគាំទ្រដំណើរការផែនការសុវត្ថិភាពទឹកភូមិ។
- មានការព្រមព្រៀងគ្នាលើកាលវិភាគសម្រាប់កិច្ចប្រជុំទៀងទាត់ ដើម្បីត្រួតពិនិត្យ តាមដានដំណើរការផែនការសុវត្ថិភាពទឹកភូមិ។
- មានការព្រមព្រៀងគ្នាអំពីពេលវេលាចាប់ផ្តើមដំណើរការផែនការសុវត្ថិភាពទឹកភូមិដែលអាចឈានទៅសម្រេចបានយ៉ាងហោចណាស់ ០៣ ជំហានដំបូង។
- មានឯកសារណែនាំ ដែលទាក់ទងទៅនឹងផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងសម្ភារអប់រំ ផ្សព្វផ្សាយផ្សេងៗ។
- មានបញ្ជីឈ្មោះ តួនាទី និងព័ត៌មានសម្រាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ និងអ្នកសំខាន់ៗផ្សេងៗទៀតក្នុងការជួយគាំទ្រដំណើរការផែនការសុវត្ថិភាពទឹកភូមិ។

សមាសភាពក្រុមការងារផែនការសុវត្ថិភាពទឹកភូមិអាចសម្រេចដោយមេភូមិ និងភាគីពាក់ព័ន្ធផ្សេងទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិគួរតែមានសមាសភាពដូចខាងក្រោម៖

- មេភូមិ (អនុភូមិ ជាជម្រើសបន្ទាប់)
- បុគ្គលិកមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព ឬភ្នាក់ងារសុខភាពភូមិ (ប្រសិនបើ មាននៅក្នុងភូមិ)
- នាយក នាយិកាសាលាបឋមសិក្សា (ប្រសិនបើ មាននៅក្នុងភូមិ)
- មេដឹកនាំសាសនានៅក្នុងភូមិ
- សមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (ប្រសិនបើ មាន)
- សមាជិកក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ (ប្រសិនបើ មាន)
- អ្នកគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសហគមន៍ (ឯកជន)
- ប្រជាពលរដ្ឋដែលចាប់អារម្មណ៍ និងមានឆន្ទៈចូលរួម។

ប្រសិនបើ មានគណៈកម្មាធិការ ឬក្រុមការងារទទួលបន្ទុកគ្រប់គ្រងទឹកសហគមន៍ក្នុងភូមិរួចហើយ គណៈកម្មាធិការនេះ អាចជាក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ ប៉ុន្តែ សមាជិកអាចពង្រីកបន្ថែមដោយការបញ្ចូលបុគ្គលដូចដែលបានរៀបរាប់ខាងលើ។ ការប្រើប្រាស់គណៈកម្មាធិការដែលមានស្រាប់អាចជួយពន្លឿនការអនុវត្តផែនការសុវត្ថិភាពទឹកភូមិ ដោយគ្រាន់តែបញ្ចូលបន្ថែមការទទួលខុសត្រូវដែលពាក់ព័ន្ធទៅនឹងផែនការសុវត្ថិភាពទឹកភូមិប៉ុណ្ណោះ។

ប្រសិនបើ មានពេល ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិអាចធ្វើទស្សនកិច្ចសិក្សាក្នុងភូមិណាមួយនៅក្បែរ ឬភូមិដែលបានចាប់ផ្តើមផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុរួចហើយ ជាមួយនឹងការរីកចម្រើនល្អ ដែលជាឱកាស ដើម្បីរៀនសូត្រពីបទពិសោធន៍ និងវិធីសាស្ត្រដែលបានអនុវត្តន៍រួចហើយ។

គំនិត និងអនុសាសន៍បន្ថែមមួយចំនួនទៀតសម្រាប់ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ៖

- អ្នកដឹកនាំក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ ត្រូវតែមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការបំពេញតួនាទីរបស់គាត់ (នេះជាមូលហេតុដែលមេភូមិ គឺជាជម្រើសដ៏ល្អក្នុងការធ្វើជាប្រធានក្រុម)។
- ឈ្មោះសមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ តួនាទី និងការទទួលខុសត្រូវ ត្រូវតែផ្សព្វផ្សាយឲ្យដឹងក្នុងក្រុម និងក្នុងសហគមន៍ទាំងមូល។
- តុល្យភាពយេនឌ័រនៅក្នុងក្រុម និងការយកចិត្តទុកដាក់ដល់ការស្វែងរកសមាជិកជាស្ត្រីដែលមានសមត្ថភាពជាចំនុចសំខាន់ ពីព្រោះ ស្ត្រីមានភារកិច្ចក្នុងការយកទឹកមកប្រើប្រាស់ក្នុងគ្រួសារ ការរៀបចំម្ហូបអាហារ ថែទាំសុខភាពគ្រួសារ និងកូនៗ។
- ប្រើប្រាស់ព្រឹត្តិការណ៍សំខាន់ៗដែលទាក់ទងទៅនឹងកម្មវិធីទឹក ការសំអាត និងអនាម័យ ដូចជាទិវាទឹកពិភពលោក (ថ្ងៃទី ២២ ខែមីនា) ដើម្បីលើកកម្ពស់ការយល់ដឹង និងការចាប់អារម្មណ៍ពីទឹកសុវត្ថិភាព និងដើម្បីចលនាធនធានដែលចាំបាច់សម្រាប់ធ្វើការកែលម្អ។
- បង្កើតភាពជាដៃគូជាមួយសហគមន៍ជិតខាង ដើម្បីផ្លាស់ប្តូរចំណេះដឹង ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងបញ្ហាដែលពាក់ព័ន្ធទៅនឹងទឹក ការសំអាត និងអនាម័យ ។ ទាំងនេះអាចមានប្រយោជន៍ ជាពិសេស នៅពេលភូមិមួយកំពុងចាប់ផ្តើមអនុវត្តន៍ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ (ឧទាហរណ៍ “ ភូមិថ្មី ” អាចប្រៀបធៀបជាមួយសហគមន៍ដែលមានបទពិសោធន៍រួចហើយពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ)។

### ៣.១.៣ តួនាទី និងការទទួលខុសត្រូវ

ដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ តម្រូវឱ្យមានការគាំទ្រ និងការចូលរួមរបស់អង្គការ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន។

តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធមានដូចខាងក្រោម៖

❖ **នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ**

- បង្កើត រៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំ ស្ដីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ
- ផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ទីរអភិវឌ្ឍន៍ជនបទ និងអ្នកពាក់ព័ន្ធ
- អនុវត្តន៍កម្មវិធីធ្វើតេស្តគុណភាពទឹកតាមគោលការណ៍ណែនាំ ស្ដីពីគុណភាពទឹកផឹកជនបទ
- ផ្ដល់ការទទួលស្គាល់លទ្ធផលពីមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពទឹកដែលបានចុះកិច្ចព្រមព្រៀងជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ
- អនុវត្តន៍កម្មវិធីត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពទឹកផឹកតាមគោលការណ៍ណែនាំ ស្ដីពីគុណភាពទឹកផឹកជនបទ រៀងរាល់ ៣ ខែម្ដង
- តាមដាន និងឆ្លើយតបរាល់បញ្ហាដែលកើតមានឡើងដោយសារការប្រើប្រាស់ទឹកនៅតំបន់ជនបទ
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យគុណភាពទឹកផឹកជនបទនៅទូទាំងប្រទេស
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងរៀងរាល់ ៣ ខែម្ដង

❖ **មន្ទីរអភិវឌ្ឍន៍ជនបទ**

- សហការជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទដើម្បីផ្សព្វផ្សាយគោលការណ៍ណែនាំ ស្ដីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដល់គ្រប់ភាគីពាក់ព័ន្ធនានា
- ណែនាំ និងសហការជាមួយគ្រប់ភាគីពាក់ព័ន្ធដើម្បីប្រមូល និងបញ្ជូនលទ្ធផល និងសំណាកទឹកមកមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពទឹករបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ
- អនុវត្តន៍កម្មវិធីត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពទឹកផឹកតាមគោលការណ៍ណែនាំ ស្ដីពីគុណភាពទឹកផឹកជនបទ រៀងរាល់ ១ ខែម្ដង
- តាមដាន និងឆ្លើយតបរាល់បញ្ហាដែលកើតមានឡើងដោយសារការប្រើប្រាស់ទឹកនៅតំបន់ជនបទ
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យគុណភាពទឹកផឹកជនបទនៅក្នុងរាជធានី-ខេត្ត
- ធ្វើរបាយការណ៍ជូននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទរៀងរាល់ ៣ ខែម្ដង

❖ **ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល**

- សហការ និងគាំទ្រ បង្កើត រៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំ ស្ដីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ
- ជួយកសាងសមត្ថភាព និងគាំទ្រធនធានសម្រាប់ដំណើរការការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពទឹករបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ

- សហការ និងគាំទ្រការផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ
- សហការ និងជំរុញដល់ភាគីពាក់ព័ន្ធឱ្យអនុវត្តន៍ធ្វើតេស្តគុណភាពទឹកតាមគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ
- សហការ និងផ្តល់ព័ត៌មានអំពីហានិភ័យ នៃប្រភពទឹក និងការប្រើប្រាស់ទឹក

❖ **វិស័យឯកជន**

- សហការ និងគាំទ្រគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ
- សហការ និងអនុវត្តន៍ការធ្វើតេស្តគុណភាពទឹក តាមគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ
- សហការ និងផ្តល់ព័ត៌មានអំពីហានិភ័យ នៃការប្រើប្រាស់ទឹក
- សហការ ជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់
- សហការ និងគាំទ្រការផ្សព្វផ្សាយ និងអនុវត្តន៍គោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដល់គ្រប់ភាគីពាក់ព័ន្ធនានា
- តាមដាន និងផ្តល់ព័ត៌មានអំពីហានិភ័យ នៃការប្រើប្រាស់ទឹក
- សហការ និងធ្វើរបាយការណ៍ជូនមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ឬភាគីពាក់ព័ន្ធនានា។

❖ **រដ្ឋបាលស្រុក**

- សហការ ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទ អាជ្ញាធរឃុំ និងភាគីពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដល់គ្រប់ភាគីពាក់ព័ន្ធនានា
- ចូលរួម អនុវត្តន៍កម្មវិធីត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពទឹកផឹកតាមគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ រៀងរាល់ ១ ខែម្តង
- ចូលរួមតាមដាន និងឆ្លើយតបរាល់បញ្ហាដែលកើតមានឡើងដោយសារការប្រើប្រាស់ទឹកនៅតំបន់ជនបទ
- ចូលរួមប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យគុណភាពទឹកផឹកជនបទនៅក្នុងរាជធានី-ខេត្ត
- ផ្តល់របាយការណ៍ជូនក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យស្រុក និងខេត្ត

❖ **រដ្ឋបាលឃុំ**

- ដឹកនាំ គាំទ្រ រៀបចំ និងអនុវត្តន៍ ផែនការសុវត្ថិភាពទឹកឃុំ ដោយមានសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ
- វិភាគជន៍ថវិកាឃុំ សម្រាប់ធ្វើការអនុវត្តផែនការសុវត្ថិភាពទឹកឃុំ
- តាមដានការអនុវត្តផែនការសុវត្ថិភាពទឹកនៅតាមភូមិ
- ផ្តល់របាយការណ៍ជូនក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យក្នុងឃុំ និងស្រុក

❖ **ភូមិ**

- ដឹកនាំ គាំទ្រ រៀបចំ និងអនុវត្តន៍ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដោយមានការសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ
- ធ្វើការស្នើសុំថវិកាសម្រាប់ការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

- ផ្ញើរបាយការណ៍ជូនឃុំ
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តរបស់សហគមន៍លើការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ
- ពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យនៅក្នុងសហគមន៍

## ៣.២ ជំហានទី ២៖ ការគូសផែនទី និងការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

### ៣.២.១ ការគូសផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

ការគូសផែនទីផ្គត់ផ្គង់ទឹក គឺជាកត្តាសំខាន់ក្នុងការបង្កើនការយល់ដឹងអំពីស្ថានភាពសុវត្ថិភាពទឹកជនបទក្នុងសហគមន៍ដែលទាក់ទងទៅនឹងទឹកប្រើប្រាស់ក្នុងមូលដ្ឋានទាំងមូល។ ផែនទីផ្គត់ផ្គង់ទឹក ក៏អាចជួយសមាជិក និងក្រុមការងារភូមិ ឬឃុំ ឲ្យយល់ពីស្ថានភាពផ្គត់ផ្គង់ទឹកក្នុងមូលដ្ឋានរបស់ខ្លួន មិនត្រឹមតែប្រភពទឹក បណ្តាញចែកចាយទឹកប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាប្រព័ន្ធរួមមួយចាប់ពីប្រភពទឹក ការយកទឹក ការដឹកជញ្ជូន ការស្តុកទឹក បញ្ហាប្រឈម ឬ ហានិភ័យអាកាសធាតុ និងការប្រើប្រាស់ទឹកក្នុងគ្រួសារ សាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពផងដែរ។

ការគូសផែនទីប្រភព និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទអាចជំរុញកិច្ចពិភាក្សាក្នុងសហគមន៍ និងការគិតអំពីស្ថានភាពទឹកផឹករបស់ពួកគាត់ ហើយវាក៏អាចផ្តល់ជាឯកសារព័ត៌មានជាក់លាក់ (ផែនទី) ដែលមានសារៈសំខាន់សម្រាប់ធ្វើផែនការកែលម្អសុវត្ថិភាពទឹក និងជួយបង្ហាញអំពីវឌ្ឍនភាពទឹកសុវត្ថិភាពក្នុងសហគមន៍ (ប្រសិនបើ ផែនទីត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់)។ ផែនទីប្រភព និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងសហគមន៍អាចបញ្ចូលសមាសធាតុដូចខាងក្រោម៖

- **សមាសធាតុដែលត្រូវមានក្នុងផែនទីភូមិ**
  - **ហេដ្ឋារចនាសម្ព័ន្ធភូមិ** (ផ្លូវ ខ្នងផ្ទះ សាលាឃុំ សាលារៀន ប៉ុស្តិ៍នគរបាល វត្ត/វិហារសាសនា ផ្សារ មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព)
  - **ទីតាំងប្រភពទឹក** (ឧទាហរណ៍ៈ ទន្លេ ស្ទឹង បឹង ស្រះ និងប្រភពទឹកធម្មជាតិដទៃទៀត)
  - **ចំណុចទឹកប្រើប្រាស់** (ឧទាហរណ៍ៈ អណ្តូងឯកជន និងសហគមន៍)
  - **ប្រព័ន្ធចែកចាយទឹក** (ឧទាហរណ៍ ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ (សហគមន៍ និងឯកជន) រួមទាំងស្ថានីយផលិតទឹកផឹក (សហគមន៍ និងឯកជន)(។ល។)
  - **ទីតាំងប្រភពបំពុលផ្សេងៗ** (ឧទាហរណ៍ៈ កាកសំណល់(រោងចក្រ សិប្បកម្ម កសិដ្ឋាន) កន្លែងចាក់សំរាម សត្តឃាតដ្ឋាន)
  - **ទីតាំងដែលមានបទពិសោធន៍ ឬ អាចមានគ្រោះមហន្តរាយ** (ឧទាហរណ៍ៈ ទីតាំងធ្លាប់រងគ្រោះទឹកជំនន់ ឬមានគ្រោះរាំងស្ងួត)
- **សមាសធាតុដែលត្រូវមានក្នុងផែនទីឃុំ**
  - **ហេដ្ឋារចនាសម្ព័ន្ធឃុំ** (ផ្លូវ សាលាឃុំ សាលារៀន ប៉ុស្តិ៍នគរបាល វត្ត/វិហារសាសនា ផ្សារ មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព)

- **ទីតាំងប្រភពទឹក** (ឧទាហរណ៍: ទន្លេ ស្ទឹង បឹង ស្រះ និងប្រភពទឹកធម្មជាតិដទៃទៀត)
- **ចំណុចទឹកប្រើប្រាស់** (ឧទាហរណ៍: អណ្តូងសហគមន៍)
- **ប្រព័ន្ធចែកចាយទឹក** (ឧទាហរណ៍ ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ (សហគមន៍ និងឯកជន) រួមទាំងស្ថានីយផលិតទឹកផឹក (សហគមន៍ និងឯកជន)(។ល។)
- **ទីតាំងប្រភពបំពុលផ្សេងៗ** (ឧទាហរណ៍: កាកសំណល់ (រោងចក្រ សិប្បកម្ម កសិដ្ឋាន) កន្លែងចាក់សំរាម សត្តឃាតដ្ឋាន) (។ល។)
- **ទីតាំងដែលមានបទពិសោធន៍ ឬអាចមានគ្រោះមហន្តរាយ** (ឧទាហរណ៍: ទីតាំងធ្លាប់រងគ្រោះទឹកជំនន់ ឬមានគ្រោះរាំងស្ងួត)

ក្នុងពេលគូសផែនទីផ្គត់ផ្គង់ទឹក ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវតែចូលរួម និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ (សម្រាប់ផែនទីផ្គត់ផ្គង់ទឹកភូមិ ត្រូវតែមានការចូលរួមពីសហគមន៍ក្នុងពេលដំណើរការ) ផងដែរ។ ការងារនេះអាចរៀបចំតាមរយៈការប្រជុំសាធារណៈ ឬការចុះផ្ទាល់តាមគ្រួសារ តាមសាលារៀន និងតាមវត្តអារាម។ល។ គោលបំណងសំខាន់ គឺដើម្បីបង្កើតឱកាសសម្រាប់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុធ្វើការផ្សព្វផ្សាយឲ្យបានទូទាំងភូមិ ឬឃុំអំពីទឹកសុវត្ថិភាព និងដំណើរការរៀបចំផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។ គំរូ នៃផែនទីផ្គត់ផ្គង់ទឹកភូមិ និងឃុំមានបង្ហាញនៅក្នុង**រូបភាពទី ៣ និង ៤** ខាងក្រោម។

❖ **វិធីសាស្ត្រ នៃការគូសផែនទី**

- យកផែនទីភូមិសាស្ត្រភូមិ ឬ ឃុំធ្វើជាគំរូ (ប្រសិនបើមាន)
- កំណត់សម្គាល់ទិស (ជើង)
- កំណត់ព្រំប្រទល់ភូមិសាស្ត្រ ភូមិ និងឃុំ
- គូសផ្លូវក្នុងភូមិ និងឃុំ (ផ្លូវជាតិ និងផ្លូវលំ)
- កំណត់សម្គាល់សំខាន់ៗ (សមាសធាតុភូមិ និងឃុំនៅខាងលើ)




**រូបភាពទី ៣៖ ផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតភូមិ**




រូបភាពទី ៤៖ ផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឃុំ

### ៣.២.២ ការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

បន្ថែមពីលើការគូសផែនទីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនឹងធ្វើការពិភាក្សា អង្កេត និងវាយតម្លៃអំពីប្រភពទឹក ការយកទឹក (ឧទាហរណ៍ ដង ឬបូមទឹក) ការដឹកជញ្ជូន ការស្តុកទឹក និងការអនុវត្តការបន្សុទ្ធទឹកនៅក្នុងសហគមន៍ (សាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព និងស្ថាប័នសាធារណៈផ្សេងៗ)។ ទោះបីជាទឹកយកពីប្រភពមានសុវត្ថិភាពសម្រាប់ផឹកយ៉ាងណាក៏ដោយ ក៏វាអាចឆ្លងបាក់តេរី/មេរោគនៅពេលដឹកជញ្ជូនក្នុងពេលស្តុក និងពេលយកមកប្រើប្រាស់ផងដែរ។ ហេតុនេះហើយ បានជាក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវការធ្វើការសង្កេត និងវាយតម្លៃដំណើរការបន្សុទ្ធទឹករបស់សហគមន៍ សាលារៀន និងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពដែលជាផ្នែកមួយនៃ**ជំហានទី ២** រួមមាន៖

- **ប្រភពទឹក**
  - ព័ត៌មានសង្ខេបផ្សេងៗរបស់ប្រភេទ នៃប្រភពទឹក ស្ថានភាពប្រភពទឹក សមត្ថភាពផ្គត់ផ្គង់ ការប្រើប្រាស់ប្រភពទឹកទាំងនោះ
  - ព័ត៌មានលម្អិត នៃការផ្គត់ផ្គង់ទឹកឃុំតាមប្រព័ន្ធបំពង់ ទឹកផឹកដប ឬប៊ីដុង
  - របាយការណ៍ស្ថានភាព ឬបញ្ហាប្រឈមផ្សេងៗជាសង្ខេបដែលមាននៅក្នុងសហគមន៍ រួមមានព័ត៌មាន និងបទពិសោធន៍អាកាសធាតុ ឬគ្រោះមហន្តរាយនានាគួរតែត្រូវបានពិពណ៌នារួមបញ្ចូលទាំងភាពញឹកញាប់ កម្រិតផលប៉ះពាល់ និងការខូចខាតផ្សេងៗនៅក្នុងភូមិ ឃុំ ផងដែរ
- **ការប្រមូលព័ត៌មានអំពីការអនុវត្ត នៃការយកទឹក និងការដឹកជញ្ជូនទឹក រួមមាន៖**
  - របៀប នៃការយកទឹកចេញពីប្រភព (ប្រភេទសម្ភារ ឬម៉ូទ័របូម)
  - របៀប នៃការដឹកជញ្ជូន (មធ្យោបាយដឹកជញ្ជូន ឬធុង)

- តើទឹកមានការការពារ (គ្របគម្របត្រឹមត្រូវ) ក្នុងពេលដឹកជញ្ជូនដែរឬទេ ?
- ចម្ងាយពីប្រភពដែលត្រូវដឹកជញ្ជូន (ចម្ងាយ និងពេលវេលា)
- តើនរណាជាអ្នកដឹកទឹក ?

- **ការប្រមូលព័ត៌មានអំពីការអនុវត្ត នៃការស្តុកទឹក រួមមាន៖**
  - តើប្រើឧបករណ៍អ្វីសម្រាប់ស្តុកទឹក ? (ឧ. ទំហំ សម្ភារ)
  - តើឧបករណ៍ស្តុកទឹកមានមាត់តូច ឬធំ ? (ឧ. អាចលូកដៃចូលបាន ឬមិនបាន)
  - ជាធម្មតា តើឧបករណ៍ស្តុកទឹកនោះដាក់នៅកន្លែងណា ? (ឧ. ក្នុង ឬក្រៅផ្ទះ)
  - តើនៅជិតនោះ មានប្រភពចម្លងបាក់តេរី/មេរោគ ដល់ឧបករណ៍ស្តុកទឹកនោះដែរឬទេ ?
  - តើគម្របឧបករណ៍ស្តុកទឹកបានការពារពីការចម្លងបាក់តេរី/មេរោគដែរឬទេ ?
  - តើគេយកទឹកចេញពីឧបករណ៍ស្តុកទឹកដោយរបៀបណា ? (ឧទាហរណ៍ ក្បាលរ៉ូប៊ីណេ ឬ " ដង ជ្រមុជ " ជាមួយកែវ ឬសម្ភារផ្សេងទៀត ?)
  - តើមានព័ត៌មាន ឬការអង្កេតណាផ្សេងទៀត ដែលទាក់ទងទៅនឹងឧបករណ៍ស្តុកទឹក ការចម្លងបាក់តេរី/មេរោគដែលអាចកើតមានដល់ទឹកដែរឬទេ ?

- **ការប្រមូលព័ត៌មានអំពីការអនុវត្ត នៃការបន្សុទ្ធទឹក រួមមាន៖**
  - តើមានវិធីសាស្ត្របន្សុទ្ធទឹកណាមួយដែលត្រូវប្រើសម្រាប់ទឹកផឹក ?
  - តាមការអង្កេត តើឧបករណ៍បន្សុទ្ធទឹក គឺវានៅដំណើរការ និងប្រើប្រាស់បានដែរឬទេ ?
  - ប្រសិនបើមាន តើវិធីសាស្ត្របន្សុទ្ធទឹកនោះជាអ្វី ប្រើយ៉ាងដូចម្តេច ?
  - សួរដេញអំពីវិធីសាស្ត្របន្សុទ្ធទឹករបស់គាត់ (ឧ. ប្រសិនបើ ដាំទឹក -តើឧបករណ៍ដាំទឹកនោះជាអ្វី ? ប្រើរយៈពេលប៉ុន្មានហើយ ?)
  - តើទឹកផឹកជានិច្ចកាលតែងតែបានបន្សុទ្ធ ឬបន្សុទ្ធម្តងម្កាល ?
  - តើសមាជិកគ្រួសារទាំងអស់ផឹកទឹកដែលបានបន្សុទ្ធ ឬមានអ្នកខ្លះអត់ផឹក ?

- **ការប្រមូលព័ត៌មានអំពីការប្រើប្រាស់ទឹកផឹក រួមមាន៖**
  - តើឧបករណ៍អ្វីប្រើសម្រាប់ដងទឹកផឹក ? (ឧ. កែវ កាទឹក ពែង។ល។)
  - តើឧបករណ៍ដងទឹកផឹក ប្រើប្រាស់រួមគ្នានៅក្នុងផ្ទះឬ ?(ឬប្រើផ្សេងគ្នា ?)
  - តើឧបករណ៍ដងទឹកផឹកទាំងនោះ ទុកនៅលើកម្រាលឥដ្ឋ (ឬផ្ទាល់ដី) ឬទុកនៅកន្លែងដែលអាចចម្លងបាក់តេរី/មេរោគ ?
  - តើឧបករណ៍ដងទឹកផឹកបានលាងសំអាតត្រឹមត្រូវដែរឬទេ ? តើវាមានគ្របបិទជិត ឬបានផ្កាប់ចុះ ដើម្បីជួយបង្ការការចម្លងបាក់តេរី/មេរោគដែរឬទេ ?
  - តើមានធុង ឬឧបករណ៍លាងសំអាតដៃនៅជិតធុងស្តុកទឹកដែរឬទេ ? មានសាប៊ូឬទេ ? តើសាប៊ូនោះប្រើប្រាស់ឬទេ ?
  - តើមានព័ត៌មាន ឬការអង្កេតណាផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងឧបករណ៍ទឹកផឹកដែរឬទេ ? ពេលបញ្ចប់ការធ្វើផែនទីនៅក្នុងជំហានទី ២ នឹងមានលទ្ធផលដូចខាងក្រោម៖
  - ផែនទីទឹកប្រើប្រាស់សម្រាប់ភូមិ ឬឃុំ

- ព័ត៌មានអំពីការប្រើប្រាស់ប្រភពទឹកកែលម្អ ប្រភពទឹកមិនមានការកែលម្អ និងហានិភ័យអាកាសធាតុ
- ការអនុវត្តរបស់សហគមន៍ដែលទាក់ទងទៅនឹងការយកទឹក ការដឹកជញ្ជូនទឹក ការស្តុកទឹក និងការបន្សុទ្ធទឹក និងការប្រើប្រាស់ទឹក

ក្រោយពេលបានលទ្ធផលខាងលើ ប្រធានក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ ត្រូវតែរាយការណ៍លទ្ធផល និងការរកឃើញទាំងឡាយទៅក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ ហើយត្រូវតែរក្សាទុកឯកសារដើមសម្រាប់ប្រើប្រាស់បន្តទៀតដើម្បីទុកជាឯកសារយោង។

## ៣.៣ .ជំហានទី ៣៖ ការកំណត់ និងការវាយតម្លៃគ្រោះថ្នាក់ និងវិធានការការពាររួមបញ្ចូលហានិភ័យដែលបង្កឡើងដោយអាកាសធាតុ

ក្រោយពេលបញ្ចប់ជំហានទី ២ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ (និងសហគមន៍) នឹងយល់ដឹងច្បាស់អំពីស្ថានភាពទឹកប្រើប្រាស់ក្នុងភូមិ ជំហានបន្ទាប់ គឺការវិភាគរកគ្រោះថ្នាក់ និងចាត់វិធានការការពារ ដើម្បីកាត់បន្ថយ ឬលុបបំបាត់គ្រោះថ្នាក់ទាំងនោះ។ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវតែមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការនៅជំហាននេះ ហើយឲ្យសហគមន៍ចូលរួមបានច្រើនបំផុតតាមដែលអាចធ្វើបាន។ តាមរយៈការចូលរួមយ៉ាងសកម្មរបស់សហគមន៍ អ្នករស់នៅក្នុងភូមិនឹងបានយល់កាន់តែប្រសើរអំពីគ្រោះថ្នាក់ដែលបង្កដល់ប្រភពទឹក ការប្រើប្រាស់ទឹក និងផ្តល់ឱកាសដល់ពួកគាត់ចូលរួមគំនិត យោបល់អំពីមធ្យោបាយដើម្បីគ្រប់គ្រងគ្រោះថ្នាក់ទាំងនោះ។

ផ្នែកទី ១ នៃជំហានទី ៣ ការកំណត់គ្រោះថ្នាក់ មានសមាសធាតុបី (០៣) សំខាន់ៗ គឺ៖

### ៣.៣.១ ជំហានទី ៣.ក ការកំណត់មុខសញ្ញាគ្រោះថ្នាក់ និងការធ្វើតេស្តគុណភាពទឹក

#### ៣.៣.១.១ ការកំណត់មុខសញ្ញាគ្រោះថ្នាក់

ការអង្កេតពីស្ថានភាពប្រភពទឹក ទំលាប់ និងអនាម័យ នៃការប្រើប្រាស់ទឹក នឹងផ្តល់ព័ត៌មានសំខាន់ៗដែលទាក់ទងទៅនឹងភាពងាយរងគ្រោះពីការចម្លងបាក់តេរី/មេរោគ ឬការបំពុលផ្សេងៗដល់ទឹកប្រើប្រាស់។ វាជួយដល់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុក្នុងការកំណត់បញ្ហា និងប្រភពបាក់តេរី/មេរោគ ឬការបំពុលផ្សេងៗនៅក្នុងសហគមន៍របស់គេ ហើយក៏ជាផ្នែកដ៏សំខាន់មួយ នៃការសិក្សារកគ្រោះថ្នាក់។

ទម្រង់អង្កេតអនាម័យជុំវិញទឹកប្រើប្រាស់ គឺជាឧបករណ៍សម្រាប់ធ្វើការកំណត់មុខសញ្ញាគ្រោះថ្នាក់ដែលបញ្ជីសំនួរសម្រាប់ត្រួតពិនិត្យ តាមដានអនាម័យតាមប្រភពទឹក និងការអនុវត្តតាមគ្រួសារដែលមានផ្តល់ជូននៅ**ក្នុងឧបសម្ព័ន្ធ ខ**។ បញ្ជីសំនួរអង្កេតអនាម័យអាចនឹងមិនឆ្លើយតបគ្រប់ទីកន្លែងនោះទេ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ អាចប្រើវាតាមកន្លែងសមស្របដែលអាចអនុវត្តន៍បាន។

បញ្ជីសំនួរត្រួតពិនិត្យ តាមដានអនាម័យបានរៀបចំឡើងសម្រាប់ជួយសម្រួលដល់ក្រុមការងារក្នុងការធ្វើអង្កេត ហើយចម្លើយទាំងអស់ត្រូវតែផ្អែកទៅលើការអង្កេត ឬការសម្ភាសន៍ជាមួយសហគមន៍។

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គួរតែអនុវត្តន៍ការត្រួតពិនិត្យតាមដានអនាម័យឲ្យបានទៀងទាត់ (ឧទាហរណ៍ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ) ជាធម្មតាប្រព័ន្ធត្រួតពិនិត្យ តាមដានអនាម័យមិនត្រឹមតែជួយដល់ជំហានទី ៣ របស់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំងមានប្រយោជន៍សម្រាប់គោលដៅផ្សេងៗទៀត ដូចជាការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាព (**ជំហានទី ៥**) និងដើម្បីជួយកំណត់បញ្ហា ដែលអាចប៉ះពាល់ទៅដល់គុណភាពទឹកភ្លាមៗ។

ទម្រង់ត្រួតពិនិត្យ តាមដានអនាម័យទាំងអស់ត្រូវតែបានរក្សាទុកជាមួយនឹងកំណត់ត្រាផ្សេងៗ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។

### ៣.៣.១.២ ការធ្វើតេស្តគុណភាពទឹក

ការធ្វើតេស្តគុណភាពទឹក បានផ្តល់ភស្តុតាងច្បាស់លាស់អំពីទឹកសុវត្ថិភាព (ឬការចម្លងបាក់តេរី/មេរោគ) សម្រាប់សហគមន៍ ឬក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ។

វិធីសាស្ត្រធ្វើតេស្តគុណភាពទឹកមានប្រើជាទូទៅ គឺធ្វើតេស្តរកមើលបាក់តេរី " **មាន ឬ គ្មាន** " (Present-Absent) សម្រាប់បង្ហាញអំពីវត្តមាន (total coliform bacteria)។ ការធ្វើតេស្តនេះមិនបានផ្តល់លទ្ធផលជាក់លាក់ថា ជាប្រភេទបាក់តេរីអ្វីមួយនោះទេ។ វិធីសាស្ត្រធ្វើតេស្ត "**មាន ឬ គ្មាន**" មានភាពងាយស្រួល និងមានតម្លៃទាប។ លទ្ធផល នៃការធ្វើតេស្តនេះ អាចផ្តល់ឲ្យអ្នកប្រើប្រាស់ទឹកដឹងថាតើទឹករបស់ពួកគាត់មានបាក់តេរី ឬគ្មានបាក់តេរី មានសុវត្ថិភាព ឬគ្មានសុវត្ថិភាពសម្រាប់ផឹកដែរឬទេ?

វិធីសាស្ត្រធ្វើតេស្តប៉ារ៉ាម៉ែតផ្សេងៗទៀតដែលបានកំណត់ក្នុងគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទរបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ ក៏អាចប្រើសម្រាប់ធ្វើតេស្តទឹកប្រើប្រាស់នៅក្នុងសហគមន៍បានដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើតេស្តប៉ារ៉ាម៉ែត្រទាំងនោះ ត្រូវតែតម្រូវឲ្យមានបរិក្ខារ និងការចំណាយបន្ថែម ដែលពិបាកក្នុងការអនុវត្តឲ្យបានទូលំទូលាយដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។

វិធីសាស្ត្រធ្វើតេស្តគុណភាពទឹកដែលជាក់លាក់ គឺត្រូវតែធ្វើនៅក្នុងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពទឹក ដែលមានឧបករណ៍គ្រប់គ្រាន់ និងអ្នកឯកទេសច្បាស់លាស់។ ការធ្វើតេស្តគុណភាពទឹកទាំងនេះមានភាពសុក្រឹតភាពខ្ពស់ ប៉ុន្តែ ត្រូវតែតម្រូវឲ្យមានថវិកាគ្រប់គ្រាន់ និងការប្តេជ្ញាចិត្តខ្ពស់ ។

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវតែកំណត់អាទិភាពលើការងារធ្វើតេស្តគុណភាពទឹក និងបង្កើតផែនការយកសំណាក មុនពេលចុះទៅសហគមន៍។ ឧទាហរណ៍ ផែនការយកសំណាកគុណភាពទឹកនៅសហគមន៍គួរតែមានដូចខាងក្រោម៖

- ធ្វើតេស្តគ្រប់ប្រភពទឹក ឬគ្រប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ដែលមាននៅក្នុងសហគមន៍ ស្របតាមគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ
- ធ្វើតេស្តដោយជ្រើសរើស (១០%) នៃប្រភពទឹកឯកជន ស្របតាមគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ
- ធ្វើតេស្តដោយជ្រើសរើស (២០%) ទឹកផឹកក្នុងគ្រួសារដែលបានទុកដាក់ក្នុងធុងដាក់ទឹកសម្រាប់ផឹក ដើម្បីរកមេរោគ និងបាក់តេរី ។

ជាក់ស្តែង ការធ្វើតេស្តគុណភាពទឹក (បាក់តេរី) ត្រូវតែអនុវត្តន៍នៅទីកន្លែង (សហគមន៍) ក្នុងជំហានទី ៣ រួចហើយ ជំហានទី ៥ (ពេលត្រួតពិនិត្យ តាមដានវឌ្ឍនភាព) ដើម្បីកំណត់ពីកម្រិត នៃការរីកចម្រើន។ ការធ្វើតេស្តត្រូវតែអនុវត្តន៍ដោយមន្ត្រីបច្ចេកទេសពីមន្ទីរអភិវឌ្ឍន៍ជនបទ ឬដោយអង្គការមិនមែនរដ្ឋាភិបាល ឬសមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដែលបានទទួលការបណ្តុះបណ្តាល ឬប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន។

លទ្ធផល នៃការធ្វើតេស្តនេះត្រូវតែត្រួតពិនិត្យដោយមន្ទីរអភិវឌ្ឍន៍ជនបទជាមួយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងផ្សព្វផ្សាយដល់សហគមន៍ ដែលជាផ្នែកមួយ នៃការលើកកម្ពស់ការយល់ដឹង។ កំណត់ត្រា (ឬឯកសារផ្សេងៗ) នៃការធ្វើតេស្តទាំងអស់ត្រូវតែរក្សាទុកដោយមន្ទីរអភិវឌ្ឍន៍ជនបទ និងក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ សម្រាប់ប្រើប្រាស់នាពេលអនាគត និងដើម្បីធ្វើការប្រៀបធៀបជាមួយការធ្វើតេស្តនៅពេលក្រោយ។

ដូចអ្វីដែលបានលើកឡើងខាងលើ ប្រសិនបើ អាចធ្វើបាន ប្រភពទឹកសហគមន៍ទាំងអស់គួរតែធ្វើតេស្ត។ ប្រភពទឹកឯកជន (គ្រួសារ) អាចធ្វើតេស្តប្រហែល ១០% ដើម្បីចំណេញពេល និងធនធាន។ សំណាកគំរូ ១០% នោះ ត្រូវតែជ្រើសរើសដោយចៃដន្យពីកន្លែងផ្សេងៗគ្នានៅក្នុងភូមិ។

លទ្ធផលធ្វើតេស្តគុណភាពទឹកផឹក (ឧ.ទឹកពីកំសៀវ ឬធុងដាក់ទឹកផឹកក្នុងគ្រួសារ) ត្រូវតែផ្តល់ឲ្យសមាជិកគ្រួសារភ្លាមៗ។ ការអប់រំ និងការផ្លាស់ប្តូរទម្លាប់មានឥទ្ធិពលខ្ពស់តាមរយៈលទ្ធផល នៃការធ្វើតេស្ត (ជាពិសេស ប្រសិនបើ គ្រួសារកំពុងផឹកទឹកគ្មានសុវត្ថិភាព)។ វាក៏អាចជាឧបករណ៍យ៉ាងល្អសម្រាប់ការផ្លាស់ប្តូរទម្លាប់។ ការធ្វើតេស្តគុណភាពទឹកក៏អាចអនុវត្តន៍បានផងដែរនៅតាមសាលារៀន និងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព។

ការធ្វើតេស្តគុណភាពទឹកអាចអនុវត្តន៍បានបន្ទាប់ពីធ្វើការត្រួតពិនិត្យ តាមដានអនាម័យនៅចំណុចប្រភពទឹក និងនៅតាមគ្រួសារ សាលារៀន និងស្ថាប័នដទៃទៀត។ ការត្រួតពិនិត្យ តាមដានអនាម័យអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់ “ **គ្រោះថ្នាក់ខ្ពស់** ” និង “ **គ្រោះថ្នាក់ទាប** ” ព្រមទាំងប្រភពទឹកមានគ្រោះថ្នាក់ខ្ពស់ និងទាប (ឧ. ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ អាចធ្វើតេស្តពីរភាគបី (២/៣) សម្រាប់ប្រភពទឹកដែលមានគ្រោះថ្នាក់ខ្ពស់ ហើយមួយភាគបី (១/៣) សម្រាប់ប្រភពទឹកមានគ្រោះថ្នាក់ទាប)។

នៅពេលធ្វើតេស្តគុណភាពទឹកនៅជុំទី ១ ចប់ ការប្រជុំសហគមន៍គួរតែរៀបចំដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ហើយក្រុមប្រឹក្សាឃុំ និងមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទគួរតែអញ្ជើញចូលរួមធ្វើបទបង្ហាញអំពីលទ្ធផលទៅដល់សហគមន៍ និងដើម្បីឆ្លើយសំណួរដែលពួកគាត់ចង់ដឹង។ លទ្ធផលតេស្តទឹកអាចជាមធ្យោបាយមួយដែលមានឥទ្ធិពលក្នុងការផ្តល់ព័ត៌មានដល់សហគមន៍អំពីទឹកសុវត្ថិភាព និងគ្រោះថ្នាក់ នៃការកើតមានបាក់តេរី/មេរោគ ក្នុងទឹកប្រើប្រាស់របស់ពួកគាត់។

### ៣.៣.១.៣ សមាសភាព និងការទទួលខុសត្រូវការធ្វើតេស្តគុណភាពទឹក

សមាសភាពក្នុងការធ្វើតេស្តគុណភាពទឹក រួមមាន នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទ និងក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ។

ចំពោះការធ្វើតេស្តរកមើលបាក់តេរី " **មាន ឬគ្មាន** " (Present-Absent) សម្រាប់បង្ហាញអំពីវត្តមាន (total coliform bacteria) ។ ក្រុមការងារបច្ចេកទេសនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទត្រូវតែធ្វើការបណ្តុះបណ្តាលដល់មន្ត្រីបច្ចេកទេស នៃមន្ទីរអភិវឌ្ឍន៍ជនបទ ដើម្បីធ្វើការបណ្តុះបណ្តាលបន្តដល់ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ និងភូមិសម្រាប់អនុវត្តន៍ដល់សហគមន៍។

### ៣.៣.២ ជំហានទី ៣.ខ ការវាយតម្លៃគ្រោះថ្នាក់ដែលបង្កដោយអាកាសធាតុ និងបរិស្ថាន និងផលប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងប្រភពទឹក

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវតែសិក្សាវាយតម្លៃប្រភពទឹក និងសេវាផ្គត់ផ្គង់ទឹកនៅក្នុងសហគមន៍ដែលអាចរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ ឬការប្រែប្រួលអាកាសធាតុ ដោយផ្អែកទៅលើអ្វីដែលធ្លាប់កើតមានពីមុន ឬយោងតាមគ្រោះថ្នាក់ដែលព្យាករណ៍ (អាស្រ័យទៅលើទីតាំង និងកត្តាផ្សេងៗ)។ កត្តាដែលក្រុមការងារអាចនឹងពិចារណា រួមមាន ៖

- តើបរិមាណទឹកលើដីមានការខ្វះខាតដោយសាររដូវប្រាំងយូរជាងមុន ឬរដូវវស្សាខ្លីជាងមុន ដែលធ្វើឲ្យពេលវេលា នៃការផ្គត់ផ្គង់យូរជាងមុន និងតម្រូវការស្តុកទឹកច្រើនជាងមុន?
- តើបរិមាណទឹកក្រោមដីថយចុះដោយសារតែបរិមាណទឹកភ្លៀងតាមរដូវកាល ឬជាសកម្មភាពរបស់មនុស្ស ដូចជា ការបូមយកទៅប្រើប្រាស់ច្រើន (ឧ. ការកើនឡើងទីប្រជុំជន ឬដោយសកម្មភាពកសិកម្ម)?
- តើតំបន់នោះមានទឹកជំនន់តាមរដូវកាល/ជំនន់ទឹកភ្លៀង ហើយនាំឲ្យមានការហូរចូលនូវបាក់តេរី/មេរោគទៅក្នុងស្រះ អណ្តូង ឬប្រភពទឹកផ្សេងៗទៀតដែរឬទេ? តើប្រភពទឹកលើដី (ទន្លេ ស្រះ បឹង) មានការថយចុះ ឬកើនឡើង នៃការបំពុលដោយសារការផ្លាស់ប្តូររបបទឹកភ្លៀង សកម្មភាពរបស់មនុស្ស ឬការប្រែប្រួលស្រទាប់ដីដែរឬទេ?
- ព័ត៌មានពីការប្រែប្រួលអាកាសធាតុ និងការព្យាករណ៍អាកាសធាតុនាពេលអនាគត ។ល។
- តើបរិមាណ ឬគុណភាពទឹកមានរងផលប៉ះពាល់ (អវិជ្ជមាន) ដោយការប្រែប្រួលណាមួយ នៃសកម្មភាពទាំងនោះដែរឬទេ?
- តើប្រភពទឹកដែលបានសាងសង់ ឬប្រភពទឹកថ្មីបានគិតគូរដល់ការប្រែប្រួលអាកាសធាតុ និងភាពធន់នឹងអាកាសធាតុនាពេលអនាគតដែរឬទេ?

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយក្លាយជារឿងសំខាន់ដែលត្រូវយកចិត្តទុកដាក់នៅប្រទេសកម្ពុជា ហើយក៏ត្រូវតែដាក់បញ្ចូលទៅក្នុងផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដើម្បីធ្វើការឆ្លើយតបផងដែរ។ ការផ្តល់ប្រឹក្សា ឬការគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទ គឺជាកត្តាដ៏សំខាន់សម្រាប់ការសិក្សាវាយតម្លៃអំពីគ្រោះថ្នាក់នេះ។

សម្រាប់ការព័ត៌មានលម្អិតមានក្នុង **ឧបសម្ព័ន្ធ ក. ផែនការសុវត្ថិភាពទឹកឃុំ** ក្នុងជំហានទី ៣ តារាង ៣.១ តារាង ៣.២ និងតារាង ៣.៣។

### ៣.៣.៣ ជំហានទី ៣.គ ការវាយតម្លៃអំពីគ្រោះថ្នាក់ និងវិធានការត្រួតពិនិត្យ តាមដាន

ការត្រួតពិនិត្យ ការតាមដានអនាម័យ និងលទ្ធផលតេស្តគុណភាពទឹកគួរតែអនុវត្តន៍ដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដើម្បីវាយតម្លៃអំពីគ្រោះថ្នាក់សុវត្ថិភាពទឹកក្នុងភូមិ ឬឃុំ។ គ្រោះថ្នាក់ នៃសុវត្ថិភាពទឹកអាចទាក់ទងទៅនឹងគុណភាពទឹក (ទឹកសុវត្ថិភាព) ឬបរិមាណទឹក (ឧ. ការថយចុះបរិមាណទឹក នៃប្រភពទឹកប្រើប្រាស់ ឬដោយសារបញ្ហាបច្ចេកទេស ឬគ្រោះមហន្តរាយ)។ គ្រោះថ្នាក់ នៃគុណភាពទឹករួមបញ្ចូលទាំងការកើតមានបាក់តេរី/មេរោគ ការបំពុលដោយសារជាតុគីមី (ឧ. ដូចជា សារជាតុពុលអាសេនិច ក្លរអរ) ឬលក្ខណៈរូប (ឧ. ទឹកមានជាតិដែកខ្ពស់ រសជាតិមិនល្អ ភាពល្អក់ខ្ពស់ ឬបញ្ហាផ្សេងទៀត)។ ឧទាហរណ៍មួយចំនួន នៃគ្រោះថ្នាក់ដែលអាចកើតមានលើគុណភាពទឹកនៅតំបន់ជនបទ៖

- ការបន្ទោរបង់ពាសវាលពាសកាល ឬការចោលលាមកទារកមិនត្រឹមត្រូវ
- បង្គន់អនាម័យសង់ជិតប្រភពទឹកពេក (ចម្ងាយតិចជាង ១៥-២០ ម៉ែត្រ)
- ការបោះចោលកាកសំណល់ធម្មជាតិ ឬកាកសំណល់កសិកម្ម រួមទាំងលាមកសត្វ
- ការកើតមានសារជាតុពុលគីមីធម្មជាតិក្នុងប្រភពទឹកក្រោមដី (ឧ. សារជាតុពុលអាសេនិច)
- ថ្លុកទឹកកខ្វក់នៅជិតអណ្តូង
- ការបោះចោលកាកសំណល់រាវ និងរឹងតាមគ្រួសារមិនបានត្រឹមត្រូវ (លើដីទំនេរ ឬរណ្តៅដែលគ្មានការផ្សាភ្ជិត)
- ការហូរចូលនូវកាកសំណល់រឹង និងរាវពីរោងចក្រ សហគ្រាសដែលអាចបង្កផលប៉ះពាល់ដល់គុណភាពទឹក
- ការបាត់បង់/បំពុលប្រភពទឹកដោយសារអាកាសធាតុ (ភាពរាំងស្ងួត ទឹកជំនន់ និងការបំពុលដោយការច្រោះដី)
- ការថយចុះ នៃកម្រិតទឹកក្រោមដី ឬបញ្ហា និងការប្រឈមចំពោះធនធានទឹកក្រោមដីផ្សេងៗទៀត
- ខឿនអណ្តូងបែកបាក់ ឬអណ្តូងទឹកសង់មិនត្រឹមត្រូវតាមស្តង់ដា ដូចជា ការដាក់ក្បាលស្នប់ ការចាក់កម្រាលសាប ឬចង្អូរបង្ហូរទឹកចេញ
- កង្វះការថែទាំជុំវិញអណ្តូង (ឧ. គ្មានរបងព័ទ្ធជុំវិញ)
- ធុងដងទឹកមិនបានលាងសំអាត ឬទម្លាប់មិនសំអាត
- កង្វះការថែទាំជុំវិញអណ្តូង (ឧ. គ្មានរបងព័ទ្ធជុំវិញ)
- ឧបករណ៍ស្តុកទឹក និងការយកទឹកផឹកគ្មានអនាម័យនៅក្នុងគ្រួសារ

លទ្ធផល នៃការវាយតម្លៃគ្រោះថ្នាក់ត្រូវតែផ្សព្វផ្សាយដល់សហគមន៍តាមរយៈការប្រជុំ ដើម្បីផ្តល់ឱកាសសម្រាប់សំណួរ និងចម្លើយ (បើអាច ឃុំ និងមន្ទីរអភិវឌ្ឍន៍ជនបទគួរតែចូលរួម)។ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ (ឬអ្នកសម្របសម្រួលកិច្ចប្រជុំម្នាក់មកពីមន្ទីរអភិវឌ្ឍន៍ជនបទ) ត្រូវតែលើកទឹកចិត្តសហគមន៍ឲ្យចូលរួមវិភាគបញ្ហាដែលពួកគេបានកំណត់ ដែលជាការលើកទឹកចិត្តឲ្យមានការយល់ដឹងកាន់តែប្រសើរអំពីគ្រោះថ្នាក់។

នៅពេលដែលគ្រោះថ្នាក់នីមួយៗត្រូវបានកំណត់ និងពិភាក្សា អ្នកចូលរួមត្រូវតែចាប់ផ្តើមកំណត់ "**វិធានការការពារ**" ដែលសមស្របសម្រាប់បញ្ហានីមួយៗ។ ឧទាហរណ៍ គ្រោះថ្នាក់ដែលអាចកើតមានលើទឹកផឹក និងវិធានការការពារដែលមានការត្រួតពិនិត្យ តាមដានដែលពាក់ព័ន្ធនៅក្នុង**តារាងទី ៣ ដល់តារាងទី ៦** ខាងក្រោម។

**តារាងទី ៤ ៖ ឧទាហរណ៍ គ្រោះថ្នាក់ដែលអាចកើតមានចំពោះប្រភពទឹក និងវិធានការឆ្លើយតប**

| ល.រ | គ្រោះថ្នាក់ដែលអាចកើតមានចំពោះប្រភពទឹក | វិធានការឆ្លើយតប |
|---|---|---|
| ១ | លាមកសត្វនៅលើ ឬជុំវិញអណ្តូង ឬក្បែរប្រភពទឹកលើដី | - ធ្វើរបង (ឬជួសជុលរបង) ដើម្បីកុំឲ្យសត្វចេញចូលបាន<br>- សំអាតសំរាមក្នុង និងជុំវិញអណ្តូង<br>- បង្កើតបម្រាមក្នុងសហគមន៍ (កុំឲ្យសត្វគោ ក្របី ជ្រូក ទៅជិតអណ្តូង)<br>- ទុកដាក់លាមកសត្វនៅកន្លែងដែលមានចាក់សាប |
| ២ | ខឿនអណ្តូងខូច ឬប្រេះ ចង្អូរបង្ហូរទឹកនៅជុំវិញមិនល្អ | - សង់ថ្មី (ឬជួសជុល) កម្រាលសាបអណ្តូង<br>- កែលម្អជម្រាលនៅជុំវិញអណ្តូង<br>- ធានាថា កម្រាលសាបមានចង្អូរបង្ហូរទឹកដែលដំណើរការ ហើយរណ្តៅស្តុកទឹកកខ្វក់មានក្រាលបាតគ្រួស/ខ្សាច់<br>- ដាក់ក្លរីនក្នុងអណ្តូង បន្ទាប់ពីជួសជុលកម្រាលសាប ឬចង្អូរបង្ហូរទឹក ដើម្បីសម្លាប់បាក់តេរី/មេរោគ |
| ៣ | ការបន្ទោរបង់ពាសវាលពាសកាលក្នុងភូមិ | បញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុង តាមរយៈយុទ្ធនាការអនាម័យ ការសាងសង់បង្គន់អនាម័យ និងប្រើប្រាស់បង្គន់គ្រប់គ្រួសារទាំងអស់ |
| ៤ | បង្គន់អនាម័យសង់ជិតអណ្តូង (ឧ.តិចជាង ១៥-២០ ម៉ែត្រ) | - សាងសង់បង្គន់ឆ្ងាយពីប្រភពទឹក<br>- សាងសង់បង្គន់ដោយមានការផ្សាភ្ជិតចន្លោះកង់លូ |
| ៥ | ស្រះគ្មានរបង ឬគ្មានអ្វីការពារ ធ្វើឲ្យកើតមានស្លែ (ឧ. រុក្ខជាតិ) នៅក្នុងស្រះនាំឲ្យកខ្វក់ទឹក | - លើកដីខ្ពស់ពីមាត់ស្រះ ឬជុំវិញស្រះ<br>- ធ្វើ (ឬជួសជុល) របងដើម្បីកុំឲ្យសត្វគោ ក្របី ជ្រូកចូល<br>- សំអាតបរិវេណជុំវិញស្រះ និងកាប់ឆ្ការរុក្ខជាតិដែលដុះ (ជាពិសេស នៅរដូវប្រាំង)<br>- បង្កើតបម្រាមក្នុងសហគមន៍ ដើម្បីទប់ស្កាត់ការចាក់សំរាម ការបោកគក់ ឬគោ ក្របី ជ្រូក ចូលក្នុងស្រះ |
| ៦ | អណ្តូងលូគ្មានការការពារ (អត់កម្រាលសាប កង់លូ ឬគម្របលូ) | - ធ្វើគម្របការពារអណ្តូង (កម្រាលសាបរៀបដាក់លូ និងគម្រប)<br>- ប្រើម៉ូទ័របូមទឹក (ឧ.មិនឲ្យអ្នកប្រើប្រាស់យកធុងដងទឹកដោយផ្ទាល់ពីអណ្តូង) |

| ល.រ | គ្រោះថ្នាក់ដែលអាចកើតមានចំពោះប្រភពទឹក | វិធានការឆ្លើយតប |
|---|---|---|
| ៧ | ទឹកអណ្តូងរីង | ស្វែងរកប្រភពទឹកថ្មី ដូចជា៖<br>- ទឹកលើដី ជីកស្រះដែលមានទំហំធំគ្រប់គ្រាន់សម្រាប់ស្តុកទឹកប្រើប្រាស់តាមការព្យាករណ៍ភាពស្ងួតនៅពេលអនាគត<br>- ការខួងអណ្តូងថ្មីដែលមានការគណនាបរិមាណទឹក និងធ្វើតេស្តជារទឹក (pumping test) និងអនុវត្តន៍តាមស្តង់ដាបច្ចេកទេស<br>- អណ្តូងលូ ត្រូវតែស្តារ ឬជីកជម្រៅបន្ថែម<br>- សាងសង់អាងត្រងទឹកភ្លៀងដែលអាចផ្គត់ផ្គង់ទឹកក្នុងរដូវប្រាំង ស្របតាមការព្យាករណ៍រយៈពេលរាំងស្ងួត<br>- ស្វែងរកប្រភពទឹកបណ្តាញ |
| ៨ | អណ្តូងលិចទឹក | - ការសម្លាប់មេរោគក្នុងអណ្តូង ក្រោយពេលទឹកជំនន់<br>- ការលើកខឿនអណ្តូងឲ្យខ្ពស់ផុតពីទឹក និងការសាងសង់អណ្តូងធន់នឹងការជ្រាបទឹក និងធន់នឹងកំលាំងទឹកហូរ។ |
| ៩ | ការប្រើប្រាស់ទឹកបណ្តាញនៅក្នុងតំបន់លិចទឹក | - តបណ្តាញឲ្យផុតកម្ពស់ទឹកលិច |

**តារាងទី ៥៖ ឧទាហរណ៍ គ្រោះថ្នាក់ដែលអាចកើតមានក្នុងពេលយក/ដងទឹក ដឹកជញ្ជូនទឹក និងវិធានការការពារ**

| ល.រ | គ្រោះថ្នាក់ដែលអាចកើតមានក្នុងពេលយក/ដងទឹក និងដឹកជញ្ជូនទឹក | វិធានការឆ្លើយតប |
|---|---|---|
| ១ | ធុងទឹកដាក់ផ្ទាល់ដី ឬដាក់កន្លែងកខ្វក់ មុនពេលយកទៅដងទឹកអណ្តូងលូ | - កន្លែងយកទឹកមានចាក់កម្រាលសាប<br>- មានគម្របសម្រាប់ធុងយោងទឹកនៅពេលប្រើរួច<br>- គ្របមាត់អណ្តូងលូ ឬប្រើម៉ូទ័របូមទឹកដើម្បីកុំឲ្យមានអ្នកណាយកធុងដងផ្ទាល់<br>- ដាក់បម្រាមកុំឲ្យមានការយកធុងទឹកដែលមិនស្អាតទៅដងទឹកក្នុងអណ្តូង |
| ២ | ធុងសម្រាប់ដឹកទឹកមិនបានសំអាត (អាចកើតមានបាក់តេរី/មេរោគក្នុងទឹក) | សំអាតធុងសម្រាប់ដងទឹកជាប្រចាំ លាងជាមួយក្លរីន ឬបន្ទាប់មកលាងជាមួយទឹកក្តៅ និងផ្កាប់ចុះនៅកន្លែងស្ងួតហើយស្អាត |

**តារាងទី ៦៖ ឧទាហរណ៍ គ្រោះថ្នាក់ នៃការស្តុកទឹក និងវិធានការការពារ**

| ល.រ | គ្រោះថ្នាក់ នៃការស្តុកទឹក | វិធានការឆ្លើយតប |
|---|---|---|
| ១ | ទឹកដឹកទុកដាក់អត់គម្រប ឬមានមាត់ធំអាចលូកដៃចូល ឬមានកន្លែងងាយស្រួលក្នុងការធ្វើឲ្យមានបាក់តេរី/មេរោគបាន | - ប្រើធុងទឹកមានគម្រប<br>- ធុងទឹកដែលមានក្បាលរ៉ូប៊ីណេ<br>- ទិញ ឬធ្វើគម្របធុងទឹក |

| ល.រ | គ្រោះថ្នាក់ នៃការស្តុកទឹក | វិធានការឆ្លើយតប |
|---|---|---|
| ២ | ពាងទឹកទុកនៅលើដី ឬនៅកន្លែងដែលមានមនុស្ស ឬសត្វច្រើនឆ្លងកាត់ដែលអាចបង្កឲ្យមានបាក់តេរី/មេរោគក្នុងទឹកប្រើប្រាស់ | - ធ្វើគម្របពាងទឹក<br>- ធ្វើកម្រាលសាប ឬកំណល់សម្រាប់ដាក់ពាងទឹក<br>- ដាក់ពាងទឹកនៅកន្លែងដែលមានសុវត្ថិភាព ហើយស្ថិតនៅឆ្ងាយពីសត្វ ឬក្មេងៗ |
| ៣ | ពាងទឹកអត់គ្រប មានស្លែ និងបញ្ហាដទៃទៀតដែលមើលឃើញ | - ពាងទឹកត្រូវតែសំអាតជាប្រចាំ<br>- លាយសូលុយស្យុងក្លរីនសម្រាប់លាងសំអាតជាពិសេស ក្រោយពេលសំអាតដំបូងរួច<br>- ពាងទឹកត្រូវតែគ្របជានិច្ច |

**តារាងទី ៧៖ឧទាហរណ៍ ការបន្សុទ្ធ និងការស្តុកទឹក និងវិធានការគ្រប់គ្រង**

| ល.រ | ការបន្សុទ្ធ និងការស្តុកទឹក | វិធានការគ្រប់គ្រង |
|---|---|---|
| ១ | ទឹកផឹកនៅក្នុងគ្រួសារ (សង្ស័យ) អាចមិនមានសុវត្ថិភាព ដោយសារ មិនបានបន្សុទ្ធ | - ធ្វើតេស្តគុណភាពទឹក និងផ្សព្វផ្សាយលទ្ធផលដល់អ្នកប្រើប្រាស់<br>- លើកទឹកចិត្តឲ្យប្រើប្រាស់វិធីសាស្ត្របន្សុទ្ធទឹកដែលត្រឹមត្រូវ |
| ២ | គ្រួសារមិនប្រើប្រាស់វិធីសាស្ត្របន្សុទ្ធទឹកឲ្យបានត្រឹមត្រូវ | - ចុះតាមផ្ទះ និងធ្វើតេស្តទឹក ហើយបង្ហាញលទ្ធផល<br>- ប្រសិនបើ ចាំបាច់ គេត្រូវតែធ្វើការណែនាំឲ្យប្តូរវិធីប្រើផ្សេង<br>- លើកទឹកចិត្តគ្រួសារដែលអនុវត្តន៍ល្អ ជួយពន្យល់គ្នា ឬចូលរួមជាមួយក្រុមស្ម័គ្រចិត្តសុខភាពភូមិ ដើម្បីរៀនបន្ថែមអំពីរបៀបទុកដាក់ទឹកឲ្យមានសុវត្ថិភាព |
| ៣ | ធុងដាក់ទឹកផឹកទុកនៅក្រៅ ឬក្រោមផ្ទះ នៅកន្លែងដែលមិនស្អាត | - រក្សាទុកធុងដាក់ទឹកផឹកនៅក្នុងផ្ទះ<br>- ប្រសិនបើ ទុកនៅក្រៅផ្ទះវាត្រូវតែមានគម្របគ្របពីលើ និងដាក់ឲ្យផុតពីដី (កន្លែងដែលស្អាត) |
| ៤ | ធុងទឹកទុកនៅផ្ទាល់ដី ឬកម្រាលក្នុងផ្ទះ នៅកន្លែងដែលមនុស្សដើរចុះឡើងច្រើន ឬកន្លែងមិនស្អាត | - ដាក់ធុងទឹកឲ្យផុតពីដី ឬនៅលើអ្វីដែលខ្ពស់ពីក្តារ ឬកម្រាលផ្ទះ |
| ៥ | ធុងទឹកគ្មានរ៉ូប៊ីណេ ដូច្នេះ គេត្រូវតែជ្រមុជសម្ភារដងទឹក | - ប្រើធុងទឹកដែលមានក្បាលរ៉ូប៊ីណេ មិនអាចប៉ះដៃផ្ទាល់ ឬជ្រមុជដងទឹក |
| ៦ | សមាជិកគ្រួសារប្រើកាទឹក  ឬកែវរួមគ្នា | - មានកាទឹក កែវទឹករៀងៗខ្លួន ឬយ៉ាងហោចណាស់មានមួយសម្រាប់ក្មេងៗ |
| ៧ | កែវផឹកទឹកមិនបានលាងសំអាត ឬទុកដាក់នៅកន្លែងមិនស្អាត | - រក្សាកែវផឹកទឹកឲ្យស្អាត ខ្ពស់ពីកម្រាល/ក្តារ ហើយត្រូវតែមានប្រអប់គ្របកែវ |

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងសហគមន៍ត្រូវតែត្រួតពិនិត្យពីគ្រោះថ្នាក់ នៃការផ្គត់ផ្គង់ទឹក និងវិធានការគ្រប់គ្រងនានាជាមួយគ្នា ហើយធ្វើការវាយតម្លៃ និងកំណត់អាទិភាពគ្រោះថ្នាក់ដែលចាំបាច់ សម្រាប់សហគមន៍ដោយប្រើទម្រង់ដែលមានស្រាប់នៅក្នុងសៀវភៅផែនការសុវត្ថិភាពទឹក។

សរុបមក ដំណើរការនេះ គឺក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងសហគមន៍ត្រូវតែមានបញ្ជីអាទិភាពអំពីបញ្ហាទឹកសុវត្ថិភាពដែលនឹងត្រូវឆ្លើយតបដោយក្រុមការងារ។

## ៣.៤. ជំហានទី ៤៖ ការរៀបចំ និងការអនុវត្តផែនការកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលធន់នឹងអាកាសធាតុ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង

### ៣.៤.១ ការរៀបចំផែនការកែលម្អ

បន្ទាប់ពីកំណត់គ្រោះថ្នាក់ និងវិធានការគ្រប់គ្រងក្នុងជំហានទី ៣ រួចមក ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវតែធ្វើផែនការកែលម្អដែលលម្អិតច្បាស់លាស់។ ផែនការកែលម្អ គឺជាផ្នែកដ៏សំខាន់របស់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ។ នៅក្នុងផែនការកែលម្អ គេត្រូវតែបញ្ចូលយុទ្ធនាការបង្កើនការយល់ដឹង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីគ្រោះថ្នាក់ដែលកើតមានក្នុងភូមិ និងឃុំ។

ផែនការកែលម្អ ត្រូវតែបង្កើតឡើងដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដែលមានរួមបញ្ចូល នៃការកំណត់ចំនុចសំខាន់ៗ ដូចខាងក្រោម៖

**១. អ្នកណា:** គ្រប់សមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុទាំងអស់ត្រូវតែមានវត្តមាន។ ប្រធានក្រុមអាចអញ្ជើញតំណាងសហគមន៍មួយចំនួន ជាពិសេស អ្នកដែលមានការចាប់អារម្មណ៍ និងការយល់ដឹងច្រើនក្នុងពេលធ្វើផែនទីទឹកប្រើប្រាស់ ការវាយតម្លៃ និងការធ្វើតេស្តគុណភាពទឹក។ ក៏ដូចគ្នាដែរ តំណាងឃុំ និងមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទគួរតែត្រូវបានអញ្ជើញចូលរួមដើម្បីគាំទ្រដំណើរការនេះ។

**២. ពេលណា:** ផែនការគួរតែធ្វើឡើងភ្លាមៗ បន្ទាប់ពីការវាយតម្លៃទឹកប្រើប្រាស់ (**ជំហានទី ២** និង **ជំហានទី ៣**)។

**៣. ទីកន្លែង:** កន្លែងធំ មានទីធ្លាទូលាយសម្រាប់ដាក់តុ កៅអី និងកន្លែងសម្រាប់បិទផែនទីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងក្រដាសធំៗបន្ថែមទៀត។ ជម្រើសល្អអាចនៅសាលារៀន សាលាឃុំ ឬវត្តអារាម។ គេត្រូវតែកំណត់ពេលវេលាជាក់លាក់ ទីតាំង ដើម្បីជានាថា អាចរៀបចំការប្រជុំបានដែរឬទេ?

**៤. វិធីសាស្ត្រ:** ប្រធានក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងសមាជិកក្រុមការងារត្រូវតែរៀបចំរបៀបវារៈច្បាស់លាស់សម្រាប់កិច្ចប្រជុំ និងប្រាកដថា គ្រប់ៗគ្នាត្រូវតែដឹងថា អ្នកណាជាអ្នកសម្របសម្រួលដល់កិច្ចប្រជុំនោះ (**ភាគច្រើនជាប្រធានក្រុមការងារ**)។ បញ្ជាក់៖

ក. លទ្ធផលដែលចង់បានពីកិច្ចប្រជុំ គឺច្បាស់លាស់

ខ. វិន័យសម្រាប់កិច្ចប្រជុំ គឺច្បាស់លាស់

គ. សម្ភារប្រើប្រាស់សម្រាប់ការប្រជុំ មានដូចជា ក្រដាសផ្ទាំងធំ ប៊ិច ស្កុតបិទក្រដាស។ល។

ឃ. កំណត់ត្រាដែលបានរៀបចំត្រូវបានយកទៅជាមួយ (ផែនទីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ កំណត់ត្រាកិច្ចប្រជុំមុនៗ សម្ភារអប់រំ ផ្សព្វផ្សាយអំពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ សម្ភារអប់រំ ផ្សព្វផ្សាយអំពីការផ្លាស់ប្តូរទម្លាប់)។ល។

ការរៀបចំផែនការកែលម្អនឹងតម្រូវឲ្យមានការវិភាគអំពីគ្រោះថ្នាក់ ដែលបានកំណត់នៅជំហានទី ៣ និងវិធានការត្រួតពិនិត្យ តាមដាន (សកម្មភាព) ដែលអនុវត្តន៍។ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនឹងត្រូវពិចារណាអំពីកត្តាប្រឈមក្នុងការអនុវត្តជាក់ស្តែង ដូចជា ប្រភពធនធានដែលមាន។ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ នឹងត្រូវធ្វើការជាមួយសហគមន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទ ក៏ដូចជាមួយអ្នកគាំទ្រផ្សេងៗទៀត ដើម្បីស្វែងរកធនធានផងដែរ។

ផែនការរយៈពេលខ្លីអាចផ្តោតទៅលើធនធាន និងសមត្ថភាពដែលមានស្រាប់ក្នុងសហគមន៍។ ផែនការរយៈពេលវែងត្រូវការការគាំទ្រពីរដ្ឋបាលមូលដ្ឋាន អង្គការ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នផ្សេងៗទៀត ដើម្បីផ្តល់ជំនាញបច្ចេកទេស សម្ភារ បរិក្ខារ និងធនធានហិរញ្ញវត្ថុ។

- ផែនការរយៈពេលខ្លី (ឧទាហរណ៍)៖
  - **ការសំអាតបរិស្ថាន ៖** យកអ្វីដែលអាចជាប្រភពចម្លងបាក់តេរី/មេរោគ ឬការបំពុលផ្សេងៗ ដូចជាសំរាមបោះចោលគ្មានរបៀប ចង្អូរបង្ហូរទឹកមិនស្អាត ប្រឡាយបង្ហូរទឹកស្អុះ។
  - **ការពារតួអណ្តូងស្នប់ ៖** ដូរ (ឬធ្វើការជួសជុល) របងជុំវិញអណ្តូង លាងសំអាត និងកែលម្អចង្អូរបង្ហូរទឹក និងបង្កើតបម្រាមថែទាំអណ្តូង និងបរិវេណជុំវិញ ដូចជា ចងគោ ក្របី ជ្រូកក្បែរ ឬសកម្មភាពផ្សេងៗទៀតដែលនាំឲ្យមានការចម្លងបាក់តេរី/មេរោគ។
  - **ការប្រើប្រាស់ និងការថែទាំ ៖** ធ្វើការរៀបចំ (ឬកែសម្រួល) ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ (ឧទាហរណ៍ ក.អ.ទ.អ) សម្រាប់ចំណុចទឹក ឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលមានស្រាប់។ នេះអាចរួមបញ្ចូលទាំងការបង្កើត (ឬកែសម្រួល) កម្រៃសេវាប្រើប្រាស់ទឹក និងមធ្យោបាយផ្សេងៗទៀតដើម្បីឲ្យអណ្តូង ឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទមានការថែរក្សា និងដំណើរការប្រកបដោយនិរន្តរភាព។
  - **បង្កើនការយល់ដឹង៖** ធ្វើយុទ្ធនាការក្នុងមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តនានាដែលពាក់ព័ន្ធទៅនឹងជំងឺដែលបណ្តាលមកពីទឹក ការបន្សុទ្ធទឹក និងអនាម័យនៅសហគមន៍ សាលារៀន និងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព។
  - **បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល៖** រៀបចំ និងធ្វើយុទ្ធនាការដើម្បីបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល និងលើកកម្ពស់ឲ្យមានការសាងសង់បង្គន់ និងប្រើប្រាស់បង្គន់អនាម័យឲ្យបានត្រឹមត្រូវ។
  - សកម្មភាពជាច្រើនទៀតដែលមានក្នុងតារាង ៣-៦ ខាងលើ។
- ផែនការរយៈពេលវែង (ឧទាហរណ៍)៖
  - **ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទមិនដំណើរការ ឬខូច៖** ជួសជុលម៉ូទ័របូមទឹក ជួសជុលកម្រាលសាប ឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលមិនដំណើរការ ឬខូចឲ្យដំណើរការឡើងវិញ។

- **សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទថ្មី ឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទផ្សេងៗទៀតសម្រាប់សហគមន៍** ដើម្បីសមភាព និងនិរន្តរភាព ក្នុងការទទួលបានប្រភពផ្គត់ផ្គង់ទឹកដែលមានការកែលម្អ ១០០% សម្រាប់ប្រជាជន។
- **ផ្តល់ជម្រើសក្នុងការទទួលបានហិរញ្ញប្បទានសម្រាប់ជនក្រីក្រ** ទាក់ទាញស្ថាប័នមីក្រូហិរញ្ញវត្ថុ និងបង្កើតមូលនិធិទុនបង្វិល ឬមធ្យោបាយផ្សេងៗទៀតដើម្បីឱ្យគ្រួសារក្រីក្របំផុតមានលទ្ធភាពចូលរួមក្នុងការលើកកម្ពស់សេវាផ្គត់ផ្គង់ទឹក និងអនាម័យជនបទនៅតាមគ្រួសារ ដូចជា ការទិញធុងចម្រោះទឹកប្រើប្រាស់ក្នុងគ្រួសារ ការជួសជុលម៉ូទ័របូមទឹក ឬការសាងសង់បង្គន់អនាម័យជាដើម។ វាអាចបញ្ចូលការបង្កើតលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់ការផ្ទេរថវិកា ឬយន្តការផ្សេងៗដល់គ្រួសារក្រីក្របំផុត (ឧទាហរណ៍ អ្នកដែលគ្មានលទ្ធភាពខ្ចីលុយគេទិញ)។

ក្នុងការបង្កើតផែនការកែលម្អ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវតែដឹងនូវបញ្ហាមួយចំនួន ដូចខាងក្រោម៖

- **ការអនុវត្តជាក់ស្តែង៖** តើផែនការជោគជ័យដែរឬទេ ប្រសិនបើ មានធនធានបច្ចេកទេស និងហិរញ្ញវត្ថុ ជាមួយនឹងពេលវេលាកំណត់ដែលក្រុមការងារគិតថាសមរម្យ?
- **អត្ថប្រយោជន៍៖** តើមានមនុស្សប៉ុន្មាននាក់នឹងទទួលបានផលប្រយោជន៍ពីវិធានការកាត់បន្ថយផលប៉ះពាល់នេះ ហើយវិធានការនេះនឹងអនុវត្តន៍ដោយស្មើភាពគ្នាចំពោះសមាជិកទាំងអស់ក្នុងសហគមន៍យ៉ាងដូចម្តេច?
- **ប្រសិទ្ធភាពចំណាយ៖** តើធនធានដែលត្រូវការ (ថវិកា ពេលវេលា កម្លាំងពលកម្ម សម្ភារប្រើប្រាស់។ល។) សមស្របដែលអាចសម្រេចបាន (ការកាត់បន្ថយគ្រោះថ្នាក់ ការលើកកម្ពស់សុខភាព សន្សំពេលវេលា។ល។) ដែរឬទេ?
- **និរន្តរភាពបរិស្ថាន៖** តើវិធានការការពារបន្តនៅមានក្នុងរយៈពេលវែង (ឧទាហរណ៍ ១០-២៥ ឆ្នាំ) សម្រាប់ការពារការប្រែប្រួលអាកាសធាតុ ការកើនកំដៅ គ្រោះមហន្តរាយ ដែរឬទេ?
- **នយោបាយ និងសង្គមជាក់ស្តែង៖** តើផែនការកែលម្អដែលបានលើកឡើងស្របគ្នាជាមួយគោលដៅ និងគោលនយោបាយរបស់រដ្ឋបាលមូលដ្ឋាន និងថ្នាក់ជាតិដែរឬទេ? តើវាអាចទទួលយកបាន (គិតទាំងវប្បធម៌ និងសង្គម) នៅថ្នាក់មូលដ្ឋានដែរឬទេ?
- គំរូ នៃការរៀបចំផែនការកែលម្អផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុមានផ្តល់ជូននៅក្នុង **ឧបសម្ព័ន្ធទី ក. ផែនការសុវត្ថិភាពទឹកឃុំ** ជំហានទី ៤។

### ៣.៤.២ ការអនុវត្តផែនការកែលម្អ

ផែនការកែលម្អគួរតែបញ្ជាក់អំពីបញ្ហាប្រភពទឹក ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងការប្រើប្រាស់ទឹកសំខាន់ៗទាំងអស់ក្នុងសហគមន៍ រួមទាំងសាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព ឬស្ថាប័នសាធារណៈដទៃទៀត ឬកន្លែងប្រមូលផ្តុំ។

វាគឺជាការងារសំខាន់ណាស់ ដែលផែនការកែលម្អរបស់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ កំណត់យកបុគ្គលម្នាក់ (ឧទាហរណ៍ ប្រធានភូមិ) ឬស្ថាប័នមួយ (ឧទាហរណ៍

មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព) ទទួលខុសត្រូវចំពោះភារកិច្ច ឬសកម្មភាពនីមួយៗ។ សូមចំណាំថា ការទទួលខុសត្រូវ មិនមែនមានន័យថា បុគ្គលម្នាក់ ឬស្ថាប័ននោះធ្វើសកម្មភាព ឬការអនុវត្តវិធានការការពារទាំងអស់តែឯងទេ ប៉ុន្តែ ការទទួលខុសត្រូវក្នុងការធានាថា សកម្មភាព ឬការអនុវត្តវិធានការការពារទាំងនោះត្រូវបានអនុវត្តន៍ដូចដែលបានព្រមព្រៀងដែរឬទេ?

យើងមានធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តន៍ផែនការកែលម្អរបស់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដែលជាកត្តាសំខាន់ ដើម្បីទទួលបានជោគជ័យ។ វាអាចគិតបញ្ចូលទាំងធនធានថវិកា កម្លាំងពលកម្ម សម្ភារប្រើប្រាស់ និងជំនាញ។ល។ ធនធានទាំងនេះត្រូវបានកំណត់ដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដោយមានជំនួយពីអាជ្ញាធរមូលដ្ឋាន ថ្នាក់ស្រុក ថ្នាក់ខេត្ត និងការគាំទ្រពីដៃគូខាងក្រៅ។

កាលបរិច្ឆេទបញ្ចប់ត្រូវតែកំណត់ឲ្យបានជាក់លាក់តាមដែលអាចធ្វើបាន ដើម្បីងាយស្រួលក្នុងការបញ្ជាក់ពីថ្ងៃបញ្ចប់ ឬការប៉ាន់ស្មានជាចំនួនថ្ងៃ សប្តាហ៍ សម្រាប់សកម្មភាពរយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង និងការប៉ាន់ស្មានជាខែ (ការបញ្ចប់ជា ខែ ឬឆ្នាំ) អាចនឹងគ្រប់គ្រាន់។

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ក៏ត្រូវតែគិតពីសកម្មភាព ០៣ ធំៗ ក្នុងពេលធ្វើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ៖

- **សកម្មភាពរូបវន្ត** (ឧ. ជួសជុលប្រភពទឹក សាងសង់អណ្តូងថ្មី ពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ល។)
- **យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរទម្លាប់** (ឧ. ការផ្សព្វផ្សាយប្រសិទ្ធភាព នៃវិធីសាស្ត្របន្សុទ្ធទឹកតាមគ្រួសារ យុទ្ធនាការបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល ការផ្សព្វផ្សាយអំពីការលាងសំអាតដៃ យុទ្ធនាការសំអាតបរិស្ថាន។ ល។)
- **ដំណើរការ និងរចនាសម្ព័ន្ធការងារ** (ឧ. ការបង្កើតក្រុមការងារផែនការទឹកសុវត្ថិភាពជនបទដែលធន់នឹងអាកាសធាតុ និងអនាម័យនៅតាមសាលារៀន ស្វែងរកដៃគូអភិវឌ្ឍន៍ និងធនធានដើម្បីគាំទ្រដល់ការអនុវត្ត ការត្រួតពិនិត្យ ការតាមដាន និងរាយការណ៍អំពីការរីកចម្រើនទៅរដ្ឋបាលមូលដ្ឋាន ឬការបង្កើត និងការអនុវត្តវិធានការផ្សេងៗនៅសហគមន៍ដែលទាក់ទងទៅនឹងទឹកសុវត្ថិភាព)។

### ៣.៤.៣ សកម្មភាពលើកកម្ពស់ការយល់ដឹង

ផែនការលើកកម្ពស់ការយល់ដឹងត្រូវបានកំណត់ជាផែនការជាក់លាក់ ដើម្បីជំរុញការយល់ដឹងរបស់សហគមន៍ដែលអាចធ្វើក្នុងរូបភាពផ្សេងៗ ទីតាំងផ្សេងៗគ្នា និងតាមដំណាក់កាល នៃដំណើរការអនុវត្តន៍។ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវបានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន សាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព ដើម្បីបង្កើតយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្របតាមតម្រូវការជាក់ស្តែង (**និងកាលកំណត់**) សម្រាប់គ្រួសារ សិស្ស គ្រូ បុគ្គលិកមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព អ្នកជំងឺ និងអ្នកផ្តល់សេវាកម្មផ្គត់ផ្គង់ទឹក។ មន្ទីរអភិវឌ្ឍន៍ជនបទ ឬរដ្ឋបាលឃុំគួរតែផ្តល់នូវសម្ភារអប់រំផ្សព្វផ្សាយដែលពាក់ព័ន្ធទៅនឹងទឹកសុវត្ថិភាព និងពង្រឹងសមត្ថភាពដល់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដើម្បី៖

- ធ្វើតេស្តគុណភាពទឹកផឹក ដោយប្រើឧបករណ៍តេស្តរកវត្តមាន ឬ អវត្តមានមេរោគ (P/A Test)

- ដឹកនាំការពិភាក្សាអំពីវិធីសាស្ត្រការពារជំងឺដែលទាក់ទងទៅនឹងទឹក វិធីសាស្ត្របន្សុទ្ធទឹក និងបច្ចេកទេសស្តុកទឹកឲ្យមានសុវត្ថិភាព
- រៀបចំពិធីអបអរសាទរ ស្តីពីទឹក និងបរិស្ថាន ដូចជា ទិវាទឹកពិភពលោក ទិវាបរិស្ថានជាតិ និងទិវាលើកកម្ពស់អនាម័យជាតិ ឬពិធីផ្សេងៗទៀតដែលទាក់ទងទៅនឹងបញ្ហាទឹក និងអនាម័យ។ល។
- ការខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងត្រូវតែធ្វើជាប្រចាំ ដែលជាផ្នែកមួយ នៃសកម្មភាពរបស់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដូចជា ចុះទៅដល់ខ្នងផ្ទះ រៀបចំប្រជុំសហគមន៍ ឬក្នុងឱកាសផ្សេងៗទៀត។

ជម្រើសផ្សេងទៀត គឺការលើកកម្ពស់ការយល់ដឹងអាចផ្ទេរទៅឲ្យក្រុមការងារដែលទទួលខុសត្រូវជាក់លាក់ ឬបុគ្គលដែលស័ក្តិសម និងមានទឹកចិត្តក្នុងការធ្វើសកម្មភាពសំខាន់ៗទាំងនោះ។ ឧទាហរណ៍ដូចជា៖

- ក្លឹបសិស្ស (ក្រុមមិត្តអប់រំមិត្ត ព្រមទាំងផ្សព្វផ្សាយទៅដល់សហគមន៍)
- ក្រុមអ្នកស្ម័គ្រចិត្តសុខភាពភូមិ
- ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម (ឧ. ពេទ្យសត្វភូមិ....)
- ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ
- អ្នកធ្វើការខាងការងារស្ត្រី កុមារ និងអាហារូបត្ថម្ភ
- គណៈកម្មាធិការសំអាតបរិស្ថានភូមិ
- សហគមន៍ដឹកនាំអនុវត្តន៍កម្មវិធីអនាម័យ

សារ ស្តីពីការលើកកម្ពស់ការយល់ដឹង ត្រូវបានរៀបចំតាមស្ថានភាពការផ្គត់ផ្គង់ទឹកជាក់ស្តែងរបស់ភូមិ (ឬឃុំ) ដែលបានវាយតម្លៃ និងបានកំណត់នៅក្នុងជំហានទី ២ និងទី ៣។ នៅក្នុងជំហានទី ៤ ផែនការកែលម្អរបស់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ មានសកម្មភាពអាទិភាពសម្រាប់ជួយធានានូវសុវត្ថិភាពទឹកសម្រាប់ប្រជាជនទាំងអស់នៅក្នុងសហគមន៍។ ផែនការកែលម្អរបស់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុខ្លះតម្រូវឲ្យមានការផ្លាស់ប្តូររូបវ័ន្ត (ឧ.ការជួសជុលកម្រាលសាបអណ្តូង ឬការសំអាតបរិស្ថានជុំវិញ) ប៉ុន្តែ សកម្មភាពផ្សេងៗទៀត គឺតម្រូវឲ្យមានទាំងការផ្លាស់ប្តូររូបវ័ន្ត និងទម្លាប់។ សកម្មភាពខ្លះទៀតផ្តោតទាំងស្រុងទៅលើការផ្លាស់ប្តូរទម្លាប់។

នៅក្នុងដំណាក់កាល នៃដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ បញ្ហា និងទម្លាប់ដែលត្រូវផ្លាស់ប្តូរ ត្រូវតែច្បាស់លាស់ និងអាចប្រើបានសម្រាប់ការអភិវឌ្ឍកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹង។ ឧទាហរណ៍ ការឆ្លើយតបបញ្ហា ដូចជា៖

- កែប្រែវិធីសាស្ត្រដឹកជញ្ជូនទឹក និងស្តុកទឹកក្នុងផ្ទះឲ្យមានសុវត្ថិភាព
- កាត់បន្ថយការបោះសំណល់រាវ និងរឹងពាសវាលពាសកាល និងលាមកទារក
- ផ្តល់ព័ត៌មានអំពីជម្រើសវិធីសាស្ត្របន្សុទ្ធ និងស្តុកទឹកឲ្យមានសុវត្ថិភាពតាមគ្រួសារ
- បង្កើត និងពង្រឹងក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យឲ្យមានការទទួលខុសត្រូវលើការប្រើប្រាស់ និងថែទាំប្រភពទឹក និងសកម្មភាពច្រើនផ្សេងៗទៀត។

ការផ្លាស់ប្តូរទម្លាប់របស់សហគមន៍ គ្រួសារ និងបុគ្គលដែលទាក់ទងទៅនឹងទឹកសុវត្ថិភាព គឺពិតជាមានភាពស្មុគស្មាញ ហើយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គួរតែត្រូវបានលើកទឹកចិត្តក្នុងការធ្វើការងារនេះ។ ពួកគេមិនគួរមានអារម្មណ៍ថា ជាសម្ពាធ ឬបន្ថែមបន្ទុកដោយសារការងារទាំងនោះ ហើយក្រុមការងារមិនអាចមានអារម្មណ៍បាក់ទឹកចិត្តឡើយ។ ចំណុចសំខាន់ដែលត្រូវផ្តោតគឺគោលដៅ វិធីសាស្ត្រ និងពេលវេលាដែលបានរៀបចំនៅក្នុងផែនការយុទ្ធនាការលើកកម្ពស់ការយល់ដឹងនីមួយៗ។ ជនបង្គោលផែនការសុវត្ថិភាពទឹកឃុំ សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកការងារស្ត្រី និងកុមារ និងមន្ទីរអភិវឌ្ឍន៍ជនបទ ត្រូវតែធ្វើការជាមួយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដើម្បីជួយគាំទ្រដល់ក្រុមដឹកនាំលើកកម្ពស់ការយល់ដឹង រួមមាន៖

- កំណត់ផ្នែកដែលចង់ផ្លាស់ប្តូរទម្លាប់ និងគោលដៅជាក់លាក់ដែលអាចសម្រេចបាន
- ផ្តល់សម្ភារអប់រំ ផ្សព្វផ្សាយដែលចាំបាច់
- បណ្តុះបណ្តាលក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ (និងអ្នកពាក់ព័ន្ធផ្សេងទៀត) អំពីការប្រើប្រាស់សម្ភារ និងជំនាញផ្សេងៗក្នុងការអនុវត្តការផ្លាស់ប្តូរទម្លាប់
- ស្វែងរកការគាំទ្រពីមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព និងភ្នាក់ងារស្ម័គ្រចិត្តសុខភាពភូមិ
- ស្វែងរកការគាំទ្រពីគ្រូបង្រៀន សិស្ស ដែលចាប់អារម្មណ៍ក្នុងការគាំទ្រដល់ការធ្វើសកម្មភាពផ្សព្វផ្សាយនៅក្នុងសហគមន៍
- ស្វែងរកបុគ្គល និងស្ថាប័នដែលមានឥទ្ធិពលនៅក្នុងសហគមន៍ ដូចជា មេដឹកនាំសាសនា ព្រះសង្ឃ លោកអាចារ្យ និងសប្បុរសជន ដើម្បីគាំទ្រដល់យុទ្ធនាការ
- ស្នើសុំការបណ្តុះបណ្តាល និងការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ដូចជា អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ច្រើនពាក់ព័ន្ធទៅនឹងវិធីសាស្ត្រអប់រំ ផ្សព្វផ្សាយ និងការផ្លាស់ប្តូរទម្លាប់លើបញ្ហាទឹក និងអនាម័យ។
- ស្វែងរកអ្នកស្ម័គ្រចិត្តនៅក្នុងសហគមន៍ ដែលមានឆន្ទៈសម្រាប់ធ្វើជាគំរូ ក្នុងការចែករំលែកបទពិសោធន៍ ឬជួយជំរុញគ្រួសារដទៃទៀតក្នុងសហគមន៍របស់គាត់។

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គួរតែទទួលបានការគាំទ្រ ជៀសវាងការប្រើប្រាស់វិធីសាស្ត្រដែលមិនត្រឹមត្រូវ ឬមិនសូវមានប្រសិទ្ធភាព។ ជាធម្មតា ការផ្លាស់ប្តូរទម្លាប់ គឺជាបញ្ហាប្រឈមដែលមនុស្សត្រូវការជំនួយលើការវិភាគស្ថានភាពរបស់ពួកគេ និងការសម្រេចចិត្តដោយខ្លួនគេផ្ទាល់ ដែលការផ្លាស់ប្តូរទម្លាប់របស់ពួកគេ គឺជាអ្វីដែលពួកគេចង់ធ្វើ (មិនមែនដោយសារតែអ្នកផ្សេងប្រាប់ឲ្យធ្វើទេ)។ នេះគឺជាមូលហេតុដែលក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវតែស្វែងរកការគាំទ្រ និងការចូលរួមរបស់អ្នកដទៃទៀតក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដែលជាធម្មតាការផ្លាស់ប្តូរទម្លាប់ វាពិបាកជាងការរំពឹងទុក និងចំណាយពេលច្រើន។

វិធីសាស្ត្រលើកកម្ពស់ការយល់ដឹងមួយចំនួន (ការផ្លាស់ប្តូរទម្លាប់) ដែលមានប្រសិទ្ធភាពសម្រាប់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុក្នុងប្រទេសផ្សេងទៀត រួមមាន៖

- រៀបចំកម្មវិធីលើកទឹកចិត្ត (ឧ.ការប្រកួតប្រជែង និងការផ្តល់រង្វាន់ដល់គ្រួសារដែលបានអនុវត្តន៍ល្អ)
- ផ្តល់សម្ភារអប់រំ ផ្សព្វផ្សាយនៅតាមសាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព និងវត្តអារាម

- រៀបចំយុទ្ធនាការសំអាតបរិស្ថានភូមិ
- រៀបចំកិច្ចប្រជុំពិភាក្សាជាសាធារណៈអំពីសុវត្ថិភាពទឹក ដែលអាចធ្វើរួមជាមួយព្រឹត្តិការណ៍សំខាន់ៗផ្សេងទៀត
- អប់រំ ផ្សព្វផ្សាយដល់កុមារ ដើម្បីឲ្យកុមារអប់រំបន្តនៅតាមសាលារៀន និងនៅតាមសហគមន៍
- រៀបចំកម្មវិធីកម្សាន្តពេលល្ងាចដែលមានចម្រៀងទាក់ទងទៅនឹងសុវត្ថិភាពទឹក លេងល្ខោន បញ្ចាំងវីដេអូ ឬឈុតកំប្លែងខ្លីៗ

ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតឯកសារ និងសម្ភារអប់រំ ផ្សព្វផ្សាយ និងយុទ្ធសាស្ត្រជាតិ ស្តីពីការផ្លាស់ប្តូរឥរិយាបថ ដែលក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ និងឃុំអាចយកពីមន្ទីរអភិវឌ្ឍន៍ជនបទសម្រាប់ប្រើប្រាស់ក្នុងពេលធ្វើយុទ្ធនាការ។ ដូចគ្នាដែរ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ អាចច្នៃប្រឌិតវិធីសាស្ត្រ និងដំណោះស្រាយផ្ទាល់ខ្លួនតាមដែលអាចធ្វើបាន។ អ្វីដែលសំខាន់បំផុត គឺត្រូវតែចងក្រងឯកសារពីអ្វីដែលអាចធ្វើបាន និងពីអ្វីដែលធ្វើមិនបាន ដែលជាផ្នែកមួយ នៃដំណើរការរៀនសូត្រ។

ជាចុងក្រោយ រដ្ឋបាលឃុំ មន្ទីរអភិវឌ្ឍន៍ជនបទ និងអង្គការ ដៃគូអភិវឌ្ឍន៍ គួរតែជួយក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ កត់ត្រា និងចែករំលែកបទពិសោធន៍របស់ពួកគេអំពីការលើកកម្ពស់ការយល់ដឹង (ទាំងល្អ ទាំងមិនល្អ) ជាមួយភូមិ (ឬសហគមន៍) ផ្សេងៗទៀតដែលជាផ្នែកមួយ នៃដំណើរការរៀនសូត្រ។ ការធ្វើបែបនេះ ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិនឹង “ **រៀនពីខ្លួនឯងផ្ទាល់ផង** ” និងអាចបន្តធ្វើឲ្យប្រសើរឡើងផង។

## ៣.៥ ជំហានទី ៥ ៖ ការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាព និងការទំនាក់ទំនង នៃលទ្ធផល

### ៣.៥.១ សេចក្តីផ្តើម

ការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាពត្រូវបានដាក់បញ្ចូលចាប់ពីពេលចាប់ផ្តើមធ្វើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។ គោលបំណងសំខាន់ នៃការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាព គឺដើម្បីផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ថាតើមានការរីកចម្រើនបានកម្រិតណា ហើយថាតើនឹងអាចឈានដល់ចំណុចដៅដែលបានកំណត់ (ឬលើសពីចំណុចដៅ) ដែរឬទេ។

គោលបំណងសំខាន់ផ្សេងៗទៀត នៃការត្រួតពិនិត្យ ការតាមដានវឌ្ឍនភាព គឺដើម្បីឲ្យក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ អាចធ្វើការទំនាក់ទំនងល្អជាមួយសហគមន៍ រាជរដ្ឋាភិបាល និងអង្គការ ដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ ឬដែលបានគាំទ្រ។

សម្រាប់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ ការត្រួតពិនិត្យ ការតាមដាននឹងផ្តល់នូវចម្លើយពីរគឺ៖

- តើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបានអនុវត្តន៍ត្រឹមត្រូវដែរឬទេ?

- តើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុសម្រេចបានតាមលទ្ធផលដែលចង់បានដែរឬទេ ?

ការត្រួតពិនិត្យ ការតាមដានទាមទារនូវសូចនាករ មធ្យោបាយ នៃការវាស់វែង និងវិធីសាស្ត្រ នៃការកត់ត្រាលទ្ធផល។ កម្មវិធីត្រួតពិនិត្យ តាមដានដែលមានប្រសិទ្ធភាព រួមមានដូចខាងក្រោម៖

- តើ ត្រូវត្រួតពិនិត្យ តាមដាន *អ្វី* ?
- តើ ត្រូវត្រួតពិនិត្យ តាមដាន *កន្លែងណា* ?
- តើ ត្រូវត្រួតពិនិត្យ តាមដានដោយ *អ្នកណា* ?
- តើ ត្រូវត្រួតពិនិត្យ តាមដាន*ពេលណា ហើយ ប៉ុន្មានដង* ?
- តើ ត្រូវកត់ត្រា និងទំនាក់ទំនងលទ្ធផល *បែបណា*? ហើយតើត្រូវដោះស្រាយនូវបញ្ហាដែលបានរកឃើញ *បែបណា* ?

### ៣.៥.២ វិធីសាស្ត្រ នៃការត្រួតពិនិត្យ ការតាមដាន

ផែនការកែលម្អ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺជាចំនុចសំខាន់សម្រាប់ត្រួតពិនិត្យ តាមដាន។ រាល់ផ្នែកនីមួយៗ នៃផែនការកែលម្អ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវតែមានសកម្មភាពការងារ ពេលវេលាកំណត់ និងអ្នកទទួលខុសត្រូវ។ សមាសភាពចំនួនបី (០៣) សំខាន់ៗក្នុងផែនការកែលម្អដែលត្រូវតែត្រួតពិនិត្យ តាមដាន រួមមាន៖

- សកម្មភាពរូបវន្ត
- ការផ្លាស់ប្តូរទម្លាប់ និងការលើកកម្ពស់ការយល់ដឹង
- ដំណើរការ និងរចនាសម្ព័ន្ធការងារ

ប្រធានក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ឬអ្នកទទួលបន្ទុកត្រូវតែធ្វើការសង្កេតជាទៀងទាត់ (ពិនិត្យជាក់ស្តែងនៅនឹងកន្លែង) អំពីការរីកចម្រើន នៃផែនការកែលម្អនេះ។ ឧទាហរណ៍ ការកំណត់ថាតើបានសាងសង់របងការពារអណ្តូង ការអនុវត្តការយកទឹករបស់គ្រួសារ និងបច្ចេកទេសបន្សុទ្ធទឹកមានការប្រសើរជាងមុនដែរឬទេ ?

រដ្ឋបាលឃុំ និងមន្ទីរអភិវឌ្ឍន៍ជនបទ ត្រូវតែធ្វើការគាំទ្រដោយចុះទៅពិនិត្យតាមកាលកំណត់ (រួមជាមួយនឹងការធ្វើតេស្តគុណភាពទឹក និងការត្រួតពិនិត្យ ការតាមដានអនាម័យ) ដើម្បីបញ្ជាក់ថាតើគោលដៅផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ អាចសម្រេចបានដែរឬទេ។

### ៣.៥.៣ ការទំនាក់ទំនង នៃលទ្ធផល

ទិន្នន័យបានពីការត្រួតពិនិត្យ ការតាមដាន ស្តីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវបានចងក្រងជាឯកសារ និងត្រូវតែរក្សាទុកដោយប្រុងប្រយ័ត្ននៅថ្នាក់ភូមិ និងឃុំ។ ដើម្បីឲ្យមានប្រសិទ្ធភាព របាយការណ៍ នៃការត្រួតពិនិត្យ ការតាមដាន (ទិន្នន័យ ឬរបាយការណ៍សង្ខេបណាមួយ) ត្រូវតែចែកជូនដល់ក្រុមប្រឹក្សាឃុំ និងមន្ទីរអភិវឌ្ឍន៍ជនបទក្នុងពេលប្រជុំប្រចាំខែ ឬប្រចាំត្រីមាស និងនៅពេលប្រជុំដាច់ដោយឡែកអំពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។ នាយក នាយិកាសាលាបឋមសិក្សា និងប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពជាសមាជិកសំខាន់ គឺដោយសារស្ថាប័នរបស់ពួកគេជាទូទៅមានហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតផ្ទាល់ខ្លួន (ឧ. អណ្តូង ឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និង

ឧបករណ៍ស្តុកទឹកផ្សេងៗទៀត) ហើយការរក្សាការផ្តល់សេវាទឹកប្រកបដោយសុវត្ថិភាពក្នុងស្ថាប័នទាំងពីរនេះ គឺមានសារៈសំខាន់ណាស់។

កិច្ចប្រជុំ ស្តីពីផែនការសុវត្ថិភាពទឹកជនបទនៅថ្នាក់ឃុំ អាចជាមធ្យោបាយដ៏ល្អបំផុតក្នុងការជានានូវការចែករំលែកព័ត៌មាន។ ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំត្រូវតែរៀបចំកិច្ចប្រជុំមួយ ឬច្រើនជារៀងរាល់ឆ្នាំជាមួយក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ (ឬប្រជុំមួយរួមគ្នាទាំងអស់) ដើម្បីពិភាក្សាអំពីលទ្ធផល នៃការរីកចម្រើន បញ្ហាប្រឈម ឬឧបសគ្គណាមួយដែលក្រុមកំពុងជួបប្រទះ។ ការកំណត់កិច្ចប្រជុំនៅថ្នាក់ឃុំអាចនឹងជួយជំរុញឲ្យមានការតាមដាន និងប្រមូលទិន្នន័យនៅថ្នាក់ភូមិបានទៀងទាត់។ មន្ទីរអភិវឌ្ឍន៍ជនបទគួរតែត្រូវបានអញ្ជើញឲ្យចូលរួមកិច្ចប្រជុំទាំងនេះ អាចជាប្រជុំប្រចាំត្រីមាស (ឬយ៉ាងហោចណាស់ប្រចាំឆមាស)។

ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ/ឃុំ ត្រូវតែផ្តល់ព័ត៌មានអំពីការរីកចម្រើនដល់សមាជិកក្នុងសហគមន៍ តាមរយៈការប្រជុំភូមិ/ឃុំ ហើយគួរតែផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់សំណួរ និងចម្លើយ។ ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ/ឃុំ អាចកំណត់រយៈពេលសមរម្យក្នុងការរៀបចំកិច្ចប្រជុំទាំងនេះ ដែលអាចធ្វើប្រចាំឆមាស។ ការពិភាក្សា និងប្រជុំក្រៅផ្លូវការជាមួយសមាជិកសហគមន៍ និងស្ថាប័ននានាក្នុងសហគមន៍អាចធ្វើញឹកញាប់ជាងនេះ។

## ៣.៦ ជំហានទី ៦ ៖ ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព នៃផែនការកែលម្អ

ការត្រួតពិនិត្យ ការតាមដានជាទៀងទាត់ទៅលើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងបទពិសោធន៍ពីការអនុវត្តការងាររបស់ក្រុមផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺមានសារៈសំខាន់ណាស់ ពីព្រោះ សហគមន៍ និងបរិស្ថានតែងតែមានការផ្លាស់ប្តូរ។ កំណើនប្រជាជន ឬចំណាកស្រុក ការប្រើប្រាស់ដីធ្លី និងការប្រែប្រួល នៃការរស់នៅក្នុងពេលមានគ្រោះមហន្តរាយ ឬគ្រោះមហន្តរាយផ្សេងៗ ការផ្លាស់ប្តូរបច្ចេកវិទ្យាទឹក ការសំអាត និងអនាម័យ ការផ្លាស់ប្តូរនីតិវិធី និងគោលនយោបាយរដ្ឋបាលមូលដ្ឋាន និងស្ថានភាពដទៃទៀត អាចនឹងមានផលប៉ះពាល់ដល់ស្ថានភាពសុវត្ថិភាពទឹកក្នុងតំបន់។

លើសពីនេះទៀត ការពិនិត្យឡើងវិញអំពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺមានសារៈសំខាន់ណាស់ក្នុងការជួយលើកកម្ពស់ការយល់ដឹង ការសម្របសម្រួលជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា និងការកៀរគរធនធាន។

ផែនការសុវត្ថិភាពទឹកភូមិ និងឃុំ ត្រូវបានបង្កើតកាលវិភាគមួយសម្រាប់ពិនិត្យឡើងវិញជាទៀងទាត់ដោយផ្អែកទៅលើលក្ខខណ្ឌ និងតម្រូវការមូលដ្ឋាន។ ក៏ដូចគ្នាដែរ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវតែរៀបចំការត្រួតពិនិត្យម្តងម្កាល “ **តាមកាលៈទេសៈ** ” ដូចខាងក្រោម៖

- **ត្រួតពិនិត្យជាបន្ទាន់** ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ និងឃុំ ត្រូវតែប្រជុំជាបន្ទាន់ ប្រសិនបើមានការផ្លាស់ប្តូរ ឬមានបញ្ហាមិនល្អកើតឡើង (ឧ. ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចមួយមិនដំណើរការនៅក្នុងសហគមន៍ សាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព) ដែលតម្រូវឲ្យចាត់វិធានការកែលម្អបន្ទាន់។

- **ត្រួតពិនិត្យប្រចាំឆ្នាំ** កំណត់ពេលវេលាជាមុន ជាពិសេស មុនពេលរៀបចំផែនការវិនិយោគឃុំ សម្រាប់ពេលណាមួយសមស្រប នៃឆ្នាំ ។ ការត្រួតពិនិត្យ ការតាមដានប្រចាំឆ្នាំ ត្រូវបានវាយតម្លៃ អំពីភាពជោគជ័យ និងបញ្ហាប្រឈម និងមេរៀនបទពិសោធន៍អំពីសកម្មភាពដែលបានអនុវត្តន៍ឆ្នាំមុន។ ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពតាមដែលបានរកឃើញ ហើយអនុម័តឡើងវិញ ក្នុងកិច្ចប្រជុំក្រុមផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។
- **ត្រួតពិនិត្យតាមជាក់ស្តែង** ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ និងឃុំអាចធ្វើការត្រួតពិនិត្យអំពីវឌ្ឍនភាពសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ ក្នុងពេលមានទស្សនកិច្ចរបស់គណៈប្រតិភូក្រសួងអភិវឌ្ឍន៍ជនបទ ឬប្រតិភូដៃគូអភិវឌ្ឍន៍ ឬសម្រាប់ហេតុផលផ្សេងៗទៀត។ ការត្រួតពិនិត្យបែបនេះ ក៏អាចធ្វើបានសម្រាប់ការកៀគរប្រេកពជនជាន (ឧ.ការរៀបចំសំណើថវិកា ឬសម្រាប់ដំណើរការវិនិយោគឃុំ ស្រុក)។

ការកែសម្រួលផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវបានធ្វើប្រចាំឆ្នាំ ដោយយោងតាមកាលវិភាគត្រួតពិនិត្យ តាមដាន។ ទោះបីជាយ៉ាងណាក៏ដោយ កាលវិភាគនេះត្រូវតែធ្វើតាមតម្រូវការក្នុងមូលដ្ឋាន។ នៅ " **ជំហានទី ៦** " ដំណើរការត្រួតពិនិត្យ តាមដាន និងការកែសម្រួលឡើងវិញ គួរតែធ្វើតាមជំហានទី ៥។ ដូច្នេះ ប្រសិនបើ មានការយឺតយ៉ាវ នៃវឌ្ឍនភាពនោះ ការត្រួតពិនិត្យ ការតាមដានប្រចាំឆ្នាំគួរតែផ្តោតទៅលើការកំណត់រកបញ្ហា និងការប្រឈម និងស្វែងរកដំណោះស្រាយសមស្រប ដែលអាចធ្វើបាន ដើម្បីពន្លឿនការរីកចម្រើនរបស់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។

ការធ្វើបច្ចុប្បន្នភាព និងការអនុម័តឡើងវិញ នៃការបញ្ចប់វដ្តជំហានទី ៦ របស់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបានបង្ហាញក្នុង**រូបភាពទី ២**។

ជំហានបន្ទាប់អាចធ្វើលឿនជាង ដូចជា ការផ្តោតទៅលើជុំទីពីរ នៃវដ្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដែលនឹងផ្តោតទៅលើ៖

- ធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ បើចាំបាច់ (**ជំហានទី ១**)
- បញ្ចូលការផ្លាស់ប្តូរស្ថានភាពទឹកប្រើប្រាស់ក្នុងភូមិ (ឬឃុំ) និងកែសម្រួលផែនទី(**ជំហានទី ២**)
- ចុះត្រួតពិនិត្យតាមផ្ទះ និងធ្វើតេស្តគុណភាពទឹក (**ជំហានទី ៣**)
- កែសម្រួលផែនការអនុវត្តដោយយោងទៅតាមព័ត៌មានថ្មី ព្រមទាំងសមិទ្ធផល បញ្ហាប្រឈម និងបទពិសោធន៍ពីឆ្នាំមុន (**ជំហានទី ៤**)
- យកបទពិសោធន៍ពីមុន ព័ត៌មានថ្មី និងព័ត៌មានផ្សេងៗពីជំហានខាងលើ បន្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ការកែសម្រួល និងការពង្រីកសកម្មភាព។

## ៤. ការផ្ទៀងផ្ទាត់ឡើងវិញ និងការទទួលស្គាល់

វិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ នៅតាមមូលដ្ឋាន (ភូមិ និងឃុំ) នឹងទទួលបានលទ្ធផលល្អដោយមានការកំណត់គោលដៅច្បាស់លាស់ មានដំណើរការផ្ទៀងផ្ទាត់ឡើងវិញ មានការទទួល

ស្គាល់ដើម្បីជានាតម្លាភាព និងការលើកទឹកចិត្តដល់សហគមន៍ និងគ្រួសារ។ សម្រាប់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គេផ្តល់អនុសាសន៍ថា ការវាស់វែង និងការទទួលស្គាល់ គួរតែធ្វើឡើងតាមកម្រិតលទ្ធផលកំណត់ដូចខាងក្រោម៖

- ប្រភពទឹកផឹករបស់សហគមន៍មិនមានបាក់តេរី/មេរោគ និងសារធាតុគីមីដែលបង្កឲ្យមានផលប៉ះពាល់ដល់សុខភាព។
- ការយកទឹក ការស្តុកទឹក និងទឹកផឹកមិនមានការចម្លងបាក់តេរី/មេរោគឡើងវិញ។
- គុណភាពទឹកផឹកស្របតាមគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ។ វាមានការប្រើប្រាស់វិធីសាស្ត្របន្សុទ្ធទឹកត្រឹមត្រូវ និងមានប្រសិទ្ធភាព ក្នុងករណីចាំបាច់។
- សហគមន៍មានបរិស្ថានស្អាត (សំណល់រាវ និងរឹងត្រូវបានគ្រប់គ្រងប្រកបដោយអនាម័យល្អ)
- ប្រភពទឹក គឺមានភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

លើសពីនេះទៀត ភូមិ ឬឃុំនៅតំបន់ជនបទនឹងទទួលបានការផ្គត់ផ្គង់ទឹក ដែលមានការកែលម្អប្រកបដោយសមធម៌ និងចីរភាព គឺនៅពេលដែលបានអនុវត្តន៍ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។ សេចក្តីពឹងទុកចុងក្រោយ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺ " ***ប្រជាជនទាំងអស់ទទួលបានសេវាផ្គត់ផ្គង់ទឹកដែលមានការកែលម្អ*** " ពោលគឺទឹកផឹកមានសុវត្ថិភាព រួមទាំងប្រភពទឹកមានភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុផងដែរ។ វាគឺជាការចាំបាច់ណាស់ក្នុងការកំណត់ជំហាន និងគោលដៅសម្រាប់ការវាស់វែងជាមួយប្រព័ន្ធទទួលស្គាល់ពីវឌ្ឍនភាពឆ្ពោះទៅរកគោលដៅចុងក្រោយ។ ដូច្នេះ គោលការណ៍ណែនាំនេះក៏បានណែនាំ **ការទទួលស្គាល់ចំនួន ០៥ កម្រិត** ដើម្បីជួយដល់ការត្រួតពិនិត្យ តាមដាន និងវាស់វែងវឌ្ឍនភាព នៃការអនុវត្តផែនការសុវត្ថិភាពទឹកភូមិ និងឃុំដែលមានដូចខាងក្រោម៖

**កម្រិតទី ១ (កែវថ្លា)**

- ដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបានចាប់ផ្តើម ហើយក្រុមការងារផែនការសុវត្ថិភាពទឹកភូមិ ឬឃុំ បានបង្កើតឡើង (**ជំហានទី ១**)។
- ការគូសផែនទី និងការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ បានបញ្ចប់ (**ជំហានទី ២**) ។
- ការវាយតម្លៃគ្រោះថ្នាក់ ជាមួយនឹងការកំណត់វិធានការការពារបានបញ្ចប់ (**ជំហានទី ៣**)។
- យុទ្ធនាការផ្សព្វផ្សាយនៅក្នុងសហគមន៍បានចាប់ផ្តើម (**ជំហានទី ៤**) ។

**កម្រិតទី ២ (កែវពណ៌ខៀវ)**

- ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុជំហានទី ៤ (**ផែនការកែលម្អ**) បានបញ្ចប់ជាមួយនឹងឯកសារផែនការដាក់ជូនក្រុមប្រឹក្សាឃុំ (**សម្រាប់ផែនការភូមិ**) ឬរដ្ឋបាលថ្នាក់ស្រុក (**សម្រាប់ផែនការឃុំ**)។
- ក្រុមប្រឹក្សាឃុំ (**ឬរដ្ឋបាលថ្នាក់ស្រុក**) ទទួលស្គាល់ និងគាំទ្រផែនការកែលម្អ។
- ឃុំ ឬស្រុក និងអ្នកគាំទ្រផ្សេងៗទៀតវិភាជន៍ថវិកាដល់ភូមិ ឬឃុំ ដើម្បីអនុវត្តន៍ការងារកែលម្អ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីទឹកសុវត្ថិភាព។

**កម្រិតទី ៣ (កែវពណ៌ប្រាក់)**

- សម្រេចបានលទ្ធផលកម្រិតទី ១ និងទី ២ ខាងលើ។
- ភូមិ ឬឃុំ រៀបចំចងក្រងឯកសារផែនការដើម្បីសម្រេចឲ្យបានការផ្គត់ផ្គង់ទឹក ដែលមានការកែលម្អ ១០០% ប្រកបដោយបរិយាបន្ន និងចីរភាព ។
- វឌ្ឍនភាពនៅតែបន្តនៅថ្នាក់ភូមិ ឬឃុំ និងជំហានទី ៥ (ការត្រួតពិនិត្យ តាមដាន និងការទំនាក់ទំនងលទ្ធផល) គឺដំណើរការល្អ។

**កម្រិតទី ៤ (កែវពណ៌មាស)**

- សម្រេចបានលទ្ធផលកម្រិតទី ៣ ខាងលើ
- វឌ្ឍនភាពនៅតែបន្ត ហើយជំហានទី ៦ (ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ) បានអនុវត្តន៍ជាបន្តបន្ទាប់។
- វឌ្ឍនភាពនៅតែបន្តឆ្ពោះទៅរកការសម្រេចបានការផ្គត់ផ្គង់ទឹកមានការកែលម្អទៅដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ ឬឃុំ។

**កម្រិតទី ៥ (កែវពណ៌ពេជ្រ)**

- សម្រេចបានលទ្ធផលកម្រិតទី ៤ ខាងលើ។
- សម្រេចបាន ១០០% នៃការផ្គត់ផ្គង់ទឹកមានការកែលម្អទៅដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ ឬឃុំ។
- ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ហើយដំណើរការត្រួតពិនិត្យ តាមដាន (និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង) គឺនៅតែបន្តអនុវត្តន៍យ៉ាងសកម្ម។

ដំណើរការផ្ទៀងផ្ទាត់ និងវាយតម្លៃការអនុវត្តផែនការសុវត្ថិភាពទឹកភូមិ ឬឃុំ គួរតែរៀបចំ និងអនុវត្តដោយមន្ត្រីថ្នាក់ស្រុកទទួលបន្ទុកការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ និងមានការគាំទ្រផ្នែកបច្ចេកទេសដោយមន្ទីរអភិវឌ្ឍន៍ជនបទ។

ប្រសិនបើ ការផ្ទៀងផ្ទាត់ និងការវាយតម្លៃការអនុវត្តផែនការសុវត្ថិភាពទឹកភូមិ ឬឃុំ ទទួលបានលទ្ធផលកម្រិតទី ៥ (**កែវពណ៌ពេជ្រ**) នោះថ្នាក់ស្រុកអាចផ្តល់ដំណឹងដល់ភូមិ ឬឃុំ ដើម្បីរៀបចំ និងធ្វើការផ្ទៀងផ្ទាត់មួយកម្រិតទៀត ដោយប្រើប្រាស់ប្រូតូកូលសម្រាប់ការផ្ទៀងផ្ទាត់ និងបញ្ជាក់សុពលភាពសហគមន៍ទឹកសុវត្ថិភាព ដើម្បីប្រកាសជា **សហគមន៍ទឹកសុវត្ថិភាព** ។

ការទទួលស្គាល់ការសម្រេចបាន “ **សហគមន៍ទឹកសុវត្ថិភាព** ” ត្រូវតែផ្សព្វផ្សាយជាសាធារណៈតាមរយៈការប្រារព្ធពិធីទទួលស្គាល់ក្នុងមូលដ្ឋាន និងតាមប្រព័ន្ធផ្សព្វផ្សាយជាតិ និងប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ដើម្បីលើកទឹកចិត្តពីការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុនេះ។ ស្លាកសញ្ញា ឬបដាទទួលស្គាល់ “ **សហគមន៍ទឹកសុវត្ថិភាព** ” គួរតែដាក់នៅថ្នាក់ភូមិ ឬឃុំ។

## ៥. ថវិកាសម្រាប់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

ដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ គឺជាឧបករណ៍វិភាគ និងធ្វើផែនការ។ ដើម្បីធ្វើការងារនេះបាន វាទាមទារឲ្យមានការចំណាយពេលវេលារបស់សមាជិកក្រុមការងារថ្នាក់ឃុំ និងថ្នាក់ខេត្តក្នុងការគាំទ្រ តាមដាន និងកសាងសមត្ថភាព។ ដូចគ្នាដែរ ដំណើរការនេះទាមទារឲ្យមានធនធានថវិកាមួយចំនួនសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល ផលិត និងចែកចាយសម្ភារអប់រំផ្សព្វផ្សាយ ការប្រជុំ និងអាហារសម្រន់ សម្ភារការិយាល័យ និងចំណាយផ្សេងៗទៀត។ ប្រសិនបើ គ្មានធនធានថវិកាជាមូលដ្ឋានទាំងនេះទេ ភូមិ ឬឃុំមិនអាចរៀបចំផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុប្រកបដោយនិរន្តរភាពបានទេ។ ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបានកំណត់ជាអាទិភាពមួយនៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ២ (២០១៩ - ២០២៣) ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ដោយបានកំណត់គោលដៅ ៥០០ ឃុំ នៅឆ្នាំ ២០២៣។ ឃុំមួយមានភូមិចំនួន ១០ ជាមធ្យម ហើយភូមិនីមួយៗនឹងមានផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុរបស់ខ្លួន។ ដូច្នេះ ភូមិប្រហែល ៥.០០០ នឹងត្រូវធ្វើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ នៅត្រឹមឆ្នាំ ២០២៣ និងបន្តធ្វើរហូតដល់គ្រប់ភូមិទាំងអស់។

ចំនួនថវិកាដែលត្រូវការ ដើម្បីបង្កើតផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុចំនួន ១០០ ឃុំ (ប្រហែល ១.០០០ ភូមិ) គឺមិនទាន់អាចធ្វើការប៉ាន់ប្រមាណនៅឡើយទេ។ ថវិកាប្រហែល ១.០០០ ដុល្លាអាមេរិក ត្រូវបានសន្មត់នៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ២ (២០១៩-២០២៣) សម្រាប់ការធ្វើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុក្នុងមួយឃុំ ។ តួលេខនេះ គឺបានពីការពិភាក្សាមិនផ្លូវការពីការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុសាកល្បងនៅខេត្តព្រៃវែង និងកំពង់ស្ពឺ។ ការប៉ាន់ស្មានតួលេខនេះ អាចទាប ឬខ្ពស់ជាងតម្រូវការជាក់ស្តែង ដោយផ្អែកទៅលើស្ថានភាព និងទីតាំងភូមិសាស្ត្ររបស់ភូមិ/ឃុំ។

ដើម្បីធានាថាមានធនធានថវិកាគ្រប់គ្រាន់ សម្រាប់ការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មន្ត្រីរដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំ ត្រូវតែដាក់ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបញ្ចូលទៅក្នុងផែនការថវិការបស់មន្ទីរ និងស្រុក និងផែនការវិនិយោគឃុំ។

ដំណើរការផែនការសកម្មភាពជាតិ និងផែនការសកម្មភាពខេត្ត ត្រូវតែមានការសម្របសម្រួលដោយរាជរដ្ឋាភិបាល និងអង្គការ ដៃគូអភិវឌ្ឍន៍។ គម្រោងសាកល្បងផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ បានរកឃើញថា រដ្ឋបាលមូលដ្ឋាន និងថ្នាក់ខេត្ត (ឧ. ក្រុមប្រឹក្សាឃុំ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត) អាចជំរុញការចូលរួមពីវិស័យឯកជន ដើម្បីចូលរួមផ្តល់ហិរញ្ញវត្ថុដល់ការលើកកម្ពស់សុវត្ថិភាពទឹកផឹកនៅសហគមន៍ សាលារៀន និងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងស្ថាប័នសាធារណៈដទៃទៀត (ឧ.សាលារៀន និងមណ្ឌលសុខភាព) អាចដើរតួនាទីសំខាន់ក្នុងការស្វែងរកការគាំទ្រឲ្យមានការវិនិយោគក្នុងមូលដ្ឋានកាន់តែច្រើន នៅក្នុងវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ និងជួយសម្រួលដល់ការវិនិយោគពីប្រភពហិរញ្ញប្បទានផ្សេងៗ

ទៀត។ សក្តានុពល នៃប្រភពធនធានសម្រាប់គាំទ្រផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ រួមមាន៖

- បណ្តាមន្ទីរខេត្តនានា (សម្រាប់មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព និងសាលារៀន)
- ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទខេត្ត
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- រដ្ឋបាលថ្នាក់ស្រុក (ផែ្នកកម្មវិធីវិនិយោគស្រុក)
- ក្រុមប្រឹក្សាឃុំ (ផែ្នកកម្មវិធីវិនិយោគឃុំ)
- ធនធាននានានៅសហគមន៍ (ឧ. វត្តអារាម បដិភាគពីគ្រួសារ ។ល។)
- អង្គការ ដៃគូអភិវឌ្ឍន៍នានា (ឧ.អង្គការក្នុងស្រុក និងក្រៅស្រុក)

បច្ចុប្បន្ននេះ វាមិនមាន " **ផែនការ** " ឬផែនការជាសកលដើម្បីជានាធនធានថវិកាគ្រប់គ្រាន់សម្រាប់ការងារលើកកម្ពស់សុវត្ថិភាពទឹកនៅថ្នាក់មូលដ្ឋានឡើយ។ ធនធានថវិកាជាតិសម្រាប់វិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ កន្លងមកផ្តោតច្រើនតែទៅលើហេដ្ឋារចនាសម្ព័ន្ធ។

សរុបមក គោលការណ៍ណែនាំនេះបានផ្តល់អនុសាសន៍ឲ្យមានការចលនាធនធានថវិកាក្នុងដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ចាប់ពីពេលចាប់ផ្តើម និងចាប់ពីគ្រប់កម្រិតទាំងអស់ (ខេត្ត ដល់ភូមិ)។ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ជាមួយនឹងការគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ត្រូវតែមានផែនការកៀរគរប្រភពធនធាននៅគ្រប់ឱកាសទាំងអស់តាមដែលអាចធ្វើទៅបាន។ នេះរួមបញ្ចូលទាំងការគាំទ្រឲ្យបានខ្លាំងក្លាពីសំណាក់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្នុងការចលនា និងបែងចែកធនធានជាតិ និងធនធានពីអង្គការ ដៃគូអភិវឌ្ឍន៍ ទៅតំបន់ និងប្រជាជនដែលត្រូវការការគាំទ្របំផុត ក៏ដូចគ្នានឹងការជួយដល់ស្រុក និងឃុំ ក្នុងការកៀរគរប្រភពធនធាន។ ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ នៃរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ (ជនបង្គោលការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ) ដើរតួនាទីយ៉ាងខ្លាំងក្នុងការខិតខំប្រឹងប្រែងកៀរគរធនធាន។

# ៦. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ក. គំរូសៀវភៅផែនការសុវត្ថិភាពទឹកថ្នាក់ឃុំ

### ផែនការសុវត្ថិភាពទឹកឃុំដែលធន់នឹងអាកាសធាតុ




| | |
|---|---|
| ឃុំ | |
| ស្រុក | |
| ខេត្ត | |
| ចំនួនភូមិ | |
| ចំនួនសាលារៀន | |
| ចំនួនវត្ត | |
| ចំនួនមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព | |
| ចំនួនគ្រួសារ | |
| ចំនួនប្រជាជន | |
| កាលបរិច្ឆេទ នៃការធ្វើផែនការ | |
| រយៈពេល នៃការធ្វើផែនការ | |

## ជំហានទាំង ៦ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ




**រូបភាពទី ១៖ ជំហានទាំង ៦ នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ**

## ជំហានទី ១ ៖ ការចូលរួមរបស់សហគមន៍ និងការបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

សមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុចុះហត្ថលេខាលើតារាងបន្ទាប់ពីបានយល់គ្រប់ជំហានទាំងអស់របស់ផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុ និងភារកិច្ចរបស់ខ្លួនចំពោះផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។

**តារាង ១.១ ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ**

| ល.រ | ឈ្មោះសមាជិកក្រុមផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ | តួនាទី និងភារកិច្ច | តួនាទី និងភារកិច្ចសមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ | លេខទូរស័ព្ទ | ហត្ថលេខាទទួលយកភារកិច្ច |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ ២០២

**មេឃុំ**

## ភារកិច្ចរបស់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ:

- បំពេញតារាងក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។
- គូសផែនទីឃុំ បង្ហាញអំពីប្រភពទឹក និងស្វែងយល់អំពីព័ត៌មានផ្សេងៗដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទឹក រួមទាំងបញ្ហានានាដែលទាក់ទងទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។
- កំណត់មុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមានដល់ទឹក ចាប់ពីប្រភពទឹករហូតដល់ទឹកផឹក រួមបញ្ចូលបញ្ហានានាដែលអាចកើតឡើងដោយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ
- ធ្វើផែនការកំណត់អាទិភាព និងដឹកនាំសកម្មភាពកែលម្អគ្រប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងសហគមន៍។
- ធ្វើផែនការ និងដឹកនាំសកម្មភាពលើកកម្ពស់ការយល់ដឹងតាមភូមិដល់គ្រួសារអំពីការអនុវត្តត្រឹមត្រូវក្នុងការរក្សាទឹកប្រើប្រាស់ឲ្យមានសុវត្ថិភាព។
- ធ្វើផែនការ និងដឹកនាំការតាមដានវឌ្ឍនភាព នៃផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ រួមមាន ការត្រួតពិនិត្យ ការតាមដានគុណភាពទឹកក្នុងសហគមន៍ និងតាមគ្រួសារ និងចែករំលែកព័ត៌មាន។
- រៀបចំ និងលើកផែនការសម្រាប់មន្ទីរអភិវឌ្ឍន៍ជនបទដែលធន់នឹងអាកាសធាតុ ឬអាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធ ចុះតាមភូមិដើម្បីជួយពិនិត្យថាតើការអនុវត្តផែនការសុវត្ថិភាពទឹកបានត្រឹមត្រូវ និងមានប្រសិទ្ធភាពឬទេ?
- ប្រជុំពិនិត្យឡើងវិញលើវឌ្ឍនភាពសកម្មភាពផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ និងពិភាក្សាគ្នាថាតើការអនុវត្តបានតាមផែនការកំណត់ឬទេ? ធ្វើបច្ចុប្បន្នភាព ឬកែសម្រួល (ប្រសិនបើចាំបាច់) ដើម្បីជួយឲ្យប្រសើរឡើងនូវការអនុវត្ត ហើយអាចសម្រេចបានតាមគោលដៅកំណត់។
- រៀបចំផែនការថវិកា ធ្វើការកៀរគរ ឬស្នើសុំវិភាជន៍ថវិកា (ឃុំ ស្រុក និងខេត្ត) សម្រាប់ការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ។

***សមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុឯកភាពទៅលើការជួបប្រជុំជារៀងរាល់_____ ខែ។***

***(ការប្រជុំគួរតែធ្វើឡើងយ៉ាងហោចណាស់ ៤ ដងក្នុងមួយឆ្នាំដើម្បីឲ្យផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុមានដំណើរការ)***

## សំនួរគន្លឹះសម្រាប់ពិភាក្សាក្នុងកិច្ចប្រជុំរបស់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ

- ☐ តើកិច្ចប្រជុំក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុបានអនុវត្តតាមកាលវិភាគដែរឬទេ?
- ☐ តើឃុំមានរៀបចំផែនការ និងកៀគរថវិកាលើការងារទឹកស្អាត និងអនាម័យដែរឬទេ?
- ☐ តើផែនទីដែលបង្ហាញពីទឹកប្រើប្រាស់ត្រឹមត្រូវដែរឬទេ? តើគួរតែមានការកែលម្អដែរឬទេ?
- ☐ តើទឹកប្រើប្រាស់នៅថ្នាក់ឃុំត្រូវបានត្រួតពិនិត្យដែរឬទេ (ឧ. ស្រះ ឬស្ថានីយផលិតទឹកបឹងអាង)?
- ☐ តើមានមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗទៀត គួរតែបន្ថែមទៅក្នុងផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដែរឬទេ?
- ☐ តើផែនការកែលម្អត្រូវបានអនុវត្តន៍តាមកាលកំណត់ដែរឬទេ?
- ☐ តើសកម្មភាពលើកកម្ពស់ការយល់ដឹងត្រូវបានអនុវត្តន៍តាមការគ្រោងទុកដែរឬទេ?
- ☐ តើមានផែនការកែលម្អផ្សេងៗទៀតដែរឬទេ?
- ☐ តើមានការត្រួតពិនិត្យតាមភូមិជាទៀងទាត់ ដើម្បីតាមដានមើលការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដែរឬទេ? ប្រសិនបើ មិនបានអនុវត្តន៍ មូលហេតុអ្វី?
- ☐ បញ្ហាប្រឈមផ្សេងៗ និងដំណោះស្រាយ

### តារាង ១.២. ខាងក្រោមនេះប្រើប្រាស់សម្រាប់បុគ្គលិកដើម្បីកត់ត្រាពេលវេលា នៃកិច្ចប្រជុំ

| កាលបរិច្ឆេទកិច្ចប្រជុំរបស់ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ | ហត្ថលេខាប្រធានក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

## ជំហានទី ២៖ ការគូសផែនទី និងការពិពណ៌នាអំពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

**តារាង ២.១ ទិន្នន័យសង្ខេបក្នុងឃុំ**

| | | |
|---|---|---|
| ១. ស្រុក | | |
| ២. ភូមិ | | |
| ៣. ចំនួនមនុស្សចំណាកស្រុក | | |
| ៤. ប្រភេទផ្ទះ | | |
| ៥. លក្ខណៈភូមិសាស្ត្រ (ទំនាប ខ្ពង់រាប និងងាយរងគ្រោះដោយ..) | | |
| ៦. ផ្លូវអាចធ្វើដំណើរ/ពីភូមិ (ផ្លូវ រថយន្ត) | | |
| ៧. ចំនួនប្រជាជន | សរុប | |
| | បុរស | |
| | ស្ត្រី | |
| | កុមារ | |
| ៨. ចំនួនគ្រួសារសរុប | | |
| ចំនួនគ្រួសារដែលស្ត្រីជាមេគ្រួសារ | | |
| ចំនួនគ្រួសារក្រីក្រ | | ក្រ ១៖ ......................ក្រ ២៖ ...................... |
| ៩. ប្រភេទជនជាតិ | | |
| ១០. មុខរបរសំខាន់ៗ | | |
| ១១. អត្រាភាគរយ នៃអ្នកចេះអាន និងសរសេរ | | បុរស (%) |
| | | ស្ត្រី (%) |
| ១២. ប្រភពចំណូលសំខាន់ៗ | | |
| ១៣. ចំនួនសាលារៀន | មត្តេយ្យសិក្សា | |
| | បឋមសិក្សា | |
| | អនុវិទ្យាល័យ | |
| | វិទ្យាល័យ | |
| ១៤. ចំនួនហេដ្ឋារចនាសម្ព័ន្ធសុខភាព | គ្លីនិក | |
| | មណ្ឌលសុខភាព | |
| | ប៉ុស្តិ៍សុខភាព | |
| ១៥. ចំនួនគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ | | |
| ១៦. ចំនួនគណៈកម្មការទឹកស្អាត និងអនាម័យ | | |

តារាង ២.២. សង្ខេបពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឃុំ (សន្លឹកទី ១)

| ប្រភេទប្រភពទឹកចម្បង | ចំនួនប្រភពទឹក | ចំនួនប្រភពទឹកត្រូវកែលម្អ | ស្ថានភាពប្រភពទឹក | | | | ប្រភពធនធានទឹកដែលអាចប្រើប្រាស់បាន | | | ភាគរយ ឬ ចំនួនប្រជាជនប្រើប្រាស់ទឹក | ភាពជាម្ចាស់ (សហគមន៍ សាធារណៈ ឬ ឯកជន) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | គុណភាពសំណង់ | ស្ថានភាពថែទាំ | បរិស្ថានជុំវិញ | ការគំរាមកំហែងបំពុលក្នុងមូលដ្ឋាន | ចំងាយទៅប្រភពទឹក (គិតជាពេល ឬ ម៉ែត្រ) | ពេញមួយឆ្នាំ | តាមរដូវកាល (ខែ) | | |
| ១. ទឹកផុស | | | | | | | | | | | |
| ២. អណ្តូងលូដែលមិនមានការពារ | | | | | | | | | | | |
| ៣. អណ្តូងលូមានការការពារ | | | | | | | | | | | |
| ៤. អណ្តូងស្នប់សហគមន៍ | | | | | | | | | | | |
| ៥. អណ្តូងឯកជន | | | | | | | | | | | |
| ៦. ទឹកភ្លៀង | | | | | | | | | | | |
| ៧. ស្ទឹង | | | | | | | | | | | |
| ៨. ទន្លេ | | | | | | | | | | | |
| ៩. បឹង | | | | | | | | | | | |
| ១០. ស្រះ | | | | | | | | | | | |
| ១១. ប្រព័ន្ធចែកចាយទឹក (សហគមន៍) | | | | | | | | | | | |
| ១២. ប្រព័ន្ធចែកចាយទឹក (ឯកជន) | | | | | | | | | | | |
| ១៣. ស្ថានីយទឹកដឹកប៊ីដុង (២០លីត្រ) | | | | | | | | | | | |
| ១៤. ស្ថានីយទឹកដឹកឯកជន | | | | | | | | | | | |

| ប្រភេទប្រភពទឹកចម្បង | ការប្រើប្រាស់ទឹកប្រចាំគ្រួសារ | | | | | | បរិមាណទឹកប្រើប្រាស់ | | | គុណភាពទឹក | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ផឹក | ដាំស្ល | ងូត | បោកគក់ | សត្វពាហនៈ | ស្រោចស្លួនច្បារ | គ្រប់គ្រាន់ | ខ្វះខាតពេលណាមួយ នៃឆ្នាំ (ខែ) | ខ្វះខាតពេញមួយឆ្នាំ | ទឹកស្អាត | ទឹកមិនស្អាត |
| ១. ទឹកផុស | | | | | | | | | | | |
| ២. អណ្តូងលូដែលមិនមានការពារ | | | | | | | | | | | |
| ៣. អណ្តូងលូមានការការពារ | | | | | | | | | | | |
| ៤. អណ្តូងស្នប់សហគមន៍ | | | | | | | | | | | |
| ៥. អណ្តូងឯកជន | | | | | | | | | | | |
| ៦. ទឹកភ្លៀង | | | | | | | | | | | |
| ៧. ស្ទឹង | | | | | | | | | | | |
| ៨. ទន្លេ | | | | | | | | | | | |
| ៩. បឹង | | | | | | | | | | | |
| ១០. ស្រះ | | | | | | | | | | | |
| ១១. ប្រព័ន្ធចែកចាយទឹក (សហគមន៍) | | | | | | | | | | | |
| ១២. ប្រព័ន្ធចែកចាយទឹក (ឯកជន) | | | | | | | | | | | |
| ១៣. ស្ថានីយទឹកផឹកបឺដុង (២០ លីត្រ) | | | | | | | | | | | |
| ១៤. ស្ថានីយទឹកផឹកឯកជន | | | | | | | | | | | |

តារាង ២.៣. ទិន្នន័យសង្ខេបពីប្រភពទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឃុំ ( សន្លឹកទី ២ )

## តារាង ២.៤. ការផ្គត់ផ្គង់ទឹកស្អាតឃុំ តាមប្រព័ន្ធបំពង់

កាលបរិច្ឆេទៈ

| | | |
|---|---|---|
| ១. ចំនួនខ្នងផ្ទះនឹងទទួលបានសេវា | | |
| ២. ប្រភពទឹកសម្រាប់ប្រព័ន្ធ (ចំលើយអាចច្រើនជាង ១) | | - ☐ ស្រះ (ចំនួន....ស្រះ សមត្ថភាពស្តុកទឹក......ម$^{៣}$)<br>- ☐ អណ្តូង (ចំនួន.... អណ្តូង ចំនួនជាសរុបទឹក.....ម$^{៣}$)<br>- ☐ ទន្លេ<br>- ☐ ផ្សេងៗ(បញ្ជាក់)...................................... |
| ៣. បរិមាណរបស់ប្រភពទឹក | ពេញមួយឆ្នាំ | |
| | ផ្នែក នៃឆ្នាំ (ខែដែលខ្វះទឹក) | |
| សមាសភាគ នៃប្រព័ន្ធ៖ | | |
| ៤.សមត្ថភាពម៉ាស៊ីនបូមទឹក | | ចំនួនម៉ាស៊ីនបូម....(ចំនួនម៉ាស៊ីនសម្រាប់បម្រុង......)<br>សមត្ថភាព.................ម៉ែត្រគូប/ម៉ោង |
| ៥. អាងស្តុកទឹក | | ☐ អាងស្តុកទឹកក្រោមដីមានចំណុះ .....................ម$^{៣}$<br>☐ អាងអាកាសមានចំណុះ ....................ម$^{៣}$ |
| ៦. ប្រព័ន្ធចម្រោះទឹក (វិធីសាស្ត្រចម្រោះទឹក៖ ប្រើប្រាស់អាងផ្ទុំកករ អាងធ្វើឲ្យរង អាងច្រោះ វិធីសំលាប់មេរោគ) | | |
| ៧. សមត្ថភាពផលិត | | .................................... ម$^{៣}$/ម៉ោង |
| ៨.ប្រវែង នៃប្រព័ន្ធចែកចាយ (ក្នុងឃុំ) | | ....................................គីឡូម៉ែត្រ |
| ៩. ចំនួនចំនុចចែកចាយទឹកសាធារណៈ (ក្នុងឃុំ) | | |
| ១០. ចំនួនខ្នងផ្ទះដែលបានតបណ្តាញទឹក (ក្នុងឃុំ) | | .....................................ខ្នងផ្ទះ |
| ១១. ស្ថានភាពថែទាំប្រព័ន្ធ | | |
| ១២. ភាពជាម្ចាស់របស់ប្រព័ន្ធ៖ សហគមន៍ (ឈ្មោះ លេខទំនាក់ទំនង,...) | | លោក៖.....................................<br>លេខទូ/ន៖......................................... |
| ប្រត្តិបត្តិករឯកជន (ឈ្មោះ លេខទំនាក់ទំនង ស្ថានភាពអជ្ញាប័ណ្ណ) | | លោក៖.....................................<br>លេខទូ/ន៖.........................................<br>ស្ថានភាពអាជ្ញាប័ណ្ណ៖........................................ |
| ផ្សេងៗ | | ថ្លៃតបណ្តាញ៖......................................រៀល<br>ថ្លៃប្រើប្រាស់ទឹក៖...................................... រៀល<br>បណ្តាញគ្របដណ្តប់ក្នុងឃុំ៖<br>ចំនួនភូមិមានបណ្តាញ៖ ................. ភូមិ<br>ចំនួនភូមិដែលគ្រោងពង្រីកបណ្តាញក្នុងរយៈពេលប្រាំឆ្នាំខាងមុខ៖.......... ភូមិ |

**ស្ថានភាពទឹកបច្ចុប្បន្ន (ស្ថានភាពទឹកខាងលើ)**

ផ្នែកនេះផ្តេកទៅលើការរកឃើញពីជំហានទី ២ នៃដំណើរការផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ។ វាផ្តល់នូវសេចក្តីសង្ខេបអំពីប្រភពទឹក និងការផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំ និងការប្រើប្រាស់ទឹកក្នុងសហគមន៍។

## ជំហានទី ៣៖ ការកំណត់គ្រោះថ្នាក់ និងវិធានការឆ្លើយតប

**តារាង ៣.១. គ្រោះមហន្តរាយ**

| | | |
|---|---|---|
| **១. ការកំណត់មុខសញ្ញាគ្រោះថ្នាក់** | | |
| ១.១ | មុខសញ្ញាគ្រោះថ្នាក់ដោយសារអាកាសធាតុ | ☐ គ្រោះទឹកជំនន់ (☐ ជំនន់ពីទន្លេ ឬ ☐ ជំនន់រហ័ស)<br>☐ គ្រោះរាំងស្ងួត (☐ ដោយសារអាកាសធាតុ ឬ ☐ ធនធានទឹករីងស្ងួត)<br>☐ គ្រោះថ្នាក់ដោយសារការបំពុលពីសារធាតុគីមី (ឈ្មោះ ឬប្រភេទរបស់សារធាតុបំពុល៖.............................................)<br>☐ គ្រោះថ្នាក់ដោយសារការហូរច្រោះដី<br>☐ មិនធ្លាប់ជួបគ្រោះមហន្តរាយ |
| **២. ការវាយតម្លៃលើគ្រោះទឹកជំនន់** *(ប្រសិនបើ គ្មានគ្រោះទឹកជំនន់ អាចរំលងបាន)* | | |
| ២.១ | តើទឹកជំនន់កើតឡើងញឹកញាប់យ៉ាងដូចម្តេចដែរ? | ☐ រៀងរាល់ឆ្នាំ<br>☐ ជានិច្ចកាល (២ ទៅ ៥ ឆ្នាំម្តង)<br>☐ ម្តងម្កាល (៥ ទៅ ១០ ឆ្នាំ)<br>☐ កម្រ (ច្រើនជាង ១០ ឆ្នាំ) |
| ២.២ | តើទឹកជំនន់មានកម្រិតណា? | ☐ ទាប<br>☐ មធ្យម<br>☐ ខ្លាំង |
| ២.៣ | តើផ្នែកណាខ្លះ នៃឃុំ ដែលរងគ្រោះដោយទឹកជំនន់ជានិច្ចកាល? | ☐ ឃុំទាំងមូល (៦០% ទៅ ១០០% នៃឃុំ)<br>☐ ផ្នែកខ្លះក្នុងឃុំ (៣០% ទៅ ៦០% នៃឃុំ)<br>☐ ផ្នែកខ្លះក្នុងឃុំ (ក្រោម ៣០% នៃឃុំ)<br>សូមបញ្ជាក់៖.......................................................<br>(ឧ.ចំនួនភូមិលិចទឹកមានចំនួន ៣ ក្នុងចំណោម ១០ ប្រហែល ៣០%) |
| ២.៤ | តើមានប្រភពទឹកកខ្វក់ដោយសារទឹកជំនន់ឬទេ? | ☐ មាន<br>☐ មិនមាន |
| ២.៥ | តើប្រភពទឹកអ្វីខ្លះដែលរងផលប៉ះពាល់ដោយទឹកជំនន់? | ☐ ទឹកអណ្តូង<br>☐ ទឹកស្រះ<br>☐ ទឹកបឹងបួ/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>............................ |

| | | |
|---|---|---|
| ២.៦ | តើប្រភពទឹកអ្វីខ្លះដែលត្រូវបានប្រើក្នុងអំឡុងពេលទឹកជំនន់? | ☐ ទឹកអណ្តូង<br>☐ ទឹកលក់តាមរទេះ ឬឡាន<br>☐ ទឹកបឹងស្ទឹង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>........................... |
| ២.៧ | តើមានបង្គន់អនាម័យខូចខាតដោយទឹកជំនន់ដែរឬទេ? | ☐ មាន<br>☐ មិនមាន |
| ២.៨ | តើមានកន្លែងណាផ្សេងទៀតសម្រាប់បន្ទោរបង់ដែរឬទេ? (សូមបញ្ជាក់) | |
| **៣. ការវាយតម្លៃលើគ្រោះរាំងស្ងួត** *(ប្រសិនបើ គ្មានគ្រោះរាំងស្ងួត អាចរំលងបាន)* | | |
| ៣.១ | តើគ្រោះរាំងស្ងួតអាចកើតឡើងញឹកញាប់យ៉ាងដូចម្តេច? | ☐ រៀងរាល់ឆ្នាំ<br>☐ ជានិច្ចកាល (២ ទៅ ៥ ឆ្នាំម្តង)<br>☐ ម្តងម្កាល (៥ ទៅ ១០ ឆ្នាំ)<br>☐ កម្រ (ច្រើនជាង ១០ ឆ្នាំ) |
| ៣.២ | តើគ្រោះរាំងស្ងួតមានរយៈពេលប៉ុន្មាន? | ☐ ចាប់ពី ០ ដល់ ១ ខែ<br>☐ ចាប់ពី ១ ដល់ ២ ខែ<br>☐ ចាប់ពី ២ ខែឡើងទៅ |
| ៣.៣ | តើប្រភពទឹកអ្វីខ្លះដែលរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួត? | ☐ ទឹកអណ្តូង<br>☐ ទឹកស្រះ<br>☐ ទឹកពីស្ទឹង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>........................... |
| ៣.៤ | តើប្រភពទឹកអ្វីខ្លះអាចប្រើប្រាស់បានក្នុងអំឡុងពេលគ្រោះរាំងស្ងួត? | ☐ ទឹកអណ្តូង<br>☐ ទឹកលក់តាមរទេះ ឬ ឡាន<br>☐ ទឹកបឹងស្ទឹងទឹកពីស្ទឹង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>........................... |
| **៤. គ្រោះថ្នាក់ដោយសារការបំពុលពីសារធាតុគីមី** *(ប្រសិនបើ គ្មាន អាចរំលងបាន)* | | |
| ៤.១ | តើគ្រោះថ្នាក់ដោយសារការបំពុលពីសារធាតុគីមីមានកម្រិតណា? | ☐ ទាប<br>☐ មធ្យម<br>☐ ខ្លាំង |
| ៤.២ | តើផ្នែកណាខ្លះ នៃឃុំដែលរងគ្រោះថ្នាក់នេះ? | ☐ ឃុំទាំងមូល<br>☐ ផ្នែកខ្លះក្នុងឃុំ (៣០% ទៅ ៦០% នៃឃុំ)<br>☐ ផ្នែកខ្លះក្នុងឃុំ (ក្រោម ៣០% នៃឃុំ) |

| | | |
|---|---|---|
| | | សូមបញ្ជាក់៖........................................................... |
| ៤.៣ | តើប្រភពទឹកអ្វីខ្លះដែលរងផលប៉ះពាល់ដោយគ្រោះថ្នាក់នេះ ? | ☐ ទឹកអណ្តូង<br>☐ ទឹកស្រះ<br>☐ ទឹកបឹងធុង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>............................ |
| ៤.៤ | តើប្រភពទឹកអ្វីខ្លះអាចប្រើប្រាស់បានក្នុងអំឡុងពេលគ្រោះថ្នាក់នេះ ? | ☐ ទឹកអណ្តូង<br>☐ ទឹកលក់តាមរទេះ ឬឡាន<br>☐ ទឹកបឹងធុង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>............................ |
| **៥.គ្រោះថ្នាក់ដោយការហូរច្រោះដី** (*ប្រសិនបើ គ្មាន អាចរំលងបាន*) | | |
| ៥.១ | តើគ្រោះថ្នាក់នេះអាចកើតឡើងញឹកញាប់យ៉ាងដូចម្តេច? | ☐ រៀងរាល់ឆ្នាំ<br>☐ ជានិច្ចកាល (២ ទៅ ៥ ឆ្នាំម្តង)<br>☐ ម្តងម្កាល (៥ ទៅ ១០ ឆ្នាំ)<br>☐ កម្រ (ច្រើនជាង ១០ ឆ្នាំ) |
| ៥.២ | តើផ្នែកណាខ្លះ នៃឃុំដែលរងគ្រោះថ្នាក់នេះ ? | ☐ ឃុំទាំងមូល<br>☐ ផ្នែកខ្លះក្នុងឃុំ (៣០% ទៅ ៦០% នៃឃុំ)<br>☐ ផ្នែកខ្លះក្នុងឃុំ (ក្រោម ៣០% នៃឃុំ)<br>សូមបញ្ជាក់៖........................................................... |
| ៥.៣ | តើប្រភពទឹកអ្វីខ្លះដែលរងផលប៉ះពាល់ដោយគ្រោះថ្នាក់នេះ ? | ☐ ទឹកអណ្តូង<br>☐ ទឹកស្រះ<br>☐ ទឹកបឹងធុង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>............................ |
| ៥.៤ | តើប្រភពទឹកអ្វីខ្លះ អាចប្រើប្រាស់បានក្នុងអំឡុងពេលគ្រោះថ្នាក់នេះ ? | ☐ ទឹកអណ្តូង<br>☐ ទឹកលក់តាមរទេះ ឬឡាន<br>☐ ទឹកបឹងធុង/ជប<br>☐ ផ្សេងៗ (បញ្ជាក់)<br>............................ |
| | ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងភាពងាយរងគ្រោះរបស់ឃុំចំពោះអាកាសធាតុ / មុខសញ្ញាគ្រោះថ្នាក់ នៃអាកាសធាតុ។ (បំពេញដោយក្រុមការងារអ្នកសម្របសម្រួល) | |

| IV | ទិន្នន័យអាកាសធាតុពេលអតីតកាល | | |
|---|---|---|---|
| IV.1 | រយៈពេលរាំងស្ងួត (Dry Spell) | | day/year |
| IV.2 | បរិមាណទឹកភ្លៀងទាបបំផុត | | mm/year |

| | | | | | |
|---|---|---|---|---|---|
| | IV.3 | កម្រិត នៃភាពរងគ្រោះពេលមានភាពរាំងស្ងួត ( Drought Vulnerability ) | | | |
| | IV.4 | កម្រិត នៃភាពរងគ្រោះពេលមានទឹកជំនន់ ( Flood Vulnerability ) | | | |
| | IV.5 | ភាពញឹកញាប់ នៃគ្រោះរាំងស្ងួត | | | |
| | IV.6 | ភាពញឹកញាប់ នៃគ្រោះទឹកជំនន់ | | | |
| | IV.7 | បរិមាណ នៃភាពរំហួត ( Evapotranspiration ) | | mm/year | |

| V | ទិន្នន័យអាកាសធាតុពេលអនាគត | | |
|---|---|---|---|
| V.1 | បម្រែបម្រួលលើបរិមាណទឹកភ្លៀង | | % |
| V.2 | បម្រែបម្រួលលើរយៈពេលរាំងស្ងួត | | day/year |
| V.3 | បម្រែបម្រួល នៃភាពរំហួត | | % |
| V.4 | រយៈពេលរាំងស្ងួត | | day/year |
| V.5 | បរិមាណទឹកភ្លៀង | | mm/year |
| V.6 | បរិមាណ នៃភាពរំហួត | | mm/year |
| V.7 | កម្រិត នៃរយៈពេលរាំងស្ងួត | | |
| V.8 | កម្រិត នៃបរិមាណទឹកភ្លៀង | | |

### ការធ្វើការវាយតម្លៃហានិភ័យដោយគ្រោះមហន្តរាយ

ព័ត៌មានលម្អិតដែលទាក់ទងទៅនឹងការវាយតម្លៃហានិភ័យដោយគ្រោះមហន្តរាយមាន នៅក្នុងឧបសម្ព័ន្ធ ១

**តារាង ៣.២ ការវាយតម្លៃ កំណត់ ដាក់ពិន្ទុកហានិភ័យដោយគ្រោះធម្មជាតិ និងវិធានការកែលម្អ**

| គ្រោះមហន្តរាយ | | | | | ការប៉ះពាល់ | | | | ភាពងាយរងគ្រោះ | | | | ហានិភ័យ | | | វិធានការកែលម្អ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គ្រោះធម្មជាតិ | ពិន្ទុ | ចំណាត់ថ្នាក់ | ភាពជឿជាក់នាពេលបច្ចុប្បន្ន | ភាពជឿជាក់នាអនាគត | ការប៉ះពាល់ | ពិន្ទុ | ចំណាត់ថ្នាក់ | ពិន្ទុ នៃភាពជឿជាក់ | ភាពងាយរងគ្រោះ | ពិន្ទុ | ចំណាត់ថ្នាក់ | ពិន្ទុនៃភាពជឿជាក់ | ពិន្ទុ | ហានិភ័យខ្ពស់ | ចំណាត់ថ្នាក់ | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

## ខ. គ្រោះថ្នាក់ដែលអាចកើតមានចំពោះទឹកប្រើប្រាស់

យោងតាមការពិភាក្សា និងការចុះត្រួតពិនិត្យនៅកន្លែងផ្ទាល់ សូមធ្វើការកត់ត្រាមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាននៅក្នុងផ្នែកមួយៗ នៃទឹកប្រើប្រាស់ក្នុងឃុំ។ បន្ទាប់ពីការពិភាក្សាពីគ្រោះថ្នាក់ទាំងនេះ ធ្វើការកំណត់រកវិធានការរក្សាទឹកឲ្យមានសុវត្ថិភាព។




ប្រភេទប្រភពទឹក (គូសសញ្ញាគ្រប់ប្រភពទឹកដែលមាននៅក្នុងភូមិ)៖

- ☐ អណ្តូងលូ
- ☐ អណ្តូងស្នប់
- ☐ ស្រះ
- ☐ ទឹកប៊ីដុង (២០ លីត្រ)
- ☐ ទឹកភ្លៀង
- ☐ ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍
- ☐ ផ្សេងៗ

**តារាង ៣.២ ស្ថានភាពគ្រោះថ្នាក់ ការវាយតម្លៃ និងវិធានការកែលម្អរបស់ប្រភពទឹក**

| **ប្រភពទឹក** *(ឧ. ១. ស្រះសហគមន៍ ១ នៃភូមិ ក (១០×២០×៣)ម$^{៣}$ បម្រើប្រជាជន ២០ គ្រួសារ)* | **ស្ថានភាពគ្រោះថ្នាក់** *(ឧ. ១. ស្រះរីងស្ងួតនៅក្នុងរដូវប្រាំង មិនអាចបំពេញតម្រូវការគ្រប់)* | **វិធានការកែលម្អ** *(ឧ. ១. ពង្រីកបន្ថែម និងពន្យល់ពលរដ្ឋប្រើប្រាស់សន្សំសន្ចៃ)* | **កម្រិតអាទិភាព** ១=ខ្ពស់ ២=មធ្យម ៣=ទាប |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |




តារាង៣.៣ ស្ថានភាពគ្រោះថ្នាក់ ការវាយតម្លៃ និងវិធានការកែលម្អរបស់ **ការផងទឹក/ការដឹកជញ្ជូន**

| **ការផងទឹក/ការដឹកជញ្ជូន** *(ឧ. ១. ចំនួនគ្រួសារក្នុងភូមិ ក ប្រើប្រាស់ស៊ីទែនដឹកទឹកលក់)* | **ស្ថានភាពគ្រោះថ្នាក់** *(ឧ. ១. ស៊ីទែនដឹកទឹក ដែលមិនស្អាត និងទុកដាក់មិនត្រឹមត្រូវ)* | ☑ **វិធានការកែលម្អ** *(ឧ. ១. អប់រំដល់អ្នកដឹកទឹកលក់តាមស៊ីទែន ត្រូវតែលាងសំអាត)* | **កំរិតអាទិភាព** ១=ខ្ពស់ ២=មធ្យម ៣=ទាប |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |



**តារាង ៣.៤ ស្ថានភាពគ្រោះថ្នាក់ ការវាយតម្លៃ និងវិធានការកែលម្អរបស់ ការស្តុកទឹក**

| **ការស្តុកទឹក**<br>*(ឧ. ១. ១០% នៃគ្រួសារចំនួន ១២៥ ក្នុងភូមិ ក ស្តុកទឹកប្រើប្រាស់មិនត្រឹមត្រូវ)* | ☒ **ស្ថានភាពគ្រោះថ្នាក់**<br>*(ឧ. ១. ១០% នៃគ្រួសារមានពាង រឺអាងមិនមានគម្រប កំណល់ និងទុកដាក់នៅកន្លែងដែលគ្មានអនាម័យល្អ)* | ☑ **វិធានការកែលម្អ**<br>*(ឧ. ១. អប់រំប្រជាជនទាំងនោះពីវិធីសាស្ត្រទុកដាក់ទឹកត្រឹមត្រូវ)* | **កម្រិតអាទិភាព**<br>**១=ខ្ពស់**<br>**២=មធ្យម**<br>**៣=ទាប** |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |



## តារាង ៣.៥ ស្ថានភាពគ្រោះថ្នាក់ ការវាយតម្លៃ និងវិធានការកែលម្អរបស់ ទឹកផឹក / ការអនុវត្តដែលទាក់ទង ទៅនឹងទឹកផឹក

| ទឹកផឹក/ ការអនុវត្តដែលទាក់ទងទៅនឹងទឹកផឹក<br>*(ឧ. ១. ១០% នៃគ្រួសារចំនួន ១២៥ ក្នុងភូមិ ក ផឹកទឹកមិនស្អាត និង ២០%ក្នុងភូមិដដែលការទុកដាក់ទឹកផឹក និងសម្ភារសម្រាប់ផឹកទឹក)* | ☒ ស្ថានភាពគ្រោះថ្នាក់<br>*(ឧ. ១. ១០% នៃគ្រួសារចំនួន ១២៥ ក្នុងភូមិ ក ផឹកទឹកនៅមិនបន្សុទ្ធ និង ២០% ក្នុងភូមិដដែលទុកដាក់កែវគ្មានសុវត្ថិភាព គ្មានអនាម័យ)* | ☑ វិធានការកែលម្អ<br>*(ឧ. ១. អប់រំគ្រួសារទាំងនោះឲ្យធ្វើការបន្សុទ្ធទឹកតាមរយៈ ការដាំ ច្រោះទឹក... និងលាងសំអាតទៀងទាត់ និងទុកដាក់កំសៀវ កែវទឹកត្រឹមត្រូវ)* | កម្រិតអាទិភាព<br>១=ខ្ពស់<br>២=មធ្យម<br>៣=ទាប |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ជំហានទី ៤៖ ផែនការកែលម្អនៅថ្នាក់ឃុំ

គ្រោះថ្នាក់មួយចំនួនដែលបានកំណត់ក្នុងជំហានទី ៣ តម្រូវឲ្យក្រុមការងារឃុំចាត់វិធានការកែលម្អ (ឧ. ជួសជុលរបងព័ទ្ធជុំវិញស្រះ ឬការប្តូរទីតាំងបង្គន់អនាម័យទៅឆ្ងាយពីទឹកលិច)។ **កត់ត្រាផែនការកែលម្អកម្រិតឃុំ/ភូមិក្នុងតារាងនេះ** ហើយធ្វើចំណាត់ថ្នាក់សកម្មភាពទៅតាមកម្រិតគ្រោះថ្នាក់ និងធនធានដែលមាន (១. អាទិភាពខ្ពស់ ២. អាទិភាពមធ្យម ៣. អាទិភាពទាប)។

ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុអាចជួយកែលម្អតាមរយៈសកម្មភាពផ្សេងៗ (ឧ.យុទ្ធនាការលើកកម្ពស់ការយល់ដឹង ហើយត្រួតពិនិត្យ តាមដានការកែទម្លាប់បន្តិចម្តងៗ)

**តារាង ៤.១ ផែនការកែលម្អ**

| ល.រ | **តើគួរតែធ្វើអ្វីខ្លះនៅក្នុងឃុំ ដើម្បីកែលម្អទឹកប្រើប្រាស់?** *(ឧ. ១. តបណ្តាញទឹកដល់គ្រួសារក្រីក្រ ១០ តំណក្នុងភូមិ ក)* | **ឈ្មោះអ្នកដែលទទួលបន្ទុកការងារនេះ** *(ឧ. ១. ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ* | **តើត្រូវការសម្ភារ និងធនធានអ្វីខ្លះ?** *(ឧ. ១. ថវិកា ២,៨ លានរៀល (១ តំណ ២៨ ម៉ឺនរៀល) ប្រភពថវិការឃុំ* | **ធ្វើពេលណា?** *(ឧ. កក្កដា ២០២១)* | **កម្រិតអាទិភាព** ១=ខ្ពស់ ២=មធ្យម ៣=ទាប | **ពិនិត្យមើលលទ្ធផល** ☑ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ការលើកកម្ពស់ការយល់ដឹង

គេត្រូវតែមានផែនការដាក់លាក់សម្រាប់លើកកម្ពស់ការយល់ដឹង។ រាល់យុទ្ធនាការលើកកម្ពស់ការយល់ដឹងគួរតែបញ្ចូលការអប់រំដើម្បីឲ្យទឹកមានសុវត្ថិភាពក្នុងករណីគ្រោះទឹកជំនន់ ឬស្ថានភាពគ្រោះអាសន្នណាមួយ។

ឧទាហរណ៍ សកម្មភាពលើកកម្ពស់ការយល់ដឹង មានដូចជា៖

- ការប្រើប្រាស់ទឹកសុវត្ថិភាពតាមភូមិ និងគ្រួសារ
- ចែកសម្ភារអប់រំតាមសាលារៀន មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព វត្តអារាម
- ព្រឹត្តិការណ៍/យុទ្ធនាការណ៍សំអាតបរិស្ថានជុំវិញប្រភពទឹក
- ពិភាក្សាទឹកសុវត្ថិភាពនៅក្នុងអង្គប្រជុំជាសាធារណៈ បញ្ចូលក្នុងព្រឹត្តិការណ៍ពិសេសប្រចាំឆ្នាំ

**តារាង ៤.២ ការលើកកម្ពស់ការយល់ដឹង**

| ល.រ | ការលើកកម្ពស់ការយល់ដឹង<br>*(ឧ. ១. អប់រំអំពីការការពារប្រភពទឹក ការប្រើប្រាស់សម្ភារផងទឹកមានអនាម័យ ការបន្សុទ្ធទឹក និងការទុកស្តុកទឹក និងកែវផឹកទឹកឱ្យបានត្រឹមត្រូវ)* | វិធីសាស្ត្រ<br>*(ឧ. ១. ចុះជុំរុញតាមខ្នងផ្ទះ និងជួបប្រជុំតាមភូមិ ធ្វើនៅតាមសាលារៀន ចែកចាយ និងប្រើប្រាស់សៀវភៅ....)* | រយៈពេល<br>*(ឧ. រៀងរាល់ត្រីមាស)* | អ្នកទទួលបន្ទុក<br>*(ឧ. ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ)* |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |

## ជំហានទី ៥៖ ផែនការត្រួតពិនិត្យ តាមដាន

ក្នុងជំហាននេះ ការត្រួតពិនិត្យ តាមដានគួរតែមានកម្រិតផ្សេងៗគ្នា៖

១. ក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវតែត្រួតពិនិត្យទឹកប្រើប្រាស់ជារួមក្នុងឃុំ រួមទាំងផែនការកែលម្អ។

២. សមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ត្រូវតែត្រួតពិនិត្យតាមភូមិ តាមសាលារៀនជាមួយនាយកសាលា តាមមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពជាមួយមន្ត្រីមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព តាមរយៈការប្រជុំថ្នាក់ឃុំ ជាមួយក្រុមការងារផែនការសុវត្ថិភាពទឹកឃុំ ឬតាមរយៈការត្រួតពិនិត្យតាមមូលដ្ឋាន។

៣. មន្ទីរអភិវឌ្ឍន៍ជនបទ ឬអាជ្ញាធរមូលដ្ឋានដទៃទៀត ត្រូវតែត្រួតពិនិត្យក្នុងឃុំម្តងម្កាល ដើម្បីពិនិត្យមើលការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ។

**តារាង ៥.១. ការត្រួតពិនិត្យបន្តបន្ទាប់នៅថ្នាក់ឃុំដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ**

| ល.រ | ប្រភេទប្រភពទឹក (ឧ.ស្រះ ទឹកលិច ស្ថានីយផ្គត់ផ្គង់ ទីបឹជុង) | ការត្រួតពិនិត្យ (ឧ. របង ការសំអាតជម្មតា) | អ្នកទទួលបន្ទុក | ពេលវេលា |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |

តារាង ៥.២ ការត្រួតពិនិត្យបន្តបន្ទាប់តាមភូមិ សាលារៀន និងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាពដោយក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ប្រចាំត្រីមាស

| ល.រ | ឈ្មោះសមាជិកក្រុមការងារផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ | វិធីសាស្ត្រ | ចំនួនប្រជុំដែលបានពិភាក្សាពីការអនុវត្តផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ | ចំនួនកន្លែងដែលបានត្រួតពិនិត្យ | កាលបរិច្ឆេទ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |

## ផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដែលត្រូវត្រួតពិនិត្យដោយមន្ទីរអភិវឌ្ឍន៍ជនបទ ឬអាជ្ញាធរពាក់ព័ន្ធ

ផ្នែកនេះគឺសម្រាប់កំណត់ផែនការត្រួតពិនិត្យ តាមដានបន្តបន្ទាប់លើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ ដោយមន្ទីរអភិវឌ្ឍន៍ជនបទ ឬអាជ្ញាធរមូលដ្ឋាន ។

| លរ | កាលបរិច្ឆេទ | ឈ្មោះអ្នកត្រួតពិនិត្យ | ស្ថាប័ន | ការត្រួតពិនិត្យ (ឧ. កិច្ចប្រជុំ ការអនុវត្តផែនការ ការត្រួតពិនិត្យ ការតាមដានតាមទីតាំង ការលើកកម្ពស់ការយល់ដឹង...) | លទ្ធផល | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |

## ឧបសម្ព័ន្ធ ខ. ការកំណត់ និងការវាយតម្លៃហានិភ័យដោយគ្រោះមហន្តរាយ

តារាងខាងក្រោមនេះ គឺជាទិន្នន័យដែលបានមកពីការកំណត់ហានិភ័យក្នុងពេលធ្វើផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុដោយប្រើប្រាស់តារាង excel ដែលបានផ្តល់ជូន។

ក. ការកំណត់មុខសញ្ញាគ្រោះមហន្តរាយ

ក. ១.សេចក្តីណែនាំ ស្តីពីការប្រើប្រាស់ តារាងការកំណត់មុខសញ្ញាគ្រោះមហន្តរាយ (តារាង ក.២)

| ការកំណត់មុខសញ្ញាគ្រោះមហន្តរាយ | ការដាក់ពិន្ទុគ្រោះមហន្តរាយ | ការកំណត់ពិន្ទុភាពជឿជាក់ |
|---|---|---|
| 1) ជ្រើសរើសមុខសញ្ញាគ្រោះថ្នាក់ក្នុងតារាងក.២ | 1) ជ្រើសរើសលក្ខណៈវិនិច្ឆ័យទី ១ ពីតារាងក.២ | 1) ជ្រើសរើសកម្រិត នៃភាពជឿជាក់ (ខ្ពស់ មធ្យម និង ទាប) |
| 2) សរសេរចូលពីព័ត៌មានលម្អិត នៃគ្រោះមហន្តរាយ សម្រាប់លក្ខណៈវិនិច្ឆ័យ | 2) ជ្រើសរើសកំណត់សំគាល់ នៃលក្ខណៈវិនិច្ឆ័យទី ១ តារាង ក.២ | ចេញពីតារាងនៅក្នុងប្រអប់ ពេលបច្ចុប្បន្ន |
| 3) សរសេរពីមតិ យោបល់ | 3) ជ្រើសរើសលក្ខណៈវិនិច្ឆ័យទី ២ ពីតារាង ក.២ | 2) ជ្រើសរើសកម្រិត នៃភាពជឿជាក់ (ខ្ពស់ មធ្យម និង ទាប) |
| ខ. ឈ្មោះភូមិដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ | 4) ជ្រើសរើស កំណត់សំគាល់ នៃលក្ខណៈវិនិច្ឆ័យទី ២ | ចេញពីតារាងនៅក្នុងប្រអប់ ពេលអនាគត |
| | 5) ដាក់ពិន្ទុ និងពិនិត្យមើលពិន្ទុ 1 (ទាប) 2 (មធ្យម) ឬ 3 (ខ្ពស់) | 3) សរសេរមតិ យោបល់ពីមូលហេតុ នៃការដាក់ពិន្ទុភាពជឿជាក់ |
| | | |

## ក.២. ការកំណត់មុខសញ្ញាគ្រោះមហន្តរាយ

| ការកំណត់មុខសញ្ញាគ្រោះមហន្តរាយ | | | | | | |
|---|---|---|---|---|---|---|
| គ្រោះមហន្តរាយ | ភាពញឹកញាប់ | រយៈពេល | អាំងតង់ស៊ីតេ | ទំហំនៃភាពប៉ះពាល់ | ពេលណា? | មតិយោបល់ |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

| ការដាក់ពិន្ទុគ្រោះមហន្តរាយ | | | | | | | ភាពជឿជាក់លើការវិភាគ | | |
|---|---|---|---|---|---|---|---|---|---|
| គ្រោះមហន្តរាយ | លក្ខណៈវិនិច្ឆ័យទី ១ | កំណត់សំគាល់ទី ១ | លក្ខណៈវិនិច្ឆ័យទី ២ | កំណត់សំគាល់ទី ២ | ពិន្ទុ | ចំណាត់ថ្នាក់ | បច្ចុប្បន្ន | អនាគត | មតិយោបល់ |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## ខ. ការកំណត់ការប៉ះពាល់

| ការកំណត់ការប៉ះពាល់ | | | ការដាក់ពិន្ទុ | | | កម្រិតភាពជឿជាក់ | |
|---|---|---|---|---|---|---|---|
| គ្រោះមហន្តរាយ | ប្រភេទ | ការប៉ះពាល់ | ពិន្ទុ | ចំណាត់ថ្នាក់ | មតិ យោបល់ | ពិន្ទុ | មតិ យោបល់ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## គ. ភាពងាយរងគ្រោះ

| តារាងវិភាគភាពងាយរងគ្រោះ | | | តារាងដាក់ពិន្ទុភាពងាយរងគ្រោះ | | | ភាពជឿជាក់ | |
|---|---|---|---|---|---|---|---|
| ជាតុ | ប្រភេទ | សំនួរពីភាពធន់ | កំណត់សំគាល់ | ពិន្ទុ | ចំណាត់ថ្នាក់ | ពិន្ទុ | មតិ យោបល់ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## ឃ. ភាពធន់នឹងហានិភ័យ

| តារាងវិភាគភាពធន់នឹងហានិភ័យ | | | ការវិភាគលើភាពធន់ | | |
|---|---|---|---|---|---|
| ជាតុសំខាន់ | ប្រភេទ | សំនួរ នៃភាពធន់ | ការវិភាគលើភាពធន់ | ពិន្ទុ | ចំណាត់ថ្នាក់ |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ខ. ទម្រង់អង្កេតអនាម័យជុំវិញទឹកប្រើប្រាស់

ព័ត៌មានទូទៅ

ឈ្មោះឃុំ៖.........................................ឈ្មោះភូមិ..................................................

ឈ្មោះសាលារៀន/មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព៖.................................................

ឈ្មោះអ្នកដែលត្រូវសម្ភាសន៍៖...........................................................................

កាលបរិច្ឆេទ៖.....................................................................................................

ធ្វើដោយ៖..........................................................................................................

**ផ្នែកទី ១៖ ប្រភពទឹក**

កម្រងសំនួរ

តើក្នុងពេលនេះ តើអ្នកយកទឹកពីប្រភពណាមកផឹក?

- ☐ ស្រះសហគមន៍
- ☐ ស្រះ ឬស្ទឹង
- ☐ អណ្តូងលូគ្មានការការពារ
- ☐ អណ្តូងលូដែលបានការពារ
- ☐ អណ្តូងស្នប់
- ☐ រ៉ូប៊ីណេទឹករួម (ពីប្រព័ន្ធចែកចាយទឹក)
- ☐ រ៉ូប៊ីណេតាមផ្ទះ (បណ្តាញទឹក)
- ☐ ផ្សេងៗ.........................................

### ស្រះសហគមន៍

ពិនិត្យមើលប្រភពទឹក ហើយសិក្សាពីស្ថានភាពតាមរយៈសំនួរខាងក្រោម៖

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | របងជុំវិញស្រះ គ្មាន មានមិនគ្រប់គ្រាន់ ឬបាក់ទ្រុឌទ្រោម | | |
| ២ | សត្វអាចចូលក្នុងស្រះទឹកបាន | | |
| ៣ | មានបង្គន់ចម្ងាយ ជិតជាង ១៥-២៥ ម និងនៅទីទួលខ្ពស់ជាងស្រះ | | |
| ៤ | មានប្រភពបំពុលផ្សេងៗ (ឧ. លាមកសត្វ សំរាម ថ្លុកទឹក និងការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត) ចម្ងាយជិតជាង ១៥-២៥ ម ពីស្រះ | | |
| ៥ | មានសញ្ញាណរុក្ខជាតិល្វើយ | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## អណ្តូងលូ

ពិនិត្យមើលប្រភពទឹក ហើយសិក្សាពីស្ថានភាពតាមរយៈសំនួរខាងក្រោម៖

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | មានបង្គន់ចម្ងាយ ជិតជាង ១៥-២៥ ម និងនៅទីទួលខ្ពស់ជាងអណ្តូង | | |
| ២ | មានប្រភពបំពុលផ្សេងៗ (ឧ. លាមកសត្វ សំរាម ថ្លុកទឹក និងការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត) ចម្ងាយជិតជាង ១៥-២៥ ម ពីអណ្តូង | | |
| ៣ | កង់លូខាងលើដី (មាត់អណ្តូង) បាក់បែក ឬអត់មាន | | |
| ៤ | កង់លូអណ្តូងនៅចន្លោះ ០-៣ ម ចុះក្រោម មិនបានផ្សាភ្ជិតត្រឹមត្រូវ | | |
| ៥ | អត់មានចង្អូរបង្ហូរទឹក ឬមិនដំណើរការ បណ្តាលឲ្យស្ទះ និងមានថ្លុកទឹកចម្ងាយ ២ ម ពីអណ្តូង | | |
| ៦ | ខឿនជុំវិញអណ្តូងមានទំហំតូចជាង ១ ម | | |
| ៧ | ខឿនជុំវិញអណ្តូងប្រេះបែក បណ្តាលឲ្យទឹកដក់ និងជ្រាបចូលក្នុងអណ្តូង | | |
| ៨ | គ្មានខឿនជុំវិញអណ្តូង ឬបាក់បែកទាំងស្រុង | | |
| ៩ | អណ្តូងគ្មានគម្រប | | |
| ១០ | គ្មានរបងជុំវិញអណ្តូង ឬបាក់បែក | | |
| ១១ | ខ្សែ និងធុងយោងទឹកទុកដាក់នៅកន្លែងមិនស្អាត | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## អណ្តូងស្នប់អាហ្វ្រីដេវ

ពិនិត្យមើលប្រភពទឹក ហើយសិក្សាពីស្ថានភាពតាមរយៈសំនួរខាងក្រោម៖

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | មានបង្គន់ចម្ងាយ ជិតជាង ១៥-២៥ ម ពីអណ្តូង | | |
| ២ | មានប្រភពបំពុលផ្សេងៗ (ឧ. លាមកសត្វ សំរាម ថ្លុកទឹក និងការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត) ចម្ងាយជិតជាង ១៥-២៥ ម ពីអណ្តូង | | |
| ៣ | ចង្អូរទឹកមិនល្អ (បែកបាក់ ឬស្ទះ) បណ្តាលឲ្យមានថ្លុកទឹកចម្ងាយ ២ ម ពីអណ្តូង | | |
| ៤ | ខឿនជុំវិញអណ្តូងមានទំហំតូចជាង ១ ម | | |
| ៥ | ខឿនជុំវិញអណ្តូងប្រេះបែក បណ្តាលឲ្យទឹកជ្រាបចូលអណ្តូង | | |
| ៦ | អត់មានខឿនជុំវិញអណ្តូង (ឬខឿនបាក់បែកទាំងស្រុង) | | |
| ៧ | ជើងស្នប់រលុង បណ្តាលឲ្យទឹកជ្រាបចូលអណ្តូង | | |
| ៨ | គ្មានរបងជុំវិញអណ្តូង(ឬបាក់បែកទាំងស្រុង) | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## ប្រព័ន្ធត្រងទឹកភ្លៀង

ពិនិត្យមើលប្រភពទឹក ហើយសិក្សាពីស្ថានភាពតាមរយៈសំនួរខាងក្រោម៖

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | ដំបូលកខ្វក់ (លាមកសត្វ សំរាម ស្លឹកឈើ...) | | |
| ២ | ទត្រងទឹកភ្លៀង អត់មានប្រព័ន្ធបញ្ចៀសទឹកភ្លៀងដំបូង កខ្វក់ ឬស្ទះ | | |
| ៣ | អាង/ពាងត្រងទឹកភ្លៀង ឬរ៉ូប៊ីណេ មិនស្អាត (ឧ. ភក់ជ្រាំ លាមកសត្វ ឬសំរាមផ្សេងៗ) | | |
| ៤ | អាង/ពាងត្រងទឹកភ្លៀងអត់មានគម្របគ្រប | | |
| ៥ | អាង/ពាងប្រេះ ឬបែកបាក់ | | |
| ៦ | រ៉ូប៊ីណេសម្រាប់យកទឹកអត់មាន ឬមានតែជ្រាបទឹក ឬខូច | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## ផ្នែកទី ២៖ ការយកទឹក និងការស្តុកទឹកប្រើប្រាស់

ពិនិត្យមើលស្ថានភាពការយកទឹកតាមរយៈសំនួរខាងក្រោម៖

សូមបង្ហាញពីសម្ភារប្រើប្រាស់សម្រាប់យកទឹកពីប្រភពទឹក

☐ ប្រើធុង ☐ ប្រើម៉ាស៊ីនបូម ☐ ផ្សេងៗ.......................

**ធុងដងទឹក**

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | ធុងទឹកប្រើសម្រាប់ធ្វើអ្វីផ្សេង ក្រៅពីដងទឹក | | |
| ២ | ធុងគ្មានគម្រប | | |
| ៣ | ធុងទាំងក្នុង និងក្រៅមិនស្អាត | | |
| ៤ | ធុងទុកដាក់នៅកន្លែងគ្មានសុវត្ថិភាព ដែលអាចធ្វើឲ្យឆ្លងមេរោគ | | |
| ៥ | ធុងទឹក ជាធុងថ្នាំលាបផ្ទះ ឬធុងថ្នាំបាញ់សំលាប់សត្វល្អិត | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

### អាង/ពាងស្តុកទឹកប្រើប្រាស់

ពិនិត្យមើលស្ថានភាពការយកទឹកតាមរយៈសំនួរខាងក្រោម៖

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | អាង/ពាងប្រើសម្រាប់ដាក់អ្វីផ្សេងទៀត ក្រៅពីដាក់ទឹក | | |
| ២ | មានប្រភពកខ្វក់ (ភក់ជ្រាំ សត្វ សំរាម) ជុំវិញអាង/ពាង | | |
| ៣ | អាង/ពាងគ្មានគម្រប/គ្មានកំណល់ | | |
| ៤ | អាង/ពាងគ្មានរ៉ូប៊ីណេ | | |
| ៥ | រ៉ូប៊ីណេជ្រាបទឹក ឬខូច | | |
| ៦ | អត់មានកម្រាលសាបនៅផ្នែកខាងក្រោមរ៉ូប៊ីណេ កខ្វក់ ឬខូច | | |
| ៧ | ផ្នែកណាមួយ នៃអាង/ពាងជ្រាប ឬខូច | | |
| ៨ | ខាងក្នុងអាង/ពាងមិនស្អាត (មានកករ សត្វល្អិត ឬកម្ទេចកម្ទី) | | |
| ៩ | សម្ភារយកទឹកប្រើប្រាស់ទុកគ្មានអនាម័យ (ខាងក្រៅ លើដី) | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

**ផ្នែកទី ៣ ៖ ទឹកផឹក**

## ទឹកសម្រាប់ផឹក

សួរអំពីទឹកផឹក ទៅកាន់គ្រួសារ

១. តើអ្នកផឹកទឹកឆៅ ឬទឹកបន្សុទ្ធ?

☐ដាំជាប្រចាំ ☐ទឹកដាំម្តងម្កាល ☐ ក្នុងករណីចាំបាច់ ម្តងម្កាល ☐ មិនដែល

២. ប្រសិនបើ ទឹកបានបន្សុទ្ធ តើវិធីអ្វីដែលអ្នកប្រើ?

| វិធីសាស្ត្រ | |
|---|---|
| ☐ ដាំ<br>☐ ទិញទឹកដប ២០ លីត្រ<br>☐ ធុងចម្រោះ (................................)<br>☐ច្រោះដោយក្រណាត់តែមួយមុខ<br>☐ ប្រើសារធាតុគីមី (..........................)<br>☐ប្រកទឹកដាក់ដបហាលថ្ងៃ (SODIS)<br>☐ផ្សេងៗ........................................ | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## សម្ភារបន្សុទ្ធទឹក

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត | មិនដឹង |
|---|---|---|---|---|
| **ទឹកដាំ** | | | | |
| ១ | កំសៀវទឹក/ឆ្នាំង ប្រើដាំទឹកផង និងទុកទឹកសម្រាប់ផឹកផង (គ្មានការទុកដាក់ដាច់ដោយឡែកពីគ្នា ហើយជ្រមុជកែវ/ផ្តិលដួសទឹកផឹក) | | | |
| ២ | ប្រើកែវមានដៃសម្រាប់ដួសទឹកផឹក | | | |
| ៣ | កំសៀវ/ឆ្នាំងដាំទឹកគ្មានគម្រប | | | |
| ៤ | កំសៀវ/ឆ្នាំងទុកនៅកន្លែងមិនស្អាតដែលអាចឲ្យធូលី សត្វ សំរាមចូល | | | |
| ៥ | កំសៀវ/ឆ្នាំងគ្មានទឹក ឬទុកចោលយូរ | | | |
| **ទឹកបន្សុទ្ធដោយច្រោះ** | | | | |
| ៧ | ធុងចម្រោះគ្មានរ៉ូប៊ីណេ | | | |

| | | | | |
|---|---|---|---|---|
| ៨ | ធុងចម្រោះជ្រាបទឹក ប្រេះ ខូច ឬស្ថានភាពងាយខូច | | | |
| ៩ | ធុងចម្រោះស្ងួត/មិនបានប្រើយូរមកហើយ | | | |
| ១០ | ធុងចម្រោះទុកនៅកន្លែងមិនស្អាតដែលធូលី សត្វ សំរាមចូល | | | |
| ១១ | ចំពោះចម្រោះសេរ៉ាមិច_ផើងមិនបានលាងសំអាត<br>ចំពោះធុងចម្រោះជីវសាស្ត្រ_មិនដែលលាងសំអាត មិនគ្រប ប្រើអស់ទឹក | | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## សម្ភារដាក់ទឹកផឹក

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត | មិនដឹង |
|---|---|---|---|---|
| ១ | ធុងទឹកប្រើប្រាស់ផ្សេងៗទៀត ក្រៅពីដាក់ទឹកផឹក | | | |
| ២ | ធុងទឹកដាក់នៅកន្លែងដែលមានធូលី សត្វ សំរាម ចូលធ្វើឲ្យទឹកកខ្វក់ | | | |
| ៣ | ធុងទឹកគ្មានគម្រប | | | |
| ៤ | ធុងទឹកគ្មានរ៉ូប៊ីណេ ឬជ្រាប ខូច (ឧ. ប្រើប្រដាប់ដួសមានដៃ) | | | |
| ៥ | ធុងទឹកជ្រាប ខូច ឬស្ថានភាពជិតខូច | | | |
| ៧ | ផ្នែកខាងក្នុងធុងមិនស្អាត (កករ សត្វល្អិត ឬកម្ទេចកម្ទី) | | | |
| ៨ | ធុង ឬបីដុងដាក់ទឹក ជាធុងថ្នាំសំលាប់សត្វល្អិត | | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖

## សម្ភារដងទឹកផឹក- កែវ ឬផ្តិល

| ល.រ | អង្កេតអនាម័យ | ពិត | មិនពិត |
|---|---|---|---|
| ១ | សម្ភារដងទឹកផឹកទុកលាយឡំជាមួយសម្ភារផ្ទះបាយផ្សេងៗ | | |
| ២ | សម្ភារដងទឹកផឹកមិនស្អាត | | |
| ៣ | សម្ភារដងទឹកផឹកទុកនៅកន្លែងមិនស្អាត ឬដាក់ផ្ទាល់លើរនាប | | |
| ៤ | សម្ភារដងទឹកផឹកផ្កាប់ចុះក្រោម ផ្ទាល់លើរនាប | | |
| ៥ | សត្វអាចចូលទៅក្បែរសម្ភារដងទឹកផឹក | | |

កំណត់ត្រាការអង្កេតឃើញផ្សេងៗទៀត៖